សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal university of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការលែងលះ

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **កញ្ញា លឹម សោភា**

**កញ្ញា គង់ ឡៃហេង**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ **សុខ ចិន្តា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៤

ឆ្នាំចូលរៀន ២០២០

ឆ្នាំសរសេរសារណា ២០២៤

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


**សារណាបញ្ចប់ការសិក្សា**

# ការលែងលះ

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **កញ្ញា លឹម សោភា**

**កញ្ញា គង់ ឡៃហេង**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ **សុខ ចិន្តា**



ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៤

ឆ្នាំចូលរៀន ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **លឹម សោភា** និងនាងខ្ញុំឈ្មោះ **គង់ ឡៃហេង** ជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រនៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី២៤ ឆ្នាំសិក្សា២០២០-២០២៤។

ជាបឋមនាងខ្ញុំ សូមលំឱនកាយវាចាចិត្តដើម្បីសម្តែងការគោរព ការដឹងគុណ និងកតញ្ញុតាធម៌ យ៉ាងជ្រាលជ្រៅបំផុតជូនចំពោះអ្នកមានគុណទាំងទ្វេគឺ **លោកឪពុក និងអ្នកម្តាយ** ដែលបានផ្តល់កំណើត ខិតខំប្រឹងប្រែងក្នុងការចិញ្ចឹមបីបាច់ថែរក្សាតាំងពីតូចក្រូចឆ្មារហូតដល់ធំធាត់ពេញវ័យ ព្រមទាំងបានផ្តល់នូវភាពកក់ក្តៅ សេចក្តីស្រឡាញ់ និងការអប់រំទូន្មានប្រៀនប្រដៅកូនៗប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងជម្រុញ និងលើកទឹកចិត្តក្នុងការបញ្ជូនកូនៗទៅទទួលការអប់រំ។ មិនតែប៉ុណ្ណោះ លោកទាំងពីរបានផ្តល់នូវការផ្គត់ផ្គង់ថវិការ និងសិក្ខាបករណ៍ចាប់តាំងពីកម្រិតបឋមសិក្សា មធ្យមសិក្សា រហូតដល់ថ្នាក់បរិញ្ញាបត្រធ្វើឱ្យកូនចងចាំជានិច្ចដោយមិនអាចបំភ្លេចបាន។

សូមគោរពថ្លែងអរគុណចំពោះ **ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង គណៈគ្រប់គ្រង ព្រមទាំងលោក លោកស្រីសាស្ត្រាចារ្យ** ទាំងអស់នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀន អប់រំទូន្មាន លះបង់ពេលវេលា ព្រមទាំងកម្លាំងកាយកម្លាំងចិត្តដល់ខ្ញុំទាំងពីរក្នុងរយៈពេលបួនឆ្នាំកន្លងមកដើម្បីឱ្យនាងខ្ញុំទាំងពីរ ទទួលបាននូវចំណេះដឹង ផ្នែកនីតិសាស្ត្រ ទៅលើបញ្ហានានាដែលពាក់ព័ន្ធទៅនឹងច្បាប់ជាតិ ព្រមទាំងច្បាប់អន្តរជាតិថែមទៀតផង។ ជាពិសេស សូមថ្លែងអំណរគុណចំពោះ **លោកស្រីសាស្ត្រាចារ្យជំនួយ សុខ ចិន្តា** ដែលជាសាស្ត្រាចារ្យណែនាំដើម្បីធ្វើឱ្យមាននូវដំណើរការ នៃកិច្ចការស្រាវជ្រាវនេះឡើងប្រកបដោយភាពជោគជ័យ។ ជាពិសេសទៀតនោះ គាត់បានចំណាយកម្លាំងកាយកម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃក្នុងការប្រឹងប្រែងពន្យល់ណែនាំតម្រង់ទិសផ្តល់ឯកសារពាក់ព័ន្ធ និងអនុសាសន៍ល្អៗ និងជួយកែលម្អចំណុចខ្វះខាតទាំងឡាយ ដើម្បីធ្វើយ៉ាងណាឱ្យកិច្ចការស្រាវជ្រាវមួយនេះ បានទទួលនូវលទ្ធផលល្អ និងត្រឹមត្រូវ។

ជាចុងក្រោយក៏សូមថ្លែងអំណរគុណ និងសូមប្រសិទ្ធិពរជ័យដល់វត្ថុស័ក្តសិទ្ធិក្នុងលោកសូមជួយថែរក្សាដល់លោកទាំងអស់ដែលបានរៀបរាប់ខាងលើ ជួបតែពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ព្រមទាំងឧទ្ទិសដល់ទេវតា ឥន្ទព្រហ្មជួយឱ្យប្រទេសជាតិយើង រួមទាំងប្រជាជនកម្ពុជាទាំងអស់ ជួបតែសន្តិភាព សុវត្ថិភាព និងអភិវឌ្ឍន៍រីកចម្រើនឆ្ពោះទៅមុខជានិរន្តន៍។

# អារម្ភកថា

បន្ទាប់ពីបានសិក្សារៀនសូត្រទៅលើថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះអស់រយៈពេល៤ឆ្នាំមកនេះ នាងខ្ញុំទាំងពីរនាក់ទទួលបានចំណេះដឹងព្រមទាំងទទួលបាននូវបទពិសោធន៍ជាច្រើន ពីលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ ដែលលោកបានខិតខំប្រឹងប្រែងបង្ហាត់បង្រៀនអស់ពីកម្លាំងកាយ និងកម្លាំងចិត្តមកដល់ក្រុមនាងខ្ញុំ។ ដោយមានការលើកទឹកចិត្តពីសំណាក់មត្តិភក្តិ និងលោកគ្រូអ្នកគ្រូ ទើបធ្វើឱ្យនាងខ្ញុំទាំងពីរសម្រេចចិត្ត នៅក្នុងការជ្រើសរើសការសរសេរសារណាបញ្ចប់ការសិក្សានេះសម្រាប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។ ការសរសេរសារណានេះមិនមែនជាការងាយស្រួលនោះទេ គឺត្រូវការអ្នកដែលមានសមត្ថភាព និងមានចំណេះដឹងក្នុងការចងក្រងសារណាមួយឡើងឱ្យកាន់តែល្អ ពីព្រោះមុននិងទទួលបានជោគជ័យតែងតែជួបនៅទុក្ខលំបាកជាមុនសិន។

ក្នុងការសរសេរសារណានេះពួកខ្ញុំទាំងពីរបានជ្រើសរើសប្រធានបទអំពី "ការលែងលះ" នេះជាស្នាដៃថ្មីមួយរបស់ក្រុមនាងខ្ញុំទាំងពីរ ដែលបានរៀបចំចងក្រងឡើងចុងក្រោយនៃការបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។ គោលបំណងរបស់ពួកខ្ញុំនោះ គឺចង់ទុកនៅស្នាដៃមួយនេះ ដើម្បីជួយសម្រួលឱ្យសិស្សនិស្សិតជំនាន់ក្រោយងាយស្រួលក្នុងការស្រាវជ្រាវ។ ដោយសារតែបុគ្គលមួយចំនួន ដែលមានបញ្ហានៅក្នុងចំណងអាពាហ៍ពិពាហ៍ ដោយមានការរស់នៅមិនចុះសម្រុងនិងគ្នាក្នុងរង្វង់គ្រួសារ មានការឈ្លោះប្រកែក រកាំរកូសរវាងគ្នានិងគ្នា ពេលខ្លះអាចឈានដល់ការប្រើប្រាស់អំពើហិង្សា ទើបធ្វើឱ្យបុគ្គលដែលមានជាប់ចំណងនេះមានបំណងផ្តាច់ចំណងអាពាហ៍ពិពាហ៍ទៅតាមនីតិវិធីនៃច្បាប់។

ក្រុមនាងខ្ញុំសង្ឃឹមថាសារណាមួយនេះនឹងអាចជាជំនួយទៅដល់អ្នកស្រាវជ្រាវ និងសិស្សានុសិស្សជំនាន់ក្រោយ ក៏ដូចជាប្រជាពលរដ្ឋគ្រប់រូបស្វែងយល់បន្ថែម និងកាន់តែច្បាស់អំពីប្រធានបទនៃការលែងលះមួយនេះ។

ក្រុមនាងខ្ញុំទាំងពីរនាក់សូមអភ័យទោសរាល់កំហុសខុសឆ្គង ព្រមទាំងចំណុចខ្វះខាតមួយចំនួនដោយអចេតនា ដូចជាពាក្យពេចន៍ ឬអក្ខរាវិរុទ្ធ ដែលមាននៅក្នុងកិច្ចការសារណារបស់ក្រុមនាងខ្ញុំ។ នាងខ្ញុំទាំងពីរនាក់នឹងទទួលរាល់ពាក្យរិះគន់គ្រប់បែបយ៉ាងក្នុងន័យស្ថាបនា និងយោបល់ល្អៗ ដើម្បីធ្វើការកែសម្រួលឡើងវិញឱ្យកាន់តែប្រសើរឡើងថែមមួយកម្រិតទៀត។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃការលែងលះ**

**១.១. ទិដ្ឋភាពទូទៅ** ........................................ ៥

**១.២. មូលហេតុនៃការលែងលះក្នុងក្រមរដ្ឋប្បវេណី** ........................................ ៦

**១.២.១. មូលហេតុដែលអាចលែងលះបាន** ........................................ ៦

១.២.១.១. ការប្រព្រឹត្តអំពើផិតក្បត់ទៅលើសហព័ទ្ធ ........................................ ៦

១.២.១.២. ការបោះបង់ចោលសហព័ទ្ធដោយគ្មានមូលហេតុត្រឹមត្រូវ ........................................ ៧

១.២.១.៣. ការបាត់ដំណឹងរបស់សហព័ទ្ធអស់រយៈពេលជាង ១(មួយ)ឆ្នាំ ដោយមិនដឹងថាសហព័ទ្ធស្លាប់ ឬរស់ ........................................ ៨

១. ២. ១. ៤. ការរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង ១(មួយឆ្នាំ) ........................................ ៩

១.២.១.៥. ករណីទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ........................................ ៩

**១.២.២. មូលហេតុរារាំងនៃការលែងលះ** ........................................ ១១

១.២.២.១. ការលែងលះដែលប៉ះពាល់ដល់ការទ្រទ្រង់ជីវភាព ឬការឈឺចាប់របស់សហព័ទ្ធ ឬកូន ........................................ ១១

១.២.២.២. ការលែងលះដោយមានគំនិតទុច្ចរិត ........................................ ១២

**១.៣. ប្រភេទនៃការលែងលះ** ........................................ ១៣

**១.៣.១. ការលែងលះដោយមានការព្រមព្រៀង** ........................................ ១៣

**១.៣.២. ការលែងលះដោយគ្មានការព្រមព្រៀង** ........................................ ១៤

**ជំពូកទី២**

**ការលែងលះដោយមានការព្រមព្រៀង**

**២.១. នីតិវិធីនៃការលែងលះដោយមានការព្រមព្រៀង** ........................................ ១៥

**២.១.១. ការដាក់ពាក្យសុំលែងលះ** ........................................ ១៥

២.១.១.១. ការដាក់ពាក្យសុំលែងលះដោយលាយលក្ខណ៍អក្សរ ........................................ ១៥

២.១.១.២. ការដាក់ពាក្យសុំលែងលះដោយផ្ទាល់មាត់ ........................................ ១៧

**២.១.២. សមត្ថកិច្ចដោះស្រាយ** ..................................................... ១៨
២.១.២.១. អាជ្ញាធរឃុំ-សង្កាត់ ..................................................... ១៨
២.១.២.២. សាលាដំបូងរាជធានីខេត្ត..................................................... ១៨
**២.១.៣. នីតិវិធីដោយមានការព្រមព្រៀងនៅតុលាការ** ..................................................... ១៩
២.១.៣.១. ការពិនិត្យពាក្យសុំ..................................................... ១៩
២.១.៣.២. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការទាញហេតុផលផ្ទាល់មាត់..................................................... ២០
២.១.៣.៣. ការចេញដីកាសម្រេចតុលាការ ..................................................... ២១
**២.២. អានុភាពនៃការលែងលះដោយមានការព្រមព្រៀង**..................................................... ២១
**២.២.១. ការផ្តាច់ទំនាក់ទំនងគតិយុត្ត** ..................................................... ២១
២.២.១.១. ការផ្តាច់ទំនាក់ទំនងរវាងសហព័ទ្ធ ..................................................... ២១
២.២.១.២. ការផ្តាច់ទំនាក់ទំនងរវាងញាតិពន្ធ..................................................... ២២
**២.២.២. សិទ្ធិ និងកាតព្វកិច្ចក្រោយការលែងលះ**..................................................... ២២
២.២.២.១. សិទ្ធិបន្សល់ក្រោយការលែងលះ ..................................................... ២២
២.២.២.២. កាតព្វកិច្ចបន្សល់ក្រោយការលែងលះ ..................................................... ២៥

## ជំពូកទី៣

## ការលែងលះដោយគ្មានការព្រមព្រៀង

**៣.១. នីតិវិធីនៃការលែងលះដោយគ្មានការព្រមព្រៀង**..................................................... ២៧
**៣.១.១. ការធ្វើពាក្យបណ្តឹងលែងលះ**..................................................... ២៧
៣.១.១.១. ការសរសេរពាក្យបណ្តឹង..................................................... ២៧
៣.១.១.២. ការដាក់ពាក្យបណ្តឹង ..................................................... ២៨
៣.១.១.៣. ការទទួលពាក្យបណ្តឹង..................................................... ២៩
៣.១.១.៤. ការពិនិត្យ និងបញ្ជូនពាក្យបណ្តឹង ..................................................... ៣០
**៣.១.២. ការផ្សះផ្សា**..................................................... 31
**៣.១.៣. ការចាត់ចែងរក្សាការពារ** ..................................................... ៣១
៣.១.៣.១. វិធានការដាក់ឱ្យសហព័ទ្ធរស់នៅបែកគ្នាជាបណ្តោះអាសន្ន ..................................................... ៣១

៣.១.៣.២. វិធានការថែរក្សាកូនជាបណ្ដោះអាសន្ន ........ ៣៣

៣.១.៣.៣. វិធានការថែរក្សាទ្រព្យជាបណ្ដោះអាសន្ន ........ ៣៣

៣.១.៣.៤. វិធានការផ្ដត់ផ្គង់សហព័ទ្ធ ឬកូនជាបណ្ដោះអាសន្ន ........ ៣៣

៣.១.៣.៥. ធ្វើការរឹបអូសជាបណ្ដោះអាសន្ន ........ ៣៤

**៣.១.៤. នីតិវិធីត្រៀមសម្រាប់ទាញហេតុផល** ........ ៣៤

**៣.១.៥. នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់** ........ ៣៥

**៣.១.៦. ការសម្រេចសេចក្ដី** ........ ៣៦

៣.១.៦.១. ការចេញសាលក្រមលែងលះ ........ ៣៦

៣.១.៦.២. ទម្រង់នៃសាលក្រមនៃការលែងលះ ........ ៣៧

៣.១.៦.៣. ការប្រកាសសាលក្រម ........ ៣៨

៣.១.៦.៤. ការចូលជាស្ថាពរនៃសាលក្រម ........ ៣៨

**៣.២. អានុភាពនៃការលែងលះដោយគ្មានការព្រមព្រៀង** ........ ៣៨

**៣.២.១. ការកាត់ផ្ដាច់ទំនាក់ទំនងគតិយុត្ត** ........ ៣៩

**៣.២.២. សិទ្ធិ និងកាតព្វកិច្ចដែលបន្សល់ក្រោយការលែងលះ** ........ ៣៩

៣.២.២.១. សិទ្ធិដែលបន្សល់ទុកក្រោយការលែងលះ ........ ៣៩

៣.២.២.២. កាតព្វកិច្ចដែលបន្សល់ទុកក្រោយការលែងលះ ........ ៤១

**សេចក្ដីសន្និដ្ឋាន** ........ ៤៣

**អនុសាសន៍** ........ ៤៥

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងសង្គមខ្មែរយើងនេះ តាមច្បាប់ធម្មជាតិមនុស្សម្នាក់ៗកើតមកតែងតែមានគូ ព្រមទាំងត្រូវការស្នេហាដើម្បីបំពេញចន្លោះនៃជីវិត ហើយការជ្រើសរើសគូគ្រងដែលជាគូអនាគតពិតជាមានសារៈសំខាន់ខ្លាំងណាស់ ព្រោះថាប្រសិនបើរើសត្រូវនោះវានឹងធ្វើឱ្យយើងមានសេចក្ដីសុខសុភមង្គល ប៉ុន្តែប្រសិនបើយើងរើសខុសនោះវានិងធ្វើឱ្យយើងជួបនូវទុក្ខលំបាកវេទនា។ ជាក់ស្ដែង ការរៀបអាពាហ៍ពិពាហ៍ គឺក្នុងគោលបំណងបង្កើតគ្រួសារមួយ ដើម្បីអាចក្លាយទៅជាគូស្វាមីភរិយានឹងគ្នាបាននោះ យើងត្រូវឆ្លងកាត់នូវការរៀបអាពាហ៍ពិពាហ៍ជាមុនសិន ការរៀបអាពាហ៍ពិពាហ៍នេះ គឺសំដៅលើការបង្ហាញឆន្ទៈ ក្នុងការបង្កើតចំណងគតិយុត្តចងភ្ជាប់រូបវន្តបុគ្គលឱ្យក្លាយទៅជាសហព័ទ្ធស្របច្បាប់តាមរយៈការចុះសំបុត្រអាពាហ៍ពិពាហ៍។ ដើម្បីកសាងគ្រួសារមួយឱ្យមានសុភមង្គលបាននោះមនុស្សពីរនាក់ត្រូវចេះមើលថែគ្នាទៅវិញទៅមក ការពារគ្នា អំណត់អត់ធន់ ចេះអត់ឱនអាធ្យាស្រ័យឱ្យគ្នាទៅវិញទៅមក ទោះបីមានឧបសគ្គអ្វីក៏ដោយក៏មិនបោះបង់គ្នា បើទោះស្ថិតនៅក្នុងដំណាក់កាលណាក៏ដោយ។ គួរកត់សម្គាល់ផងដែរថា ប្រសិនបើមានតែការរៀបអាពាហ៍ពិពាហ៍តែមួយមុខនោះក៏មិនកើតដែរ ព្រោះនៅក្នុងប្រទេសកម្ពុជា ការរៀបអាពាហ៍ពិពាហ៍ដែរស្របច្បាប់ គឺការចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នា តែបើគ្មានសំបុត្រអាពាហ៍ពិពាហ៍ ឬមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍នោះទេ ហើយមានការរស់នៅជាមួយគ្នានោះគេហៅភាគីនោះថា អនីតិសង្វាសនឹងគ្នា។ បែបនេះហើយ ទើបការរៀបអាពាហ៍ពិពាហ៍ដែលទទួលស្គាល់ដោយច្បាប់នេះ ហើយភាគីមិនអាចរំលាយបានដោយងាយៗនោះទេ បើធៀបនិងការរៀបអាពាពិពាហ៍តែមួយមុខនោះ។

ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងជីវិតជាស្វាមីភរិយានឹងគ្នា វាតែងតែគេចមិនរួចពីបញ្ហានៅក្នុងគ្រួសារបានឡើយ។ គ្រាន់តែគ្រួសារខ្លះជួបបញ្ហាតូចអាចសម្រួលគ្នាបាន តែពេលខ្លះជួបបញ្ហាធំៗពិបាកក្នុងការដោះស្រាយគ្នា ដែលអាចឈានដល់ការរស់នៅបែកបាក់គ្នាមួយរយៈ ឬពេលខ្លះទៀតអាចឈានទៅដល់ការលែងលះគ្នាក៏ថាបាន ដូចសុភាសិតមួយពោលថា *"ចានក្នុងរាវគង់តែនឹងរណ្ដំគ្នា"* អ្វីដែលសំខាន់នោះគ្រួសារមួយត្រូវចេះដោះស្រាយរឿងដែលកើតមិនល្អនោះពីរឿងធំទៅរឿងតូច ពីរឿងតូចទៅជាអត់មានរឿងអ្វីកើតឡើង ព្រោះថាគ្រួសារមួយណាក៏គេតែងតែជួបបញ្ហាដែរគ្រាន់តែតិច និងច្រើនតែប៉ុណ្ណឹង។ នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ គឺមិនបានបង្ខិតបង្ខំឱ្យប្រជាពលរដ្ឋដែលរស់នៅមិនចុះសម្រុងនឹងគ្នានោះទ្រាំរស់នៅជាមួយគ្នាដោយបៀមនូវទុក្ខឈឺចាប់វេទនា ឈឺចាប់ពើតផ្សាក្នុងជីវិតរបស់ខ្លួននោះទេច្បាប់បានចែងយ៉ាងច្បាស់ អំពីការលែងលះប្រសិនបើភាគីណាម្ខាងទទួលយកមិនបាននូវរាល់ទង្វើរបស់ភាគីម្ខាងទៀតនោះ ភាគីនោះអាចដាក់ពាក្យសុំ

លែងលះគ្នាបានទៅតាមច្បាប់ដែលបានចែងបានផងដែរ។ ប៉ុន្តែប្រសិនបើគូស្វាមីភរិយា ដែលមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍នឹងគ្នាទេនោះ គឺមិនបាច់ដាក់ពាក្យសុំការលែងលះនោះទេ យើងគ្រានតែរស់នៅបែកគ្នាទៅបានហើយ។

អាស្រ័យដូចនេះហើយ នៅក្នុងពេលបច្ចុប្បន្នយើងនេះឃើញថាកំណើននៃការលែងលះនេះកាន់តែច្រើនពីមួយឆ្នាំទៅមួយឆ្នាំទោះក្នុងករណីលែងលះដោយព្រមព្រៀងគ្នាក្តី ដោយគ្មានការព្រមព្រៀងគ្នាក្តី ដូច្នេះបញ្ហាតែងតែមាននូវដំណោះស្រាយជានិច្ច ចំពោះដំណោះស្រាយនោះគឺជាច្បាប់ ឬអាចហៅថាបទបញ្ញត្តិ។ នៅក្នុងប្រទេសកម្ពុជា ច្បាប់ដែលអាចដោះស្រាយរឿងក្តីលែងលះនេះមានដូចជា៖ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, ច្បាប់ស្តីពី នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ២០១០ និងព្រមទាំងច្បាប់ស្តីពី នីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ២០១០ ជាអាទិ៍។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយឃើញថាការលែងលះនេះមានជាប់ពាក់ព័ន្ធជាច្រើនចំណុចទើបធ្វើឱ្យមានការលើកឡើងនូវចម្ងល់ជាច្រើននៅជុំវិញការលែងលះមួយនេះ។

- តើមូលហេតុអ្វីខ្លះដែលបណ្តាលឱ្យមានការលែងលះកើតមានឡើង?
- តើការលែងលះមានប៉ុន្មានប្រភេទ?
- តើការលែងលះដោយមានការព្រមព្រៀងត្រូវប្រព្រឹត្តបែបណាខ្លះ តាមរយៈការដោះស្រាយនៅក្នុងប្រព័ន្ធតុលាការ?
- តើការលែងលះដោយគ្មានការព្រមព្រៀងត្រូវប្រព្រឹត្តបែបណាខ្លះ តាមរយៈការដោះស្រាយនៅក្នុងប្រព័ន្ធតុលាការ?
- តើការលែងលះបានបន្សល់ទុកអានុភាពអ្វីខ្លះដល់ភាគី និងអ្នកដែលពាក់ព័ន្ធ?
- តើការបែងចែក កូន ទ្រព្យសម្បត្តិ អាហាកាតព្វកិច្ចផ្សេងៗទៀតដោយរបៀបណា?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ដោយសង្កេតឃើញថា ការលែងលះនេះមានភាពស្មុគស្មាញជាខ្លាំង ហើយព្រមទាំងបានបន្សល់ទុកនូវចម្ងល់ជាច្រើនដល់អ្នកសិក្សាស្រាជ្រាវ បងប្អូនសិស្សានុសិស្ស និស្សិតដែលកំពុងតែសិក្សា វិសេសជាងនេះទៅទៀតនោះ គឺមហាជនដែលរស់នៅក្នុងសង្គមខ្មែរយើងនេះតែម្តង ទើបធ្វើឱ្យក្រុមនាងខ្ញុំមានការចាប់អារម្មណ៍ទៅលើប្រធាបបទនេះយ៉ាងខ្លាំង ហើយក៏ឈានដល់លើកយកប្រធាបបទមួយនេះមកធ្វើការសិក្សាស្រាវជ្រាវឱ្យ

កាន់តែស៊ីជម្រៅថែមទៀត។ មួយវិញទៀតការលែងលះនេះ គឺមានច្បាប់ជាច្រើនដែលជាប់ពាក់ព័ន្ធទៅលើប្រធានបទមួយនេះ ហើយបន្ថែមពីនេះទៀតនីតិវិធីនៃការដោះស្រាយរបស់វាមានភាពខុសប្លែកពីគ្នា។ ម្យ៉ាងវិញទៀត ក្រុមនាងខ្ញុំពិតជាចង់ស្វែងយល់អំពីមូលហេតុនៃការលែងលះ នីតិវិធីនៃការលែងលះ ការបែងចែកទ្រព្យសម្បត្តិ ព្រមទាំងអំណាចមេបាជាដើម។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ដោយមើលឃើញថាការលែងលះនេះពិតជាមានច្រើនប្រភេទខ្លាំងណាស់ដូចជា៖ ការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ, ការលែងលះរវាងពលរដ្ឋខ្មែរ និងជនបរទេស, ការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ តែស្ថិតនៅលើទឹកដីបរទេស និងនៅមានករណីផ្សេងៗជាច្រើនទៀត។ ដូច្នេះក្រុមនាងខ្ញុំសូមសិក្សាស្រាវជ្រាវត្រឹមតែការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ ដែលធ្វើនៅលើទឹកដីខ្មែរ នៃព្រះរាជាណាចក្រកម្ពុជាយើងតែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

សារណានេះទុកជំនួយស្មារតីដល់បញ្ញវន្តក៏ដូចជាមិត្តអ្នកសិក្សាស្រាវជ្រាវស្វែងយល់ពីការលែងលះដើម្បីយល់ដឹងបន្ថែមអំពីមូលហេតុនៃការលែងលះ ថាតើយើងមានមូលហេតុយ៉ាងណាខ្លះទើបអាចដាក់ពាក្យសុំលែងលះបាននៅក្នុងករណីដែលមិនមានការយល់ព្រមពីភាគីណាម្ខាង ព្រមទាំងចង់ស្វែងយល់អំពីលំហូនីតិវិធីនៃការលែងលះពីមួយទៅមួយថាមានភាពស្មុគស្មាញបែបណាខ្លះ និងមានភាពងាយស្រួលយ៉ាងមិចខ្លះ។ ជាពិសេសនោះ គឺការដោះស្រាយអំពីការលែងលះនេះតាមបញ្ញត្តិច្បាប់ដែលបានចែង និងដោះស្រាយចម្ងល់ការលែងលះដែលកំពុងកើតមានជាច្រើននាពេលបច្ចុប្បន្ននេះ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

នៅក្នុងនាមក្រុមនាងខ្ញុំជានិស្សិតដែលកំពុងសិក្សាផ្នែកនីតិសាស្ត្រ ដែលជាអ្នកសិក្សាស្រាវជ្រាវនូវរាល់ឯកសារជាបទដ្ឋានគតិយុត្តជាធរមាន និងឯកសារដែលជាផ្លូវការ ព្រមទាំងធ្វើការបកស្រាយនៅក្នុងសារណាបញ្ចប់ការសិក្សានេះ ក្រុមនាងខ្ញុំបានសិក្សា និងដកស្រង់នូវអត្ថន័យនៃខ្លឹមសារ ដែលជាប់ពាក់ព័ន្ធនឹងសារណាមួយនេះចេញពីប្រភពឯកសារផ្សេងៗដែលរួមមានការជាប់ពាក់ព័ន្ធទៅនឹងការលែងលះ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដូចនេះ ប្រធានបទស្រាវជ្រាវអំពី "ការលែងលះ" ខាងលើនេះក្រុមនាងខ្ញុំសុំធ្វើការបែងចែកជា ៣ ជំពូកដូចខាងក្រោម៖

- **សេចក្តីផ្តើម**
- **ជំពូកទី១៖ សញ្ញាណទូទៅនៃការលែងលះ** នៅក្នុងជំពូកនេះក្រុមនាងខ្ញុំបកស្រាយជុំវិញអំពីមូលហេតុដែលនាំឱ្យមានការលែងលះ និងប្រភេទនៃការលែងលះ។
- **ជំពូកទី២៖ ការលែងលះដោយមានការព្រមព្រៀង** ដែលបកស្រាយអំពី នីតិវិធីនៅក្នុងការដោះស្រាយរឿងក្តីនៃការលែងលះ ក្នុងករណីដែលភាគីទាំងពីរមានការព្រមព្រៀងគ្នាក្នុងការបញ្ចប់ទំនាក់ទនងអាពាហ៍ពិពាហ៍ដោយសន្តិវិធី និងគ្មានការខ្វែងគំនិតគ្នាទៅចំណុចណាមួយ និងអានុភាពដែលបន្សល់ទុកក្រោយការលែងលះគ្នា ជាពិសេសគឺបកស្រាយអំពីការបែងចែកសិទ្ធិ និងកាតព្វកិច្ចទាំងឡាយ។
- **ជំពូកទី៣៖ ការលែងលះដោយគ្មានការព្រមព្រៀង** ដែលបកស្រាយអំពីនីតិវិធីនៅក្នុងការលែងលះដោះស្រាយរឿងក្តីលែងលះដែលមានលក្ខណៈជាបណ្តឹង ដោយសារតែភាគីមិនមានការព្រមព្រៀងគ្នាមួយផ្នែក ឬទាំងស្រុងនៅក្នុងការលែងលះ ជាពិសេសនោះ គឺបកស្រាយអំពីការបែងចែកសិទ្ធិ និងកាតព្វកិច្ចទាំងឡាយ។

# ជំពូកទី១

# សញ្ញាណទូទៅនៃការលៃខលះ

# ជំពូកទី១
# សញ្ញាណទូទៅនៃការលែងលះ

## ១.១. ទិដ្ឋភាពទូទៅ

ការរៀបអាពាហ៍ពិពាហ៍ គឺជារឿងមួយដល់សំខាន់សម្រាប់មនុស្សម្នាក់ៗ នៅក្នុងពេលបច្ចុប្បន្ននេះ ពីព្រោះការរៀបអាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឱឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ដែលប្ដេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ហើយដែលមិនអាចរំលាយ ទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន។ អាពាហ៍ពិពាហ៍នឹងមានអានុភាពពេញលក្ខណៈច្បាប់បាន លុះត្រាតែអាពាហ៍ពិពាហ៍នោះធ្វើឡើងស្រប តាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់នេះ។[១] អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាពិសេសមួយដែលខុសពីកិច្ចសន្យាធម្មតា។ ចំពោះកិច្ចសន្យាធម្មតាឱ្យតែសំណើ និងស្ទីការត្រូវគ្នា គឺកិច្ចសន្យាត្រូវបានបង្កើតឡើង ដោយធ្វើជាលាយលក្ខណ៍អក្សរ ឬមិនធ្វើជាលាយលក្ខណ៍អក្សរក៏ដោយ ក៏ប៉ុន្តែកិច្ចសន្យាក្នុងរឿងអាពាហ៍ពិពាហ៍ត្រូវតែធ្វើឱ្យប្រឹតប្រៀងបំផុត និងត្រូវគោរពតាមល័ក្ខខ័ណ្ឌដូចជា៖

- ❖ អាពាហ៍ពិពាហ៍ និងមានអានុភាពដោយការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។
- ❖ ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវធ្វើដោយផ្អែកតាមនីតិវិធីដែលបានកំណត់ក្នុងបញ្ញាត្តិស្តីពីបញ្ជីអត្រានុកូលដ្ឋាន។[២]

មានន័យថា កិច្ចសន្យាក្នុងរឿងអាពាហ៍ពិពាហ៍មិនអាចធ្វើដោយផ្ទាល់មាត់បានទេ ថ្វីបើសំណើសុំនៅក្នុងការរៀបអាពាហ៍ពិពាហ៍ត្រូវគ្នាជាមួយនឹងស្ទីការនៃការរៀបអាពាហ៍ពិពាហ៍ក៏ដោយ។ ហើយបើមិនគោរពតាមល័ក្ខខ័ណ្ឌនេះទេនោះ កិច្ចសន្យាអាពាហ៍ពិពាហ៍មិនត្រូវបានបង្កើតឡើយ។

ដោយឃើញថាការលែងលះនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មិនបានឱ្យនិយមន័យវានោះទេ តែនៅក្នុងច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩ បានឱ្យនិយមន័យទៅលើការលែងលះនេះ ការលែងលះគ្នា គឺជាការផ្ដាច់ចំណងអាពាហ៍ពិពាហ៍របស់ប្ដីប្រពន្ធដែលបានរៀបការពេញច្បាប់ក្នុងពេលរស់នៅទាំងពីរនាក់។[៣] មានន័យថាការលែងលះ គឺជាការរំលាយចំណងអាពាហ៍ពិពាហ៍ ប៉ុន្តែក្នុងករណីដែលសហព័ទ្ធណាម្ខាងបាន

---

[១] ច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ៥៦ ក្រ, ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩, មាត្រា៣។

[២] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៥៥។

[៣] ច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ , លេខ៥៦ ក្រ, ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩, មាត្រា៣៨។

ទទួលមរណភាព ក៏អាពាហ៍ពិពាហ៍ត្រូវរលាយដែរ។ ការរំលាយអាពាហ៍ពិពាហ៍ក្នុងន័យនេះ គឺសំដៅលើការរំដោះខ្លួនឱ្យរួចពីចំណងនៃទំនាក់ទំនងអាពាហ៍ពិពាហ៍ដែលខ្លួនធ្លាប់ជាសហព័ទ្ធ។ ករណីយកិច្ចរួមរស់នៅជាមួយគ្នាសហការគ្នា និងមានករណីកិច្ចសង្គ្រោះគ្នាទៅវិញទៅមកត្រូវរលត់ បើទោះជាសហព័ទ្ធដែលបានលែងលះអះអាងថា ជីវភាពរស់នៅមានការលំបាកក៏ដោយក៏បុគ្គលម្ខាងទៀត ដែលជាអតីតសហព័ទ្ធមិនមានករណីកិច្ចសង្គ្រោះដែរ។ ម្យ៉ាងវិញទៀត ករណីកិច្ចស្មោះត្រង់ក៏រលត់ទៅតាមនោះដោយឯងដែរ ដោយគេអាចរៀបអាពាហ៍ពិពាហ៍ជាថ្មីម្តងទៀតបាន។[៤]

## ១.២. មូលហេតុនៃការលែងលះក្នុងក្រមរដ្ឋប្បវេណី

ជាដំបូងក្រមរដ្ឋប្បវេណីបានអនុញ្ញាតឱ្យមានការលែងលះដោយការព្រមព្រៀងគ្នារវាងគូភាគី ស្របទៅតាមខ្លឹមសារនៃមាត្រា៩៧៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងករណីនេះតុលាការនឹងសម្រេចឱ្យមានការលែងលះគ្នាប្រសិនបើតុលាការយល់ឃើញថា ភាគីទាំងសងខាងមានបំណងពិតប្រាកដ នៅក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍។

សហព័ទ្ធទាំងសងខាងមានសិទ្ធិសេរីភាពពេញលេញក្នុងការលែងលះគ្នា ប៉ុន្តែសិទ្ធិសេរីភាពនេះត្រូវតែគោរពទៅតាមក្រមរដ្ឋប្បវេណីដែលមានចែងអំពីមូលហេតុនៃការលែងលះ ដើម្បីលែងលះស្របទៅតាមនីតិវិធីច្បាប់ ហើយការលែងលះនេះមានករណីដែលអាចការលែងលះបាន និងមានករណីមិនអាចលែងលះបាន។

### ១.២.១. មូលហេតុដែលអាចលែងលះបាន

ប្រសិនបើភាគីមិនមានការព្រៀមព្រៀងលែងលះគ្នាទេនោះការលែងលះនៅតែអាចធ្វើទៅបាន លុះត្រាតែមានមូលហេតុត្រឹមត្រូវយ៉ាងច្បាស់លាស់ដូចមានចែងនៅក្នុងមាត្រា៩៧៩ នៃក្រមរដ្ឋប្បវេណីដូចជា៖

#### ១.២.១.១. ការប្រព្រឹត្តអំពើផិតក្បត់ទៅលើសហព័ទ្ធ

ក្រមរដ្ឋប្បវេណីថ្មីនេះ ការប្រព្រឹត្តអំពើផិតក្បត់ទៅលើសហព័ទ្ធ[៥] នេះបានចាត់ទុកអំពើផិតរបស់សហព័ទ្ធណាមួយនាំឱ្យភាគីម្ខាងទៀតអាចធ្វើជាសំអាងមូលហេតុក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍បាន។

អំពើផិត គឺការរួមសេវនកិច្ចរវាងបុរសដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយជាមួយស្ត្រីដទៃក្រៅពីប្រពន្ធរបស់ខ្លួនការរួមសេវនកិច្ចរវាងស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍មិនទាន់រលាយជាមួយបុរស

---

[៤] គេហទំព័រ https://search.app/?link=https%៣A%២F%២Fkhmer៤eversite.wordpress.com%២Fwp-content%២Fuploads%២F២០១៦%២F០៦%២Fproject-of-law.pdf&utm_source=igadl%២Cigatpdl%២Csh%២Fx%២Fgs%២Fm២%២F៥ ដកស្រង់នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៤។

[៥] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧,មាត្រា៩៧៨ វាក្យខណ្ឌ ក។

ដទៃក្រៅពីប្ដីរបស់ខ្លួន។[៦] មានពិរុទ្ធក្នុងបទផិតប្រសិនបើបុរស ឬស្ត្រីណាដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយ ហើយទៅរួមសេវនកិច្ចជាមួយស្ត្រី ឬបុរសផ្សេងទៀត។ មានន័យថាប្ដី ឬប្រពន្ធដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ហើយមិនទាន់មានការសម្រេចជាស្ថាពររបស់តុលាការពីការលែងលះ ឬប្ដីប្រពន្ធណាម្ខាងមិនទាន់ស្លាប់ហើយទៅរួមសេវនកិច្ចជាមួយអ្នកដទៃក្រៅពីប្ដី ឬប្រពន្ធរបស់ខ្លួនសហព័ទ្ធណាម្ខាងអាចធ្វើការដាក់ពាក្យបណ្ដឹងស្នើសុំឱ្យចោទប្រកាន់បាន។

អំពើផិតនេះ ក្រៅពីជាមូលហេតុដែលនាំឱ្យសហព័ទ្ធអាចសុំរំលាយចំណងអាពាហ៍ពិពាហ៍ ដូចដែលមានចែងក្នុងក្រមរដ្ឋប្បវេណីនោះ ភាគីដែលបានប្រព្រឹត្តអំពើផិតនោះក៏ត្រូវចោទប្រកាន់ពីបទព្រហ្មទណ្ឌផងដែរ ប្រសិនបើសហព័ទ្ធម្ខាងទៀតបានប្ដឹងដោយត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ខែដល់ ១ឆ្នាំ និងផ្ដន្ទាទោសពិន័យជាប្រាក់ពី ២០០ ០០០រៀល ដល់ ១ ០០០ ០០០ រៀល ឬផ្ដន្ទាទោសណាមួយនៃទោសទាំងពីរ។[៧] **ឧទាហរណ៍** បុរសជាប្ដីបានលួចចិញ្ចឹមស្រីកំណាន់ចិត្ត។

### ១.២.១.២. ការបោះបង់ចោលសហព័ទ្ធដោយគ្មានមូលហេតុត្រឹមត្រូវ

នៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជាការបោះបង់ចោលសហព័ទ្ធដោយគ្មានមូលហេតុត្រឹមត្រូវ[៨] ឬការចុះចោលសហព័ទ្ធមួយដោយសហព័ទ្ធមួយទៀតដោយឥតមូលហេតុ ឥតមានការផ្គត់ផ្គង់ស្បៀងអាហារ និងទំនុកបម្រុងកូនសោះ។ ក្រមរដ្ឋប្បវេណីកម្ពុជាមិនបានផ្ដល់និយមន័យដល់ពាក្យ «ចុះចោលលំនៅដោយគ្មានមូលហេតុ» ទេ។ ប៉ុន្តែនៅក្រោមច្បាប់មួយចំនួនទៀត ការចុះចោលសហព័ទ្ធដោយចេតនាក្នុងរយៈពេលមួយយ៉ាងយូរដោយមានបំណងបញ្ចប់នូវចំណងអាពាហ៍ពិពាហ៍ និងដោយគ្មានការយល់ព្រមពីសហព័ទ្ធដែលត្រូវបានបោះបង់នោះ ឬដោយគ្មានហេតុផលសំអាង។ ដូច្នេះ គឺមានមូលហេតុសំខាន់ៗ ៤យ៉ាងការចុះចោលលំនៅសង្វាសៈ

- ការរស់នៅបែកគ្នាដោយចេតនាពីសហព័ទ្ធណាមួយ។
- មានចេតនាមិនចង់ដំណើរការចំណងអាពាហ៍ពិពាហ៍ឡើងវិញ។
- ខ្វះការយល់ព្រមពីសហព័ទ្ធដែលត្រូវបានខ្លួនចុះចោល។
- ខ្វះការហេតុផលសំអាងផ្សេងៗទៀតសម្រាប់ការរស់នៅ បែកគ្នា។

ក្រមរដ្ឋប្បវេណីកម្ពុជាមិនបានបញ្ជាក់ថា ការរស់នៅបែកគ្នាដោយចេតនាត្រូវមានរយៈពេលប៉ុន្មានទេ។ ជួនកាលមានការលំបាកនឹងកំណត់ថាស្វាមីដែលអវត្តមាននោះបានចុះចោលលំនៅឋានគ្រួសារ ឬគេបាន

[៦] ច្បាប់ស្ដីពី ឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦, មាត្រា៧។

[៧] ច្បាប់ស្ដីពី ឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦, មាត្រា១០។

[៨] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧,មាត្រា៩៧៨ វាក្យខណ្ឌ ខ។

ចាកចេញជាបណ្ដោះអាសន្នដើម្បីទៅរកប្រាក់មកផ្គត់ផ្គង់គ្រួសារ។ ក្រមរដ្ឋប្បវេណីបានដោះស្រាយសំណួរនេះ ដោយកំណត់និយមន័យការចុះចោលលំនៅសង្វាសជាការអវត្តមានពីគ្រួសារ «បើបានបោះបង់ចោលសហព័ទ្ធដោយគ្មានមូលហេតុត្រឹមត្រូវ»។ ប៉ុន្តែនៅក្នុងច្បាប់ស្ដីពី អាពាហ៍ពិពាហ៍ និងគ្រួសារបានចែង និងមានលក្ខណច្បាស់ជាងក្រមរដ្ឋប្បវេណីដោយចែងថា «ការចុះចោលលំនៅសង្វាសដោយឥតមូលហេតុត្រឹមត្រូវហើយឥតមានផ្គត់ផ្គង់ស្បៀងអាហារ និងទំនុកបម្រុងកូនសោះ»។

ការចុះចោលលំនៅសង្វាសពុំមែនជារឿងដដែលដូចប្ដីប្រពន្ធដែលគ្រាន់តែរស់នៅបែកគ្នាក្នុងរយៈពេលជាងមួយឆ្នាំប៉ុណ្ណោះទេ ហើយការនេះប្ដីប្រពន្ធអាចព្រមព្រៀងគ្នាក្នុងការរស់នៅបែកគ្នា។ ប៉ុន្តែការចុះចោលលំនៅសង្វាស គឺមានន័យថាសហព័ទ្ធម្នាក់ចុះចោលលំនៅសង្វាសដែលផ្ទុយគ្នានឹងសេចក្ដីប្រាថ្នារបស់សហព័ទ្ធម្នាក់ទៀត។

**ឧទាហរណ៍** ក្រោយពីបានរៀបអាពាហ៍ពិពាហ៍រួចហើយ បុរសជាប្ដីបានចុះចោលលំនៅឋានទៅរស់នៅជាមួយឪពុកម្ដាយរបស់គាត់វិញ ដោយមិនមានមូលហេតុត្រឹមត្រូវច្បាស់លាស់។ នៅក្នុងករណីបែបនេះ នារីជាប្រពន្ធអាចដាក់ពាក្យសុំលែងលះទៅតុលាការបាន។

### ១.២.១.៣. ការបាត់ដំណឹងរបស់សហព័ទ្ធអស់រយៈពេលជាង ១(មួយ)ឆ្នាំ ដោយមិនដឹងថាសហព័ទ្ធស្លាប់ ឬរស់

ក្នុងករណីដែលសហព័ទ្ធណាមួយបានបាត់ខ្លួនហួសពីរយៈពេល១ឆ្នាំ ដោយគ្មានដំណឹងទាល់តែសោះថានៅរស់ ឬស្លាប់។[៩] ភាគីដែលនៅរស់អាចស្នើសុំទៅតុលាការ ដើម្បីរំលាយចំណងអាពាហ៍ពិពាហ៍ចាស់នោះចោល។

មាត្រានេះច្បាប់ទុកលទ្ធភាពឱ្យភាគីម្ខាងទៀតដែលនៅរស់ជាងមិនចាំបាច់ត្រូវចំណាយពេលវេលារង់ចាំដោយក្ដីអស់សង្ឃឹម និងគ្មានផ្លូវសម្រាប់ដោះស្រាយនោះទេ គឺគេអាចប្ដឹងទៅតុលាការដើម្បីស្នើសុំរំលាយអាពាហ៍ពិពាហ៍ចាស់ចោល។ ប៉ុន្តែចៅក្រមត្រូវមានការប្រយ័ត្នប្រយែងក្នុងការសម្រេចតាមការស្នើសុំដោយត្រូវមានភស្តុតាង និងមានសាក្សីគ្រប់គ្រាន់ដើម្បីសម្រេចរឿងនេះដោយសារតែទម្លាប់ខ្លះ ឬមានករណីខ្លះប្ដីបានទៅរកស៊ីនៅឆ្ងាយ ឬចេញទៅក្រៅប្រទេសដើម្បីរកការងារធ្វើដូចជា ទៅធ្វើកម្មករនៅប្រទេសថៃ ឬទៅធ្វើជាកម្មករនេសាទនៅលើកប៉ាល់ថៃជាដើម ហើយមិនមានមធ្យោបាយសម្រាប់ការផ្ដល់ដំណឹងដល់ភរិយា ឬករណីខ្លះភរិយាមានដៃគូស្នេហាផ្សេងទៀត រកលេសដើម្បីលែងលះប្ដីដែលទៅបាត់រយៈពេលយូរ។

[៩] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧,មាត្រា៩៧៨ វាក្យខណ្ឌ គ។

**ឧទាហរណ៍** ក្រោយពីបានរៀបអាពាហ៍ពិពាហ៍រួចហើយ លោក **ក** បានចាកចេញពីប្រទេសកម្ពុជាទៅធ្វើការនៅបរទេស ក៏ប៉ុន្តែចាប់តាំងពីពេលដែលគាត់ចាកចេញទៅ គឺមិនអាចទាក់ទងលោក **ក** បានទេ ហើយពុំមានដំណឹងពីលោក **ក** ថានៅរស់ ឬក៏ស្លាប់ដោយសារមូលហេតុអ្វីមួយដែរ។ ដូច្នេះ ប្រសិនបើបាត់ដំណឹងនេះលើសពី១ឆ្នាំ ភរិយារបស់លោក **ក** អាចដាក់ពាក្យបណ្តឹងទៅតុលាការបាន។

### ១. ២. ១. ៤. ការរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង ១ (មួយឆ្នាំ)

ចំពោះការរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលលើសពីមួយឆ្នាំ ដែលផ្ទុយពីគោលបំណងនៃការរៀបអាពាហ៍ពិពាហ៍។[១០] នៅត្រង់ចំណុចនេះស្រដៀងគ្នាទៅនឹងច្បាប់នៃប្រទេសដទៃទៀតដែលទទួលស្គាល់«ការរស់នៅបែកគ្នារៀងៗខ្លួនពីគ្នា» គឺជាមូលហេតុនៃការលែងលះគ្នា។ បើប្តីប្រពន្ធបានរស់នៅបែកគ្នារៀងៗខ្លួនពីគ្នាអស់រយៈពេលជាង១ឆ្នាំ ភាគីមួយអាចប្តឹងលែងលះគ្នាបាន។ ជាទូទៅនៅពេលវេលាដែលបែកគ្នានោះត្រូវតែជាប់គ្នារហូត។ បើសិនភាគីទាំងនោះបាននៅបែកគ្នាហើយត្រឡប់មកនៅជាមួយគ្នាវិញហើយបែកគ្នាទៅវិញម្តងទៀតហើយធ្វើដូច្នេះរហូតដល់ពេលវេលាដែលគេនៅបែកគ្នានោះមានចំនួនឡើងដល់មួយឆ្នាំ នោះមូលហេតុដែលភាគីស្នើសុំសម្រាប់ការលែងលះគ្នានេះ គឺមិនមែនជាមូលហេតុដែលមានកំហុសសម្រាប់សម្រេចឱ្យមានការលែងលះគ្នាបានទេ។ មានសារៈសំខាន់ណាស់ក្នុងការបែងចែករវាងមូលហេតុនៃការលែងលះគ្នាដោយសារ«ការរស់នៅបែកគ្នាជាបន្តបន្ទាប់នេះ» និង«មូលហេតុការចុះចោលលំនៅឋាន»។ ការរស់នៅបែកគ្នាដោយឡែកពីគ្នារយៈពេល១ឆ្នាំ អាចសន្និដ្ឋានបានថា ភាគីទាំងសងខាងបានព្រមព្រៀងគ្នាដើម្បីរស់នៅបែកគ្នា ឬក៏យ៉ាងហោចណាស់ភាគីមួយចង់រស់នៅបែកគ្នាហើយភាគីម្ខាងទៀតយល់ព្រម។ ក៏ប៉ុន្តែក្រមរដ្ឋប្បវេណីកម្ពុជាមិនបានបញ្ជាក់ច្បាស់ថាតើការរស់នៅបែកគ្នានោះធ្វើដោយមានការព្រមព្រៀងគ្នាទៅវិញទៅមក និងដោយស្ម័គ្រចិត្តនោះទេ។

**ឧទាហរណ៍** ក្រោយពីបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នារយៈពេល ២ឆ្នាំ លោក **ក** និងលោកស្រី **ខ** បានសម្រេចចិត្តរស់នៅបែកគ្នាដោយសារតែមានការអាក់អន់ចិត្តនឹងគ្នាបន្តិចបន្តួច។ ហេតុដូច្នេះ ប្រសិនបើអ្នកទាំងពីរនោះរស់នៅបែកគ្នាយ៉ាងដូច្នេះលើសពី ១ឆ្នាំ ភាគីម្ខាងអាចដាក់ពាក្យបណ្តឹងសុំលែងលះគ្នាទៅតុលាការបាន។

### ១.២.១.៥. ករណីទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់

ករណីដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ឬករណីផ្សេងទៀតដែលគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន៖ បញ្ញត្តិចំណុចនេះមានលក្ខណៈទូលាយ និយាយរួមទោះបីជាមូលហេតុទាំងឡាយ

[១០] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៧៨ វាក្យខណ្ឌ ឃ។

ដែលមិនចូលក្នុងចំណុចពី "**ក**" ដែលនិយាយអំពី "បើបានប្រព្រឹត្តអំពើផិតក្បត់ទៅលើសហព័ទ្ធ" ដល់ចំណុច "**ឃ**" ដែលនិយាយអំពី "បើសហព័ទ្ធបានរស់នៅជាបន្តបន្ទាប់អស់រយៈពេលជាង១ឆ្នាំ (មួយ)ឆ្នាំ ផ្ទុយនឹងគោលបំណងអាពាហ៍ពិពាហ៍" គឺស្ថានភាពទាំងនោះអាចនឹងត្រូវបានគេរាប់បញ្ចូលទៅក្នុងចំណុច "**ង**" ដែលនិយាយអំពី "ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន" នេះ។[១១] ក្នុងករណីដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយមិនអាចស្តារនូវទំនាក់ទំនងចំណងអាពាហ៍ពិពាហ៍នេះវិញបាន អាចមានមូលហេតុច្រើនយ៉ាងណាស់ដែលធ្វើឱ្យប្រេះឆាចំណងអាពាហ៍ពិពាហ៍នេះ។ ក្រមរដ្ឋប្បវេណីថ្មីបានផ្តល់សិទ្ធិ និងសេរីភាពមួយកម្រិតថែមទៀតដល់ស្វាមីភរិយា គឺការរស់នៅជាមួយគ្នាឈរលើគោលការណ៍ស្ម័គ្រចិត្តការស្រុះស្រួលគ្នាទៅវិញទៅមករវាងភាគីទាំងពីរ ក្នុងករណីដែលចំណងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយមិនអាចស្តារឡើងវិញបាន ហើយគេមិនអាចបង្ខិតបង្ខំមនុស្សឱ្យរស់នៅជាមួយគ្នាដោយទាំងមិនចុះសម្រុងគ្នា ដោយគ្មានផ្លូវសម្រាប់ដោះស្រាយបានឡើយ។

មូលហេតុនៃការបែកបាក់គ្នានៅក្នុងសង្គមគ្រួសារខ្មែរអាចមានច្រើនយ៉ាងដែលមានជាអាទិ៍៖

- អំពើហិង្សាក្នុងគ្រួសារ ដែលបានប្រព្រឹត្តលើប្តី ឬប្រពន្ធ ឬកូនក្នុងបន្ទុក ឬជនទាំងឡាយដែលរស់នៅក្រោមដំបូលផ្ទះ ឬនៅក្នុងបន្ទុក។
- ការមើលងាយមើលថោកពីសំណាក់សហព័ទ្ធម្ខាងទៅលើសហព័ទ្ធម្ខាងទៀត
- ការជៀតជ្រែកកិច្ចការផ្ទៃក្នុងគ្រួសារសំណាក់ឪពុកម្តាយញាតិមិត្ត ឬសមាជិកណាមួយទៀត ដែលធ្វើឱ្យគ្រួសារងាយនឹងបែកបាក់ ឬមិនចុះសម្រុងគ្នា។
- ការមិនចុះសម្រុងគ្នា កើតឡើងដោយមិនទុកចិត្តគ្នា ការប្រចណ្ឌគ្នាទៅវិញទៅមក។ ជួនកាលមានករណីជាច្រើនទៀតដែលភាគីមានទំនាស់គ្នា និងមិនចុះសម្រុងគ្នាហើយដែលភាគីមិនអាចផ្សះផ្សាទំនាស់រវាងពួកគេទាំងពីរនាក់បាន។

ច្បាប់នៅគ្រប់ផ្នែកទាំងអស់នៅពិភពលោកឥឡូវនេះកំពុងតែមានការផ្លាស់ប្តូរ ដើម្បីទទួលស្គាល់ថាអំពើហិង្សាប្រឆាំងនឹងស្ត្រីនៅក្នុងផ្ទះ (ការវាយដំប្រពន្ធ កូនក្នុងគ្រួសារ) គឺជាការខុសច្បាប់។ នៅប្រទេសកម្ពុជាច្បាប់ផ្សេងៗបានទទួលស្គាល់ថា អំពើហិង្សាក្នុងគ្រួសារ គឺជាការខុសច្បាប់ហើយត្រូវតែបញ្ឈប់។ ចំពោះនៅក្នុងរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាចែងនៅក្នុងមាត្រា៣៨ ចែងថា ច្បាប់ហាមប់រងមិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ។ មួយវិញទៀត ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះបានចែងថា អំពើហិង្សាក្នុងគ្រួសារទាំងឡាយណាដែលចូលជាបទល្មើសព្រហ្មទណ្ឌត្រូវ

[១១] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៧៨។

ផ្តន្ទាទោសដោយយោងតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។[១២] ក្រមព្រហ្មទណ្ឌថ្មី បានកំណត់អំពីអំពើហិង្សារួមមានការប៉ះពាល់ដល់ជីវិត ការប៉ះពាល់ដល់បូរណភាពរូបកាយ ការធ្វើទារុណកម្ម ឬការធ្វើអំពើឃោឃៅ ការឈ្លានពានខាងផ្លូវភេទជាដើម ជាបទល្មើសព្រហ្មទណ្ឌ ប៉ុន្តែច្បាប់មិនរាប់ថា ជាការប្រើអំពើហិង្សាទេនូវរាល់ការប្រៀនប្រដៅដោយផ្តល់ដំបូលន្មាន ឬធ្វើការដាស់តឿនក្រើនរំលឹក ឬចាត់វិធានការនានាសមស្រប ដើម្បីឱ្យសហព័ទ្ធ ឬកូន ឬអ្នកនៅក្នុងបន្ទុកដើរក្នុងផ្លូវល្អតាមលក្ខណរស់នៅថ្លៃថ្នូរ និងទំនៀមទម្លាប់ល្អរបស់ជាតិ។[១៣]

**ឧទាហរណ៍** នៅក្នុងករណីនេះអាចមានច្រើន ដោយរួមបញ្ចូលទាំងការប្រើប្រាស់អំពើហិង្សាទៅលើសហព័ទ្ធ(ហិង្សាផ្លូវកាយ ផ្លូវចិត្ត ជាដើម)ផងដែរ។ ជាករណីអញ្ញត្រកម្ម កថាខណ្ឌទី២ និងកថាខណ្ឌទី៣ នៃមាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ អនុញ្ញាតឱ្យតុលាការអាចច្រានចោលការទាមទារលែងលះ បើទោះបីជាមានមូលហេតុនៃការលែងលះ ដូចកំណត់ខាងលើក៏ដោយ។

### ១.២.២. មូលហេតុរារាំងនៃការលែងលះ

ជាគោលការណ៍ឱ្យតែមានមូលហេតុនៃការលែងលះ គឺតែងតែមានមូលហេតុរារាំងនៃការលែងលះផងដែរ។ ការលែងលះនេះអាចនិងមានផលប៉ះពាល់ដល់ចំណុច "**ង**" ដែលនិយាយអំពី "ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន" ធ្ងន់ធ្ងរដល់សហព័ទ្ធ និងកូនដូចនេះដើម្បីទប់ស្កាត់ការលែងលះតាមទំនើងចិត្តដែលជាផលប៉ះពាល់នោះ តុលាការអាចច្រានចោលការលែងលះ ដោយផ្អែកលើមាត្រា៩៧៨ កថាខណ្ឌទី២ និងទី៣នៃក្រមរដ្ឋប្បវេណី។

#### ១.២.២.១. ការលែងលះដែលប៉ះពាល់ដល់ការទ្រទ្រង់ជីវភាព ឬការឈឺចាប់របស់សហព័ទ្ធ ឬកូន

ទោះបីជាក្នុងករណីដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីយ៉ាងច្បាស់លាស់ក៏ដោយ ប្រសិនបើយល់ថាការលែងលះគ្នានោះនឹងបណ្តាលការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធ ឬកូនក្រលំបាកយ៉ាងខ្លាំង ឬបណ្តាលឱ្យមានការឈឺចាប់ ដែលពុំអាចទ្រាំទ្របានតុលាការអាចច្រានចោលការទាមទារលែងលះគ្នាដោយពិចារណាទៅលើស្ថានភាពទាំងឡាយបាន។[១៤]

---

[១២] ច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ, លេខ នស/រកម/១០០៥/០៣១, ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ ២០០៥, មាត្រា៣៥។

[១៣] ច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ, លេខ នស/រកម/១០០៥/០៣១, ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ ២០០៥, មាត្រា៨។

[១៤] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៧៨ កថាខណ្ឌទី២។

ដូចច្នេះ ប្រសិនបើជាចៅក្រមសម្រេចអនុញ្ញាតឱ្យមានការលែងលះគ្នាបាននោះ វានឹងប៉ះពាល់ដល់គ្រួសារទាំងមូលបើគ្រាន់តែពុំអាចទ្រទ្រង់ជីវភាពនោះគេចវេសពីកាតព្វកិច្ចក្នុងការខិតខំរកប្រាក់កម្រៃដើម្បីចិញ្ចឹមជីវិតរបស់សហព័ទ្ធម្ខាងទៀត និងកូនហើយទម្លាក់បន្ទុកទាំងនោះទៅកាន់គ្រួសារ និងប្រទេសជាតិ។

**ឧទាហរណ៍** លោក **ចំណាន** និងលោកស្រី **សុខា** បានរៀបការជាមួយគ្នានៅឆ្នាំ ២០១០។ នាពេលថ្មីនេះ លោកស្រី **សុខា** មានបញ្ហាផ្នែកសុខភាពហើយតែងតែរករឿងឈ្លោះប្រកែកជាមួយនឹងលោក **ចំណាន** ដែលរហូតដល់ពេលខ្លះ លោកស្រី **សុខា** បានជេរបញ្ចោរលោក **ចំណាន** ទៀតផង។ បន្ទាប់មកលោក **ចំណាន** បានដាក់ពាក្យបណ្ដឹងសុំលែងលះទៅតុលាការ ហើយលោកស្រី **សុខា** បានបដិសេធយ៉ាងដាច់អហង្ការ មិនយល់ព្រមនឹងការលែងលះនេះទេ។ ស្ថិតក្នុងចំណងអាពាហ៍ពិពាហ៍ អ្នកទាំងពីរមានកូនពីរនាក់ ម្នាក់អាយុ ១ឆ្នាំ និងម្នាក់ទៀតទើបតែអាយុ ២ឆ្នាំ ប៉ុណ្ណោះ។ ជាពិសេសទៀត លោកស្រី **សុខា** មិនមានការងារធ្វើទេ ហើយនាងមានជម្ងឺផ្លូវចិត្តថែមទៀតផង ចំណែកឯទ្រព្យសម្បត្តិរួមវិញ ក៏ពុំមានច្រើនដែរ។ នៅក្នុងស្ថានភាពបែបនេះ តុលាការអាចនឹងយល់ឃើញថា ប្រសិនបើឱ្យលោក **ចំណាន** និងលោកស្រី **សុខា** លែងលះគ្នាប្រហែលជាធ្វើឱ្យលោកស្រី **សុខា** មិនអាចទ្រាំទ្រនឹងការឈឺចាប់ រួមផ្សំជាមួយនឹងស្ថានភាពសុខភាពនាងទន់ខ្សោយផងនោះ។ បើយ៉ាងដូច្នេះមែន តុលាការអាចសម្រេចចិត្តច្រានចោលការទាមទារលែងលះរបស់លោក **ចំណាន** បាន។ [១៥]

### ១.២.២.២. ការលែងលះដោយមានគំនិតទុច្ចរិត

ទោះបីជាមូលហេតុនៃការលែងលះ ដូចបានកំណត់នៅក្នុងចំណុចខាងលើនេះ ការរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង ១ ឆ្នាំ ដែលមានការផ្ទុយពីគោលបំណងអាពាហ៍ពិពាហ៍ ឬមានករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបានក៏ដោយ ប្រសិនបើតុលាការយល់ឃើញថាការទាមទារនោះផ្ទុយសុច្ចរិតភាព ដោយជនដែលទាមទារឱ្យលែងលះគ្នាធ្វេសប្រហែសយ៉ាងខ្លាំង ក្នុងសហប្រតិបត្តិការជួយសង្គ្រោះចំពោះសហព័ទ្ធតុលាការអាចច្រានចោលការទាមទារលែងលះគ្នាដោយឆន្ទានុសិទ្ធិបាន។[១៦] ការកំណត់បែបនេះពិតជាត្រឹមត្រូវ ព្រោះវាបានបង្ហាញពីភាពល្អិតល្អន់របស់ច្បាប់ ក្នុងគោលបំណងការពារកុំឱ្យមានជនខិលខូចមួយចំនួនអាចលើកយកនូវបញ្ហានេះ ឬបញ្ហានោះ ដើម្បីទាមទារឱ្យបាននូវការលែងលះ ដើម្បីតែសម្រេចបាននូវផលប្រយោជន៍របស់ខ្លួន ពោលគឺគំនិតអាត្មានិយមរបស់បុគ្គលទាំងអស់នោះ។

[១៥] សៀវភៅជំនួយស្មារតី នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ, បោះពុម្ពលើកទី២ ឆ្នាំ២០២២, ទំព័រទី៣៧៩ ដល់ទំព័រទី៣៨០។

[១៦] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៧៨ កថាខណ្ឌទី៣។

ក្រៅពីមូលហេតុនៃការលែងលះ និងមូលហេតុបដិសេធចំពោះការលែងលះ ដូចបានលើកឡើងខាងលើ ដើម្បីឱ្យមានការលែងលះមួយស្របច្បាប់ គឺទាមទារនូវការប្រតិបត្តិរបស់សហព័ទ្ធនីមួយៗ ចំពោះការអនុវត្តច្បាប់ជាធរមាន។ ដូចនេះគូវិវាទគួរគប្បីយល់ពីនីតិវិធីក្នុងការលែងលះគ្នាផងដែរ ទើបអាចឱ្យមានការជឿទុកចិត្តច្បាស់អំពីអានុភាពនៃសាលក្រមលែងលះ ដោយមិនចាំបាច់ភ័យខ្លាចក្រែងរាល់ទង្វើរបស់ភាគីម្ខាងទៀតនោះទេ ព្រោះថាកាលណាដើរតាមនីតិវិធីច្បាប់ គឺច្បាប់នឹងការពារជនសុច្ចរិតជាក់ជាមិនខាន។

**ឧទាហរណ៍** លោកស្រី ***ភារី*** និងលោក **កុរុណា** បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានៅឆ្នាំ២០០០ ហើយមានកូនជាមួយគ្នាចំនួនពីរនាក់។ លុះដល់ ឆ្នាំ២០០៥ ដោយសារតែការអាក់អន់ស្រពន់ចិត្តនឹងគ្នាបន្តិចបន្តួច លោក **កុរុណា** បានដាក់ពាក្យបណ្ដឹងសុំលែងលះពីលោកស្រី ***ភារី*** ប៉ុន្តែលោកស្រី ***ភារី*** មិនយល់ព្រមលែងលះពីលោក **កុរុណា** ឡើយ។ ក្នុងករណីបែបនេះ លោកស្រី ***ភារី*** និងលោក **កុរុណា** បានរស់នៅបែកគ្នាអស់រយៈពេល ៨ (ប្រាំបី)ឆ្នាំ ក៏ពិតមែនតែតុលាការយល់ឃើញថាមានមូលហេតុដូចមានចែងក្នុងកថាខណ្ឌទី២ ឬកថាខណ្ឌទី៣ នៃមាត្រា ៩៧៨ ខាងលើឧទាហរណ៍ដូចជាលោកស្រី ***ភារី*** មិនមានការងារធ្វើ ហើយចំណែកឯកូនទាំងពីររបស់នាងនៅជាអនីតិជននៅឡើយ ចំណែកឯទ្រព្យសម្បត្តិទៀតសោត ក៏មិនសូវមានច្រើនដែលមិនអាចឱ្យលោកស្រី ***ភារី*** ផ្គត់ផ្គង់ជីវភាពក្នុងគ្រួសារបាន នៅក្រោយពេលដែលលែងលះហើយ ជាដើម។[១៧]

## ១.៣. ប្រភេទនៃការលែងលះ

នៅក្នុងចំណុចនេះដែរ ប្រភេទនៃការលែងលះនេះគេបានធ្វើការបែងចែកចេញជាពីរនោះ គឺការលែងលះដោយមានការព្រមព្រៀង និងការលែងលះដោយគ្មានការព្រមព្រៀង។

### ១.៣.១. ការលែងលះដោយមានការព្រមព្រៀង

ការលែងលះដោយការព្រមព្រៀង គឺជាការរំលាយនូវចំណងអាពាហ៍ពិពាហ៍ស្របច្បាប់រវាងសហព័ទ្ធនៅរស់ដែលការព្រមព្រៀងនេះកើតចេញពីឆន្ទៈពិតប្រាកដរបស់សហព័ទ្ធទាំងពីរ។[១៨] ការលែងលះដោយមានការព្រមព្រៀងនេះអាចប្រព្រឹត្តទៅបាន គឺនៅពេលដែលសហព័ទ្ធទាំងពីរមានឆន្ទៈស្របគ្នានៅក្នុងការព្រមព្រៀងលែងលះ ហើយថែមទាំងបានព្រមព្រៀងគ្នារួចជាស្រេចក្នុងការកំណត់អំពីការបែងចែកទ្រព្យសម្បត្តិក្រោយការលែងលះ ឬការព្រមព្រៀងលើការកំណត់ពីអំណាចមេបា ឬអាហារកាតព្វកិច្ចជាដើម។ បន្ថែមឱ្យកាន់តែច្បាស់ទៅលើចំណុចនេះ គឺចង់សំដៅថា ករណីដែលសហព័ទ្ធ មានការព្រមព្រៀងលែងលះគ្នា ដោយការឯកភាពនេះ

[១៧] សៀវភៅជំនួយស្មារតី នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ, បោះពុម្ពលើកទី២ ឆ្នាំ២០២២, ទំព័រទី៣៨០ ដល់ទំព័រទី៣៨១។

[១៨] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៧៩។

មានត្រឹមតែការព្រមព្រៀងផ្តាច់នូវចំណងអាពាហ៍ពិពាហ៍ ក៏ប៉ុន្តែភាគីពុំមានការព្រមព្រៀងគ្នាទៅលើការបែងចែកសិទ្ធិ និងកាតព្វកិច្ចផ្សេងៗក្រោយការលែងលះនោះតាមរយៈស្មារតីនៃច្បាប់រដ្ឋប្បវេណីមិនកំណត់ថាចូលជាការលែងលះដោយព្រមព្រៀងឡើយ។ ការលែងលះដោយមានការព្រមព្រៀងអាចប្រព្រឹត្តទៅបានលុះត្រាតែភាគីបានព្រមព្រៀងគ្នារួចជាស្រេចលើសិទ្ធិ និងកាតព្វកិច្ចដោយពុំមានវិវាទរវាងគ្នានិងគ្នាហើយសកម្មភាពនេះកើតឡើងដោយឆន្ទៈផ្ទាល់ និងពិតប្រាកដរបស់ភាគី។ ជាទូទៅនៅក្នុងសង្គមជាក់ស្តែងសហព័ទ្ធដែលសម្រេចចិត្តក្នុងការលែងលះដោយព្រមព្រៀង តែងតែធ្វើនូវកិច្ចសន្យាព្រមព្រៀងលែងលះដែលមានកំណត់យ៉ាងច្បាស់អំពីការព្រមព្រៀងក្នុងការបែងចែកសិទ្ធិ និងកាតព្វកិច្ចផ្សេងៗរវាងភាគីទាំងពីរដោយភ្ជាប់មកជាមួយឯកសារពាក់ព័ន្ធផ្សេងៗនៅពេលដែលភាគីដាក់ពាក្យសុំលែងលះមកកាន់តុលាការ។

### ១.៣.២. ការលែងលះដោយគ្មានការព្រមព្រៀង

ការលែងលះដោយគ្មានការព្រមព្រៀង គឺជាការទាមទារឱ្យបញ្ចប់ចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ដោយសាលាក្រមរបស់តុលាការតាមរយៈការដាក់ពាក្យបណ្តឹងដោយភាគី។ នៅក្នុងការលែងលះដោយគ្មានការព្រមព្រៀងនេះកើតឡើងភាគច្រើនដោយសារតែភាគីលែងលះមិនចុះសម្រុងគ្នារហូតឈានដល់ការសម្រេចចិត្តចែកផ្លូវគ្នាទាំងជម្លោះ។ ការបែកបាក់នេះ មិនមែនបញ្ចប់ដោយសន្តិវិធីនោះទេ ពោលគឺភាគីអាចមានមូលហេតុជាច្រើនដែលនាំឱ្យមានការខ្វែងគំនិតគ្នា ឆន្ទៈផ្ទុយគ្នាបណ្តាលឱ្យមានការប្តឹងលែងលះគ្នា។ នៅក្នុងករណីដែលពុំមានមូលហេតុដូចបានកំណត់នៅក្នុងច្បាប់ពាក់ព័ន្ធនឹងមូលហេតុនៃការលែងលះទេនោះ តុលាការក៏មិនអាចសម្រេចឱ្យមានការលែងលះគ្នាបានដែរ។ ការលែងលះតាមរយៈការដាក់ពាក្យបណ្តឹងនេះ ភាគីដែលទាមទារឱ្យលែងលះត្រូវទទួលបន្ទុកបញ្ជាក់នូវអង្គហេតុនីមួយៗ ដែលជាមូលហេតុនៃការលែងលះដើម្បីឱ្យតុលាការសម្រេចឱ្យលែងលះ។ គួរបញ្ជាក់ផងដែរថាការលែងលះដោយគ្មានការព្រមព្រៀងនេះ កើតឡើងក្នុងស្ថានភាពវិវាទដូចជាភាគីណាមួយទាមទារលែងលះតែភាគីម្ខាងទៀតមិនយល់ព្រម ឬបញ្ហាមិនព្រមព្រៀងទៅលើការបែងចែកទ្រព្យ និងអំណាចមេបាលើកូនៗ។

# ជំពូកទី២

# ការលែងលះ

# ដោយមានការព្រមព្រៀង

# ជំពូកទី២

# ការលែងលះដោយមានការព្រមព្រៀង

ការលែងលះដោយមានការព្រមព្រៀង គឺជាការរំលាយទំនាក់ទំនងនៃចំណងអាពាហ៍ពិពាហ៍ដោយមានការព្រមព្រៀងគ្នា ពីភាគីទាំងសងខាងនៃចំណងអាពាហ៍ពិពាហ៍នោះ ប៉ុន្តែតុលាការអាចឱ្យលែងលះគ្នាបាន ក្រោយពីបានយល់ឃើញថាភាគីទាំងសងខាងមានបំណងក្នុងការលែងលះពិតប្រាកដមែននោះ នៅក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍នេះ។[១៩] ពោលគឺសហព័ទ្ធទាំងពីរមានការព្រមព្រៀងគ្នាកាត់ផ្តាច់ចំណងអាពាហ៍ពិពាហ៍របស់ខ្លួនដែលបានរៀបអាពាហ៍ពិពាហ៍ពេញលេញទៅតាមផ្លូវច្បាប់ សហព័ទ្ធទាំងពីរមានការព្រមព្រៀងគ្នា និងព្រមទាំងដកចេញនូវគំនិតក្នុងការអះអាងក្នុងការលែងលះដែលកំណត់យកភាគីទាំងសងខាងមកធ្វើជាមូលហេតុនៃការលែងលះវិញ។ ការលែងលះដោយការព្រមព្រៀង គឺជាការលែងលះដោយមានការដាក់ពាក្យស្នើសុំទៅតុលាការ។[២០] តុលាការសម្រេចសេចក្តីក្រោមរូបភាពជាដីកាសម្រេច។[២១]

## ២.១. នីតិវិធីនៃការលែងលះដោយមានការព្រមព្រៀង

នៅក្នុងនីតិវិធីនៃការលែងលះដោយមានការព្រមព្រៀងនេះមាននីតិវិធីដូចជា ការដាក់ពាក្យសុំ សមត្ថកិច្ចដោះស្រាយ និងការសម្រេចសេចក្តី។

### ២.១.១. ការដាក់ពាក្យសុំលែងលះ

ក្នុងការដាក់ពាក្យសុំលែងលះនេះ គេអាចធ្វើទៅបានតាមរបៀប ២យ៉ាង គឺការដាក់ពាក្យសុំលែងលះជាលាយលក្ខណ៍អក្សរ និងការដាក់ពាក្យសុំលែងលះដោយផ្ទាល់មាត់។[២២]

#### ២.១.១.១. ការដាក់ពាក្យសុំលែងលះដោយលាយលក្ខណ៍អក្សរ

ការដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរនេះ គូភាគីត្រូវសរសរពាក្យសុំនោះនូវចំណុចដូចដែលបានរៀបរាប់ខាងលើ ដែលមានបញ្ញត្តិនៅក្នុងមាត្រា២៦ កថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃច្បាប់ស្តីពី នីតិវិធីនៃ

[១៩] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៧៩។

[២០] ច្បាប់ស្តីពី នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០, តារាងឧបសម្ព័ន្ធ ផ្នែក ៤ ចំណុចទី៥។

[២១] ច្បាប់ស្តីពី នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០, មាត្រា៣។

[២២] ច្បាប់ស្តីពី នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០, មាត្រា២៦ កថាខណ្ឌទី១។

រឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ២០១០។[២៣] នៅក្នុងពាក្យសុំគូភាគីត្រូវសរសេរចំណុចដែលច្បាប់បានកំណត់ដូចខាងក្រោមនេះ៖

- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់៖[២៤] ប្តី ឬប្រពន្ធ ដែលយកពាក្យសុំមកដាក់ត្រូវសរសេរឈ្មោះ ភេទ អាយុ សញ្ជាតិនិងត្រូវបានសរសេរអាសយដ្ឋាននៅក្នុងពាក្យសុំ។ ប៉ុន្តែប្រសិនបើមានអ្នកតំណាងដោយអាណត្តិ ដែលច្បាប់បានកំណត់ត្រូវសរសេរឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដោយអាណត្តិនោះនៅក្នុងពាក្យសុំផងដែរ។ ភាគី គឺជាចំណុចមួយដែលទាមទារឱ្យមានការបញ្ជាក់ច្បាស់លាស់ ហើយភាគីជាអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀតនៃពាក្យសុំ ដូច្នេះការកំណត់ឱ្យបាននូវឈ្មោះរបស់ភាគី អាចបញ្ចៀសបាននូវការភាន់ច្រឡំទៅលើបុគ្គលផ្សេងទៀតដែលគ្មានការពាក់ព័ន្ធជាមួយពាក្យសុំ។ ដើម្បីជៀសវាងកុំឱ្យមានការភាន់ច្រឡំ ប្រសិនបើជារូបវន្តបុគ្គលត្រូវ សរសេរឈ្មោះជននោះ ព្រមទាំងអាសយដ្ឋាន ហើយបើជានីតិបុគ្គលត្រូវសរសេរនាមករណ៍ និងទីតាំងដែលជាទីស្នាក់ការ ឬទីកន្លែងអាជីវកម្មជាចម្បងនៅក្នុងពាក្យសុំនោះ។ មូលហេតុដែលចាំបាច់សរសេរបញ្ជាក់ឱ្យបានច្បាស់លាស់ ដោយសារតែតាមរយៈការសរសេរបញ្ជាក់នៅក្នុងលិខិតពាក្យសុំ អាចកំណត់បានច្បាស់លាស់ថាតើជនណាជាភាគីអ្នកដាក់ពាក្យសុំ ឬជាភាគីម្ខាងទៀតនៃពាក្យសុំងាយស្រួលសម្រាប់ធ្វើការបញ្ជូនក្នុងការធ្វើពាក្យសុំ និងឯកសារផ្សេងៗទៀត ហើយជាពិសេស គឺអានុភាពនៃដីកាសម្រេចដែលចេញដោយតុលាការនឹងមានទៅលើអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត ហើយចងភាគីទាំងពីរនោះ។
- ខ្លឹមសារនៃដីកាសម្រេច ឬសកម្មភាពផ្សេងទៀតរបស់តុលាការដែលអ្នកពាក្យដាក់សុំទាមទារ៖ ដែលជាកម្មវត្ថុនៃការវិនិច្ឆ័យ និងការសម្រេចសេចក្តីក្នុងបណ្តឹងរដ្ឋប្បវេណី ហើយក៏ជាការកម្រិតព្រំដែននៃការសម្រេចសេចក្តីរបស់តុលាការផងដែរ ដែលការទាមទារឱ្យតុលាការចេញមានដូចជា ការបែងចែកទ្រព្យសម្បត្តិ ការបែងចែកកូន ការទទួលបន្ទុកសោហ៊ុយចាំបាច់ដើម្បីថែរក្សាកូន ការប្រាស្រ័យទាក់ទងកូនជាអាទិ៍។

[២៣] ច្បាប់ស្តីពី នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០, មាត្រា២៦ កថាខណ្ឌទី២ ។

[២៤] ច្បាប់ស្តីពី នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០, មាត្រា២៦ កថាខណ្ឌទី២ ចំណុច ក។

❖ អង្គហេតុដែលជាមូលហេតុនៃការទាមទារ គឺជាការសរសេរពីមូលដ្ឋានគតិយុត្តនៃការទាមទាររបស់ភាគី។ នៅក្នុងរឿងក្តីនៃការលែងលះដោយការព្រមព្រៀង មូលដ្ឋានគតិយុត្តនៃការទាមទារមានដូចជា ការលែងលះ ការចាត់ចែងចំពោះកូន ការចាត់ចែងចំពោះទ្រព្យសម្បត្តិ។ ការលែងលះ គឺជាអង្គហេតុមួយ ដែលអាចទាមទារឱ្យមានការលែងលះគ្នាបាន ពោលគឺអង្គហេតុនៃការកើតឡើងក្នុងចំណងអាពាហ៍ពិពាហ៍ ដែលបញ្ជាក់តាមសំបុត្រអាពាហ៍ពិពាហ៍ និងអង្គហេតុនៃការបង្ហាញឆន្ទៈព្រមព្រៀងលែងលះដូចជាកិច្ចព្រមព្រៀង ឬការអះអាងរបស់គូភាគី។ រីឯការចាត់ចែងចំពោះកូន គឺជាអង្គហេតុដែលគេអាចទាមទារឱ្យតុលាការចាត់ចែងចំពោះកូន ពោលគឺអង្គហេតុដែលបញ្ជាក់ថា ចំណងអាពាហ៍ពិពាហ៍របស់ភាគីមានចំណងដៃនោះ គឺបង្កើតបានកូន ដែលអាចបញ្ជាក់ដោយសំបុត្រកំណើតរបស់កូន។ លើសពីនេះទៀតការចាត់ចែងទ្រព្យសម្បត្តិ គឺជាអង្គហេតុដែលអាចទាមទារឱ្យមានការចាត់ចែងទ្រព្យសម្បត្តិ ពោលគឺអង្គហេតុដែលបញ្ជាក់ពីការមានទ្រព្យសម្បត្តិរួមគ្នា ហើយចំពោះអង្គហេតុនេះអាចបញ្ជាក់ដោយឯកសារនានាដូចជា ប័ណ្ណសម្គាល់សិទ្ធិម្ចាស់អចលនវត្ថុ ឬលិខិតម្ចាស់យានយន្តជាអាទិ៍។[២៥]

### ២.១.១.២. ការដាក់ពាក្យសុំលែងលះដោយផ្ទាល់មាត់

បើយោងទៅតាមបញ្ញត្តិនៃមាត្រា២៦ កថាខណ្ឌទី១ និងកថាខណ្ឌទី៣ នៃច្បាប់ស្តីពី នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ២០១០ ពាក្យសុំអាចធ្វើឡើងដោយផ្ទាល់មាត់បានផងដែរ ហើយដើម្បីដាក់ពាក្យសុំដោយផ្ទាល់មាត់ អ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្តីថ្លែងការណ៍នូវចំណុចនីមួយៗ ដែលមានកំណត់នៅក្នុងកថាខណ្ឌទី២ នៅមុខក្រឡាបញ្ជី ចំពោះករណីនេះក្រឡាបញ្ជីនឹងត្រូវធ្វើនូវកំណត់ហេតុ ព្រមទាំងចុះហត្ថលេខា ហើយកំណត់ហេតុនោះត្រូវបានចាត់ទុកជាលិខិតពាក្យសុំ។ ម្យ៉ាងវិញទៀត នៅក្នុងករណីដែលមានឯកសារជាភស្តុតាង អ្នកដាក់ពាក្យសុំត្រូវភ្ជាប់នូវឯកសារដើម ឬឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ជាមួយនឹងលិខិតនៃពាក្យសុំ ឬត្រូវដាក់ជូនឯកសារទាំងនោះទៅតុលាការនៅពេលដាក់ពាក្យសុំ។[២៦]

ជាការអនុវត្តជាក់ស្តែងជួនកាលនៅពេលដាក់ពាក្យសុំ ភាគីអ្នកដាក់ពាក្យសុំ ឬភាគីម្ខាងទៀតក៏បានរៀបចំកិច្ចព្រមព្រៀងលែងលះ ឬកិច្ចសន្យាលែងលះគ្នាជាមុនភ្ជាប់មកជាមួយពេលដាក់ពាក្យសុំផងដែរ។ ជាមួយគ្នានេះដែរ កិច្ចព្រមព្រៀងលែងលះ គឺជាលិខិតមួយដែលបញ្ជាក់អំពីឆន្ទៈរបស់សហព័ទ្ធទាំងសងខាង

[២៥] ច្បាប់ស្តីពី នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០, មាត្រា២៦ កថាខណ្ឌទី២ ចំណុច ខ។

[២៦] ច្បាប់ស្តីពី នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០, មាត្រា២៦ កថាខណ្ឌទី៤។

ថាខ្លួនពិតជាមានបំណងពិតប្រាកដនៅក្នុងការផ្តាច់ចំណងអាពាហ៍ពិពាហ៍ ដោយមិនមានការបង្ខិតបង្ខំពីសំណាក់ភាគីណាម្ខាងនោះឡើយ។ ជាទូទៅ កិច្ចព្រមព្រៀងលែងលះភាគីច្រើនសរសេរបញ្ជាក់អំពីឆន្ទៈរបស់គូភាគី នៅក្នុងការព្រមព្រៀងលែងលះដូចជា ការបែងចែកសិទ្ធិអំណាចមេបាលើកូន ការកំណត់អំពីការជួបប្រាស្រ័យទាក់ទងកូន និងការបែងចែកទ្រព្យសម្បត្តិរួមជាអាទិ៍។ គួរបញ្ជាក់ផងដែរថា ចំណុចនេះពុំមែនជាល័ក្ខខ័ណ្ឌតម្រូវក្នុងការដាក់ពាក្យសុំនោះទេ ព្រោះថាតុលាការអាចធ្វើការកោះហៅគូភាគី ហើយដំណើរការនៃនីតិវិធីសាកសួរដើម្បីបញ្ជាក់ពីឆន្ទៈរបស់គូភាគីបាន។

### ២.១.២. សមត្ថកិច្ចដោះស្រាយ

នៅក្នុងការលែងលះដោយការព្រមព្រៀងភាគីដែលមានឆន្ទៈចង់ស្នើសុំលែងលះ ត្រូវទៅដាក់ពាក្យសុំពីអាជ្ញាធរដែលមានសមត្ថកិច្ចលើការដោះស្រាយរឿងក្តីលែងលះ។ សមត្ថកិច្ចដោះស្រាយនេះមានដូចជាពីរ គឺអាជ្ញាធរឃុំ-សង្កាត់ សាលាដំបូងរាជធានីខេត្តជាដើម។[២៧]

#### ២.១.២.១. អាជ្ញាធរឃុំ-សង្កាត់

ចំពោះការលែងលះដោយការព្រមព្រៀង ភាគីអាចដាក់ពាក្យសុំទៅតុលាការតែម្តង ឬដាក់ពាក្យសុំទៅសាលាឃុំ-សង្កាត់សិនក៏បាន។[២៨] ទោះបីជាយ៉ាងណាក៏ដោយអាជ្ញាធរថ្នាក់ឃុំ-សង្កាត់មិនមានសិទ្ធិអំណាចក្នុងការអនុញ្ញាតឱ្យប្តីប្រពន្ធលែងលះគ្នាបាននោះទេ ពោលគឺឃុំ-សង្កាត់មានសមត្ថកិច្ចត្រឹមតែការផ្សះផ្សាឱ្យសហព័ទ្ធទាំងសងខាងត្រូវរ៉ូវគ្នាវិញតែប៉ុណ្ណោះ  ចំណែកឯតុលាការជាអ្នកចេញដីកាសម្រេច។ ក្រុមប្រឹក្សាឃុំ-សង្កាត់អាចធ្វើការបញ្ចុះបញ្ចូលឱ្យសះជានឹងគ្នាបាននៅក្នុងអំឡុងពេល១៥ថ្ងៃ បន្ទាប់ពីទទួលបានពាក្យសុំ។ ហើយការផ្សះផ្សានៅថ្នាក់ឃុំ-សង្កាត់អាចទទួលបានលទ្ធផលពីរ គឺការផ្សះផ្សាបានសម្រេច និងការផ្សះផ្សាមិនបានសម្រេច។ ក្នុងករណីផ្សះផ្សាមិនបានសម្រេចនោះក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវបញ្ជូនពាក្យសុំលែងលះនោះទៅកន្លែងដែលមានសមត្ថកិច្ច។[២៩]

#### ២.១.២.២. សាលាដំបូងរាជធានី-ខេត្ត

សាលាជម្រះក្តីដែលមានសមត្ថកិច្ចលើរឿងក្តីលែងលះដោយការព្រមព្រៀង គឺតុលាការនៃលំនៅឋានប្តីឬប្រពន្ធ។[៣០] នៅក្នុងករណីដែលតុលាការមានសមត្ថកិច្ចមិនអាចអនុវត្តសិទ្ធិសម្រេចសេចក្តីបានដោយសារ

---

[២៧] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៨២។

[២៨] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៨២។

[២៩] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៨២ កថាខណ្ឌទី២។

[៣០] ច្បាប់ស្តីពី នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០, តារាងឧបសម្ព័ន្ធ ផ្នែកទី៤ កថាខណ្ឌទី៤ ចំណុចទី៥

ច្បាប់ ឬហេតុការណ៍ពិត ឬករណីដែលសមត្ថកិច្ចសាលាជម្រះក្ដីមិនពិតប្រាកដ នោះសមត្ថកិច្ចនៃតុលាការត្រូវកំណត់ ដោយតុលាការកំពូលដោយដីកាសម្រេចតាមពាក្យសុំ។[៣១] សេចក្ដីសម្រេចរបស់តុលាការកំពូល គឺជាសេចក្ដីសម្រេចបិទផ្លូវតវ៉ា។[៣២] ប្រសិនបើតុលាការដែលទទួលពាក្យសុំយល់ឃើញថា រឿងក្ដីនោះមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនទេ តុលាការនេះត្រូវផ្ទេររឿងក្ដីនេះទៅតុលាការដែលមានសមត្ថកិច្ចតាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិ។[៣៣] ពាក្យសុំនេះ គឺត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយមានបញ្ជាក់ពីមូលហេតុផងដែរ។ ក្នុងករណីដែលមានតុលាការច្រើនមានសមត្ថកិច្ចលើរឿងក្ដីណាមួយ តុលាការដែលទទួលពាក្យសុំមុនគេចំពោះរឿងក្ដីនោះត្រូវជាតុលាការដែលមានសមត្ថកិច្ច។[៣៤] លើសពីនេះទៀត សមត្ថកិច្ចតុលាការត្រូវកំណត់យកនៅពេលដាក់ពាក្យសុំ[៣៥] គឺមានន័យថាតុលាការដែលដាក់ពាក្យសុំ ជាតុលាការដែលមានសមត្ថកិច្ច ទោះបីជានៅពេលក្រោយ ភាគីបានប្ដូរលំនៅឋានក៏ដោយ តុលាការនៅពេលដាក់ពាក្យសុំនៅតែមានសមត្ថកិច្ចដដែល។

### ២.១.៣. នីតិវិធីដោយមានការព្រមព្រៀងនៅតុលាការ

នៅក្នុងនីតិវិធីដោយមានការព្រមព្រៀងទៅតុលាការនេះ គឺតុលាការធ្វើការពិនិត្យពាក្យសុំ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ការទាញហេតុផលដោយផ្ទាល់មាត់ និងការចេញដីកាសម្រេច។

#### ២.១.៣.១. ការពិនិត្យពាក្យសុំ

ពាក្យសុំលែងលះ ត្រូវដាក់នៅក្នុងការិយាល័យកិច្ចការរដ្ឋបាល និងបុគ្គលិកប្រចាំតុលាការ។ បន្ទាប់ពីទទួលពាក្យសុំ មន្ត្រីរដ្ឋបាលនឹងធ្វើការបញ្ជូនពាក្យសុំទៅកាន់ក្រឡាបញ្ជី ហើយក្រឡាបញ្ជី គឺត្រូវធ្វើការពិនិត្យហើយធ្វើការចុះលេខលើសំណុំរឿងដែលបានទទួលនោះ។ ក្នុងករណីដែលពិនិត្យឃើញថាពាក្យសុំនោះមិនត្រឹមត្រូវ តាមទម្រង់នៃច្បាប់ដែលបានកំណត់ទេនោះ គឺត្រូវរាយការណ៍ជូនចៅក្រមដើម្បីឱ្យចៅក្រមសម្រេចថាតើត្រូវបង្គាប់ឱ្យកែតម្រូវ ឬលើកពាក្យសុំចោល(ដីកាសម្រេច)។ ផ្ទុយមកវិញប្រសិនបើពិនិត្យឃើញថាពាក្យសុំនោះត្រឹមត្រូវតាមទម្រង់នៃច្បាប់បានកំណត់ហើយ ដូច្នេះក្រឡាបញ្ជីត្រូវបញ្ជូនពាក្យសុំនោះទៅចៅក្រម ដើម្បីសម្រេច បើកការជំនុំជម្រះ។ គួរបញ្ជាក់ផងដែរក្នុងការដាក់ពាក្យសុំ អ្នកដាក់ពាក្យសុំត្រូវបង់ពន្ធលើពាក្យសុំ

---

[៣១] ច្បាប់ស្ដីពី នីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០, មាត្រា៥ កថាខណ្ឌទី១។

[៣២] ច្បាប់ស្ដីពី នីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០, មាត្រា៥ កថាខណ្ឌទី២។

[៣៣] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា១៨ កថាខណ្ឌទី១។

[៣៤] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា១៨ កថាខណ្ឌទី២។

[៣៥] ច្បាប់ស្ដីពី នីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណី ដែលមិនមែនជាបណ្ដឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០, មាត្រា៤ កថាខណ្ឌទី២។

ចំនួន ៥.០០០ (ប្រាំពាន់) រៀល។[៣៦] ចំណែកឯប្រាក់ប្រដាប់ក្ដីក្រៅពីពន្ធ គឺជាបន្ទុករបស់អ្នកដាក់ពាក្យសុំ។[៣៧] ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ គឺជាប្រាក់ប្រដាប់ក្ដីតុលាការដែលភាគី ឬបុគ្គលដែលទាក់ទងនឹងរឿងក្ដីត្រូវបង់ជាមុន សម្រាប់ការចំណាយរបស់តុលាការដូចជា ការកំណត់ចាំបាច់សម្រាប់ការពិនិត្យភស្តុតាង ការបញ្ជូនឯកសារ សោហ៊ុយសម្រាប់ធ្វើដំណើរ ការស្នាក់នៅរបស់ចៅក្រម និងក្រឡាបញ្ជី នៅក្នុងការពិនិត្យភស្តុតាងស្រាវជ្រាវអង្គហេតុ សាកសួរភាគីដែលប្រព្រឹត្តនៅក្រៅតុលាការ។[៣៨] ចំពោះសកម្មភាពដែលត្រូវបង់ប្រាក់ប្រដាក់ក្ដីនេះ តុលាការនឹងធ្វើការបង្គាប់ឱ្យភាគីអ្នកដាក់ពាក្យសុំ ឬបុគ្គលដែលទាក់ទងនឹងរឿងក្ដីបង់ប្រាក់តាមចំនួនដែលតុលាការបានកំណត់នោះជាមុន។ ក្នុងករណីដែលតុលាការបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្ដីជាមុន ហើយសាមីខ្លួនមិនបានបង់ ជាមុននោះទេតុលាការនឹងលើកចោលពាក្យសុំដោយដីកាសម្រេច។

### ២.១.៣.២. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការទាញហេតុផលផ្ទាល់មាត់

នៅក្នុងនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ពុំមាននីតិវិធីត្រៀមសម្រាប់ទាញហេតុផលទេ ពីព្រោះនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹងនេះ មិនមែនជានីតិវិធីកំណត់អំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ពោលគឺមិនមែនជានីតិវិធីនៃការដោះស្រាយវិវាទអំពីសិទ្ធិ ឬជាទំនាក់ទំនងគតិយុត្តឡើយ។ នីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង គឺជានីតិវិធីដែលតុលាការធ្វើការចាត់ចែងនូវចំណុចចាំបាច់ដែលពាក់ព័ន្ធនឹងជីវភាពរបស់បុគ្គលឯកជន ឬចំណុចដែលមានភាពចាំបាច់សម្រាប់ផលប្រយោជន៍សាធារណៈ។[៣៩] នៅក្នុងនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង តុលាការអាចកំណត់ ឬមិនកំណត់អំពីកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ដោយឆន្ទានុសិទ្ធិ។[៤០] តុលាការអាចធ្វើការសួរអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬជនផ្សេងទៀតដែលតុលាការយល់ថាសមរម្យឱ្យចូល ស្ដាប់ជាអ្នកសង្កេតការណ៍បាន។[៤១]

[៣៦] ច្បាប់ស្ដីពី នីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០, មាត្រា២២ កថាខណ្ឌទី១។

[៣៧] ច្បាប់ស្ដីពី នីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណី ដែលមិនមែនជាបណ្ដឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០, មាត្រា២២ កថាខណ្ឌទី៣។

[៣៨] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៦២ កថាខណ្ឌទី១។

[៣៩] ច្បាប់ស្ដីពី នីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០, មាត្រា៣។

[៤០] ច្បាប់ស្ដីពី នីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០, មាត្រា២៨ កថាខណ្ឌទី១។

[៤១] ច្បាប់ស្ដីពី នីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០, មាត្រា២៨ កថាខណ្ឌទី២។

#### ២.១.៣.៣. ការចេញដីកាសម្រេចតុលាការ

តុលាការ ជាអ្នកចេញដីកាសម្រេចតាមពាក្យសុំ។ តុលាការអាចយកអង្គហេតុដែលមិនបានអះអាងដោយអ្នកដាក់ពាក្យសុំ ឬភាគីម្ខាងទៀតមកធ្វើជាមូលដ្ឋាននៃការសម្រេចសេចក្តីបាន និងក្នុងករណីចាំបាច់តុលាការនឹងស្រាវជ្រាវអង្គហេតុ និងធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ។[៤២] ការសម្រេចសេចក្តីត្រូវធ្វើដោយដីកាសម្រេច។ ដីកាសម្រេចនេះនឹងមានតម្លៃដូចគ្នាទៅនឹងសាលក្រមស្ថាពរដែរ។ គូភាគីអាចធ្វើការប្តឹងជំទាស់បាននៅក្នុងអំឡុងពេល ២(ពីរ)សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលទទួលបាននូវការជូនដំណឹងអំពីដីកាសម្រេច។[៤៣]

## ២.២. អានុភាពនៃការលែងលះដោយមានការព្រមព្រៀង

នៅពេលដែលដីកាសម្រេចចូលជាស្ថាពរអានុភាពនៃដីកាសម្រេចក៏កើតមាន ហើយអានុភាពដែលកើតមាននោះសម្រេចក្រោមរូបភាពឆ្លើយតបនឹងពាក្យសុំរបស់ភាគីដែលបានព្រមព្រៀងគ្នាលើគ្រប់ចំណុចនៅក្នុងការលែងលះដែលមានដូចតទៅ៖

### ២.២.១. ការផ្តាច់ទំនាក់ទំនងគតិយុត្ត

អានុភាពចម្បងដែលកើតចេញពីការលែងលះ គឺជាការផ្តាច់ទំនាក់ទំនងគតិយុត្តរវាងសហព័ទ្ធ។ ហើយការកាត់ផ្តាច់ទំនាក់ទំនងទាំងនោះរួមមាន ការកាត់ផ្តាច់ចំណងគតិយុត្តរវាងសហព័ទ្ធ និងការកាត់ផ្តាច់ទំនាក់ទំនងញាតិពន្ធ។

#### ២.២.១.១. ការផ្តាច់ទំនាក់ទំនងរវាងសហព័ទ្ធ

នៅពេលដែលបុរស និងស្ត្រីដែលពេញវ័យដល់នីតិភាព ហើយរៀបអាពាហ៍ពិពាហ៍ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នាដោយស្របច្បាប់ នោះពួកគេបានបង្កើតឡើងនូវចំណងគតិយុត្ត ដែលទទួលស្គាល់ដោយច្បាប់ថាពួកគេត្រូវជាសហព័ទ្ធនឹងគ្នាចាប់ពីពេលនោះតទៅ។[៤៤] នៅពេលដែលសហព័ទ្ធទាំងពីរបានលែងលះគ្នាហើយនោះអានុភាពនៃការលែងលះបានកាត់ផ្តាច់ចំណងគតិយុត្តរវាងសហព័ទ្ធចាប់ពីពេល

[៤២] ច្បាប់ស្តីពី នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០, មាត្រា២៧។

[៤៣] ច្បាប់ស្តីពី នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០, មាត្រា៤០ កថាខណ្ឌទី១។

[៤៤] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៣៨ កថាខណ្ឌទី២។

ដីកាសម្រេចលែងលះចូលជាស្ថាពរ។ ត្រង់ចំណុចនេះបានសេចក្ដីថា រវាងភាគីប្ដី និងប្រពន្ធមិនមានទំនាក់ទំនងគតិយុត្តដែលបានទទួលស្គាល់ដោយច្បាប់ទៀតឡើយ។

**២.២.១.២. ការផ្ដាច់ទំនាក់ទំនងខាងញាតិពន្ធ**

អានុភាពនៃការលែងលះនេះមិនមែនត្រឹមតែកាត់ផ្ដាច់ទំនាក់ទំនងរវាងសហព័ទ្ធនោះទេ ការលែងលះនេះថែមទាំងនាំឱ្យមានការកាត់ផ្ដាច់ដល់ទំនាក់ទំនងញាតិពន្ធផងដែរ។ ញាតិពន្ធ គឺសំដៅដល់សាច់ញាតិដែលមិនមានជាប់សាច់ឈាមនឹងបុគ្គលជាប្ដី ឬប្រពន្ធតែជាញាតិខាងសហព័ទ្ធរបស់បុគ្គលជាប្ដី ឬប្រពន្ធនោះ ដែលនិយាយតាមន័យសាមញ្ញ គឺញាតិសាច់ថ្លៃ។ នៅពេលដែលមានការរំលាយចំណងអាពាហ៍ពិពាហ៍ ដោយការលែងលះនោះ ទំនាក់ទំនងញាតិពន្ធក៏ត្រូវបានបញ្ចប់រវាងសហព័ទ្ធទាំងសងខាងផងដែរ។[៤៥] ត្រង់ចំណុចនេះអានុភាពនៃការរំលាយចំណងអាពាហ៍ពិពាហ៍ដោយការលែងលះ គឺមានភាពខុសគ្នាទៅនឹងការរំលាយចំណងអាពាហ៍ពិពាហ៍ ដោយសារមរណភាពរបស់សហព័ទ្ធណាម្ខាងដោយទំនាក់ទំនងញាតិពន្ធមិនបញ្ចប់នោះទេ លុះត្រាតែសហព័ទ្ធដែលនៅរស់រៀបអាពាហ៍ពិពាហ៍ថ្មី។[៤៦]

**២.២.២. សិទ្ធិ និងកាតព្វកិច្ចក្រោយការលែងលះ**

ការលែងលះ គឺជាការបញ្ចប់ទំនាក់ទំនងគតិយុត្តរវាងសហព័ទ្ធដែលនៅរស់។ បើទោះបីទំនាក់ទំនងគតិយុត្តនេះត្រូវបានបញ្ចប់ក៏ដោយក្ដី ប៉ុន្តែអានុភាពនៃការលែងលះបានបន្សល់ទុកនូវសិទ្ធិ និងកាតព្វកិច្ចដល់គូភាគីដដែល។

**២.២.២.១. សិទ្ធិបន្សល់ក្រោយការលែងលះ**

ទោះបីអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់ក៏ពិតមែន ក៏ប៉ុន្តែនៅក្រោយការលែងលះបានបន្សល់ទុកនូវសិទ្ធិមួយចំនួនចំពោះភាគី។ សិទ្ធិដែលបន្សល់ក្រោយការលែងលះមានដូចជា សិទ្ធិទទួលបានអត្តាធីនភាព សិទ្ធិក្នុងការប្រើប្រាស់នាមត្រកូល សិទ្ធិលើអំណាចមេបាសិទ្ធិលើទ្រព្យសម្បត្តិ និងព្រមទាំងសិទ្ធិក្នុងការបង្កើតអាពាហ៍ពិពាហ៍ថ្មី។

**ក. សិទ្ធិទទួលបានអត្តាធីនភាព**

ក្នុងករណីដែលអនីតិជនទទួលអត្តាធីនភាពដោយការរៀបអាពាហ៍ពិពាហ៍ ហើយបានលែងលះគ្នា អានុភាពនៃអត្តាធីនភាពនៅតែមានដដែល ពុំបានបញ្ចប់តាមអានុភាពដោយការលែងលះនោះទេ គឺមានន័យ

[៤៥] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៤១ កថាខណ្ឌទី១។
[៤៦] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៤១ កថាខណ្ឌទី២។

ថា បើទោះបីជាលែងលះក៏ដោយភាគីនៃចំណងអាពាហ៍ពិពាហ៍ដែលជាអនីតិជននៅតែមានសិទ្ធិទទួលបាននូវអត្តាធីនភាពដដែល។

**ខ. សិទ្ធិក្នុងការប្រើប្រាស់នាមត្រកូលរបស់សហព័ទ្ធ**

នៅក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍ គឺមានសហព័ទ្ធមួយចំនួនពួកគាត់ធ្វើការដែលប្រើប្រាស់នូវនាមត្រកូលរបស់សហព័ទ្ធម្ខាងទៀត។ ដោយឡែកការប្រើប្រាស់ត្រកូលរបស់ភាគីម្ខាងទៀត វាពុំជាបញ្ហាចោទនោះទេ ព្រោះថាបន្ទាប់ពីការលែងលះរបស់ភាគីរួចរាល់ហើយ ក៏សហព័ទ្ធនៅតែមានសិទ្ធិនៅក្នុងការប្រើប្រាស់នាមត្រកូលរបស់សហព័ទ្ធនោះដដែល ពោលគឺមិនចាំបាច់ប្តូរត្រកូលវិញនោះទេ។ នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា គឺបានផ្តល់ជម្រើសដល់ប្តី ឬប្រពន្ធដែលបានប្តូរនាមត្រកូលថ្មី ដោយអាពាហ៍ពិពាហ៍ អាចប្រើនាមត្រកូលដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍វិញក៏បាន ឬអាចប្រើនាមត្រកូលដែលបានប្រើនៅពេលលែងលះគ្នាក៏បាន។[៤៧]

**គ. សិទ្ធិលើអំណាចមេបា**

នៅពេលដែលលែងលះកូនដែលបានកើតក្នុងចំណងអាពាហ៍ពិពាហ៍ ដែលស្ថិតនៅក្នុងស្ថានភាព ជាអនីតិជននៅឡើយត្រូវកំណត់យកឪពុក ឬម្តាយណាម្ខាងជាអ្នកមានអំណាចមេបាតាមការពិភាក្សារបស់ឪពុកម្តាយ។ ក្នុងករណីដែលឪពុកម្តាយបានលែងលះគ្នា នៅមុនកំណើតកូន ម្តាយ គឺជាអ្នកមានអំណាចមេបាចំពោះកូនដែលបានកើតមកនោះ។ ប៉ុន្តែនៅក្រោយកំណើតរបស់កូនអាចកំណត់យកឪពុកជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយបាន។[៤៨] ទន្ទឹមនឹងនេះផងដែរ ចំពោះឪពុក ឬម្តាយដែលពុំទទួលបានអំណាចមេបាលើកូនតាមការសម្រេចរបស់តុលាការក្រោយការលែងលះក៏ឪពុក ឬម្តាយនោះនៅតែមានសិទ្ធិក្នុងការចូលជួបកូន និងប្រាស្រ័យទាក់ទងគ្នាជាមួយកូនដដែល។ ការចូលជួប និងការប្រាស្រ័យទាក់ទងជាមួយកូនៗតម្រូវឱ្យឪពុក និងម្តាយដែលបានលែងលះធ្វើការពិភាក្សាគ្នាលើការកំណត់វិធីនៃការណាត់ជួបកូនពីសំណាក់ភាគីដែលមិនមានអំណាចមេបា។[៤៩] ប៉ុន្តែប្រសិនបើការពិភាក្សាពុំបានលទ្ធផលសម្រេចទេនោះ តុលាការត្រូវសម្រេចអំពីចំណុចនេះ។[៥០] ដោយឡែកចំពោះការលែងលះដោយការព្រមព្រៀង គឺវាមានភាពងាយស្រួលក្នុងការសម្រេចអំពីអ្នកមានអំណាចមេបាលើកូន និងការប្រាស្រ័យទាក់ទងជាមួយកូនជាស្រេច។

[៤៧] ក្រមរដ្ឋប្បវេណី, លេខ នស/រកម១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៨១។
[៤៨] ក្រមរដ្ឋប្បវេណី, លេខ នស/រកម១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា១០៣៧ កថាខណ្ឌទី២។
[៤៩] ក្រមរដ្ឋប្បវេណី, លេខ នស/រកម១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា១០៤០ កថាខណ្ឌទី១។
[៥០] ក្រមរដ្ឋប្បវេណី, លេខ នស/រកម១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា១០៤០ កថាខណ្ឌទី៤។

**ឃ. សិទ្ធិលើទ្រព្យសម្បត្តិ**

សហព័ទ្ធដែលបានចាប់ដៃកសាងគ្រួសាររួមគ្នា តែងតែមាននូវទ្រព្យសម្បត្តិដែលខិតខំស្វែងរកជាមួយគ្នា នៅក្នុងអំឡុងពេលដែលមានចំណងអាពាហ៍ពិពាហ៍ ដូច្នេះហើយនៅពេលដែលមានការលែងលះ ប្រាកដណាស់ថា សហព័ទ្ធនឹងត្រូវធ្វើការបែងចែងនូវទ្រព្យសម្បត្តិទាំងនោះ។ អនុលោមតាមក្រមរដ្ឋប្បវេណី ប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធបានបែងចែកជាពីរប្រភេទ គឺប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា និងប្រព័ន្ធទ្រព្យសម្បត្តិកំណត់ដោយច្បាប់។ ប្ដីប្រពន្ធអាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិ នៅមុន ឬក្រោយអាពាហ៍ពិពាហ៍បាន។[៥១] នេះបានសេចក្ដីថាប្ដីប្រពន្ធ នៅមុន ឬក្រោយពេលរៀបអាពាហ៍ពាហ៍អាចបណ្ដើរគ្នាទៅចុះកិច្ចសន្យាទ្រព្យសម្បត្តិនៅក្រសួងយុត្តិធម៌ ដើម្បីងាយស្រួលសម្រាប់ប្ដីប្រពន្ធ នៅក្នុងគ្រួសារទៅថ្ងៃមុខទៀត។ ដូច្នេះ នៅពេលលែងលះ នោះនឹងមានការបែងចែកទ្រព្យសម្បត្តិ ជាហេតុនាំឱ្យចៅក្រមមិនពិបាកឡើយក្នុងការសម្រេចដោយអនុលោមទៅតាមការកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធនោះ។ ផ្ទុយមកវិញ ប្រសិនបើប្ដីប្រពន្ធនោះមិនបានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិ ប្ដីប្រពន្ធតាមកិច្ចសន្យាទេនោះ តុលាការអាចឱ្យភាគីប្ដីប្រពន្ធនោះ ពិភាក្សាគ្នាក្នុងការបែងចែកទ្រព្យបានដូចមានចែងនៅក្នុងកិច្ចសន្យា។ ដោយឡែកក្នុងការលែងលះដោយការព្រមព្រៀង គឺគូភាគីតែងតែធ្វើការពិភាក្សាក្នុងការបែងចែកទ្រព្យសម្បត្តិរួមជាស្រេច។ ចំពោះទ្រព្យដោយឡែកវិញ សហព័ទ្ធនីមួយៗមានសិទ្ធិទទួលយករៀងៗខ្លួន។

**ង. សិទ្ធិក្នុងការបង្កើតចំណងអាពាហ៍ពិពាហ៍ថ្មី**

អានុភាពនៃការលែងលះ បានផ្ដល់សិទ្ធិដល់ភាគីក្នុងការបង្កើតនូវចំណងអាពាហ៍ពិពាហ៍ថ្មីតាមឆន្ទៈរបស់ភាគី។ នៅក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ជាមួយគ្នា ភាគីត្រូវបានហាមឃាត់ដោយច្បាប់មិនឱ្យមានចំណងអាពាហ៍ពិពាហ៍បន្ថែមជាមួយនឹងបុគ្គលដទៃផ្សេងទៀតឡើយ។[៥២] នៅពេលមានដីកាសម្រេចលែងលះ ដែលបានចូលជាស្ថាពរ បានសេចក្ដីថាភាគីមានសិទ្ធិសេរីភាពឡើងវិញក្នុងការរៀបអាពាហ៍ពិពាហ៍ដោយស្របច្បាប់ម្ដងទៀត។ ទន្ទឹមនឹងនេះ រយៈពេលដែលភាគីខាងបុរសមានសិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍ថ្មី មិនត្រូវបានដាក់កំហិតដោយច្បាប់រដ្ឋប្បវេណីឡើយ។ ប៉ុន្តែចំពោះនារីវិញ ក្រមរដ្ឋប្បវេណី គឺត្រូវបានកំណត់អំពីរយៈពេលដែលនារីមានសិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ម្ដងទៀត។ បន្ទាប់ពីលែងលះ នារីត្រូវតែរង់ចាំរយៈពេល ១២០ (មួយរយម្ភៃ)ថ្ងៃ ទើបអាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន។ ការរៀបអាពាហ៍ពិពាហ៍ថ្មីនេះ ក៏អាចធ្វើឡើងបានមុនរយៈពេលកំណត់ ១២០ (មួយរយម្ភៃ)ថ្ងៃ កាលបើមានលិខិតបញ្ជាក់ពីគ្រូពេទ្យថានារីនោះ

[៥១] ក្រមរដ្ឋប្បវេណី, លេខ នស/រកម១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៦៩ កថាខណ្ឌទី១ វាក្យខណ្ឌទី១។
[៥២] ក្រមរដ្ឋប្បវេណី, លេខ នស/រកម១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៥៩។

គ្មានផ្ទៃពោះ។[៥៣] ការកំណត់រយៈពេលក្នុងការរៀបអាពាហ៍ពិពាហ៍ថ្មីបែបនេះ ដើម្បីការពារករណីកុំឱ្យមានការយល់ច្រឡំលើទំនាក់ទំនងញាតិរបស់ទារកក្នុងផ្ទៃម្តាយ ពោលគឺកុំឱ្យមានការពិបាកក្នុងការបែងចែកអំពីបុរសដែលជាឪពុករបស់ទារក។ ប៉ុន្តែនៅក្នុងករណីដែលស្ត្រីមានការបញ្ជាក់ច្បាស់លាស់ថាគ្មានផ្ទៃពោះ គឺមានសិទ្ធិរៀបចំណងអាពាហ៍ពិពាហ៍ថ្មី។ ជារួមមក ក្រោយការលែងលះភាគីទាំងសងខាងសុទ្ធតែមានសិទ្ធិសេរីភាពឡើងវិញក្នុងការរៀបអាពាហ៍ពិពាហ៍សារជាថ្មីម្តងទៀត។

**២.២.២.២. កាតព្វកិច្ចបន្សល់ក្រោយការលែងលះ**

នៅក្រោយការលែងលះនឹងមានបន្សល់ទុកនូវកាតព្វកិច្ចមួយចំនួនចំពោះភាគីដូចជា កាតព្វកិច្ចបង់សោហ៊ុយ ដែលចាំបាច់ដើម្បីថែរក្សាកូនបញ្ចប់ករណីយកិច្ចសហព័ទ្ធ និងកាតព្វកិច្ចចំពោះតតិយជន។

**ក. កាតព្វកិច្ចបង់សោហ៊ុយដែលចាំបាច់ដើម្បីថែរក្សាកូន**

ឪពុក ឬម្តាយដែលមានចំណងអាពាហ៍ពិពាហ៍ ត្រូវប្រើប្រាស់អំណាចមេបាដោយសហការគ្នា។[៥៤] ប៉ុន្តែនៅក្រោយកាលែងលះ គឺត្រូវមានភាគីណាម្ខាងជាអ្នកមានសិទ្ធិអំណាចមេបាលើកូន ដែលគេហៅថាអំណាចមេបាទោល។ ដោយសារតែការបែងចែកកូនមានការពាក់ព័ន្ធនឹងអាហារកាតព្វកិច្ចចិញ្ចឹមកូន ហេតុនេះហើយបានជានៅក្រោយពេលលែងលះតុលាការត្រូវពិចារណា ហើយសម្រេចឱ្យភាគីណាម្ខាងឪពុក ឬម្តាយជាអ្នកមានអំណាចមេបាលើកូន។ ក្នុងករណីនេះ តុលាការកំណត់ម្តាយជាអ្នកមានអំណាចមេបា ម្តាយត្រូវចាត់ទុកថាជាអ្នកមានសិទ្ធិលើសោហ៊ុយចាំបាច់ដើម្បីថែរក្សាកូន ហើយឪពុកត្រូវចាត់ទុកថាអ្នកមានករណីយកិច្ចបង់សោហ៊ុយចាំបាច់ដើម្បីថែរក្សាកូន។[៥៥] ចំពោះចំណុចនេះ ឪពុកម្តាយដែលលែងលះគ្នាអាចធ្វើការពិភាក្សាអំពីចំណុចនេះបាន។[៥៦] ផ្ទុយទៅវិញ ប្រសិនបើការពិភាក្សានោះពុំទទួលបានជោគជ័យ តុលាការត្រូវធ្វើការសម្រេចអំពីសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងកូន[៥៧] ដោយតុលាការធ្វើការសម្រេចអំពីចំនួននៃសោហ៊ុយចាំបាច់ដើម្បីចិញ្ចឹមកូន ដោយពិចារណាទៅលើស្ថានភាពជីវភាព និងសេដ្ឋកិច្ចរបស់ឪពុក ឬម្តាយដែលមានករណីយកិច្ចត្រូវបង់នោះ។ ប៉ុន្តែនៅក្នុងរឿងក្តីលែងលះដោយការព្រមព្រៀងនេះ គូភាគីតែងតែបានព្រមព្រៀងគ្នារួចជាស្រេចមិនមានអ្វីដែលឱ្យតុលាការពិបាកសម្រេចឡើយ។

---

[៥៣] ក្រមរដ្ឋប្បវេណី, លេខ នស/រកម១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៥០។
[៥៤] ក្រមរដ្ឋប្បវេណី, លេខ នស/រកម១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១០៣៦ វាក្យខណ្ឌទី១។
[៥៥] ក្រមរដ្ឋប្បវេណី, លេខ នស/រកម១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា១០៤០ កថាខណ្ឌទី១។
[៥៦] ក្រមរដ្ឋប្បវេណី, លេខ នស/រកម១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា១០៤០ កថាខណ្ឌទី៣ និងកថាខណ្ឌទី៣។
[៥៧] ក្រមរដ្ឋប្បវេណី, លេខ នស/រកម១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា១០៤០ កថាខណ្ឌទី៤។

**ខ. ការបញ្ចប់ករណីយកិច្ចសហព័ទ្ធ**

ជាការពិតណាស់ នៅក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាសហព័ទ្ធនឹងត្រូវមានករណីយកិច្ចរួមគ្នាដូចជា ករណីយកិច្ចរួមរស់ជាមួយគ្នា ករណីយកិច្ចសហការគ្នា និងព្រមទាំងករណីយកិច្ចជួយសង្គ្រោះគ្នាទៅវិញទៅមក ដើម្បីឈានទៅកាន់វឌ្ឍនភាពគ្រួសារព្រមទាំងកសាងគ្រួសារមួយមានសាមគ្គីភាព និងប្រកបដោយសុភមង្គល។[៥៨] ប៉ុន្តែអ្វីៗទាំងអស់នេះនឹងបញ្ចប់ដោយការលែងលះគ្នា ដូចនេះ នៅពេលដែលភាគីលែងលះគ្នានឹងបណ្តាលឱ្យភាគីរួចផុតពីករណីយកិច្ចសហព័ទ្ធទាំងឡាយនោះ គឺដោយសារអានុភាពនៃដីកាសម្រេច។

**គ. កាតព្វកិច្ចចំពោះតតិយជន**

កាតព្វកិច្ចចំពោះតតិយជន គឺសំដៅលើការដែលសហព័ទ្ធត្រូវទទួលខុសត្រូវបំពេញកាតព្វកិច្ចជូនជនដទៃទៀតដែលមានឋានៈជាម្ចាស់បំណុល ដែលត្រូវបានច្បាប់ទទួលស្គាល់។ សហព័ទ្ធត្រូវមានករណីយកិច្ចសាមគ្គីគ្នាក្នុងការទទួលខុសត្រូវចំពោះកាតព្វកិច្ច និងករណីយកិច្ចផ្សេងៗ ដែលសហព័ទ្ធបានព្រមព្រៀងជាមួយតតិយជន ដែលបានធ្វើឡើងនៅក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។[៥៩] ត្រង់ចំណុចនេះបានសេចក្តីថា ទោះបីភាគីមានការលែងលះជាមួយគ្នាក៏ដោយ តែភាគីទាំងពីរនៅតែត្រូវមានកាតព្វកិច្ចទទួលខុសត្រូវ ចំពោះតតិយជនដែលជាម្ចាស់បំណុលលើបំណុលទាំងឡាយណា ដែលបានជំពាក់នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ជាមួយគ្នា។ បើបំណុលនោះ ជាបំណុលរួមនោះភាគីត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ហើយក្នុងករណីបំណុលនោះជាបំណុលដោយឡែក នោះភាគីម្ខាងៗ ត្រូវទទួលខុសត្រូវលើបំណុល នោះរៀងៗខ្លួន។ សរុបមក ថ្វីត្បិតតែចំណងអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់ដោយការលែងលះ ក៏ដោយក្តីតែអានុភាពនៃការលែងលះ មិននាំឱ្យបញ្ចប់នូវកាតព្វកិច្ចមួយចំនួនដូចដែលបានរៀបរាប់ខាងលើនេះ។

[៥៨] ក្រមរដ្ឋប្បវេណី, លេខ នស/រកម១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៦៦។

[៥៩] ក្រមរដ្ឋប្បវេណី,លេខ នស/រកម១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៧៥។

# ជំពូកទី៣
# ការលែងលះ
# ដោយគ្មានការព្រមព្រៀង

# ជំពូកទី៣

# ការលែងលះដោយគ្មានការព្រមព្រៀង

ការលែងលះដោយគ្មានការព្រមព្រៀង គឺស្ថិតនៅក្រោមវិសាលភាពនៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ហេតុនេះចំពោះការលែងលះដោយគ្មានការព្រមព្រៀងគ្នា ត្រូវប្រព្រឹត្តទៅតាមច្បាប់នេះ។ ហើយការលែងលះដោយគ្មានការព្រមព្រៀងនេះ គឺត្រូវធ្វើឡើងនៅពេលដែលភាគីនៃចំណងអាពាហ៍ពិពាហ៍មិនបានព្រមព្រៀងគ្នាក្នុងការបញ្ចប់នូវចំណងអាពាហ៍ពិពាហ៍ ឬភាគីមានទំនាស់លើការបែងចែកសិទ្ធិ និងកាតព្វកិច្ចផ្សេងៗក្រោយការលែងលះ។ ការលែងលះដោយគ្មានការព្រមព្រៀងនេះ ត្រូវបានឆ្លងកាត់ដំណាក់កាលនីតិវិធីរដ្ឋប្បវេណីជាច្រើន មុននឹងឈានដល់ការសម្រេចសេចក្តីដោយសាលក្រមរបស់តុលាការ។

## ៣.១. នីតិវិធីនៃការលែងលះដោយគ្មានការព្រមព្រៀង

នីតិវិធីនៃការលែងលះដោយគ្មានការព្រមព្រៀងនេះមានដូចជា ការធ្វើពាក្យបណ្តឹងលែងលះ ការផ្សះផ្សា ការចាត់ចែងរក្សាការពារ នីតិវិធីត្រៀមសម្រាប់ទាញហេតុផល នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងការសម្រេចសេចក្តី។

### ៣.១.១. ការធ្វើពាក្យបណ្តឹងលែងលះ

ការលែងលះដោយការគ្មានការព្រមព្រៀងចាប់ផ្តើមដំណើរការនៃនីតិវិធី នៅពេលដែលសហព័ទ្ធម្ខាងបានដាក់ពាក្យបណ្តឹងទាមទារលែងលះ ដោយអនុលោមតាមច្បាប់ ស្តីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ២០១០ និងក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។ នៅក្នុងដំណើរការនៃនីតិវិធីនេះ ជំហានដំបូងនោះ គឺភាគីត្រូវធ្វើបណ្តឹងលែងលះ ដោយភ្ជាប់មកជាមួយនឹងឯកសារព្រមទាំងភស្តុតាងពាក់ព័ន្ធផ្សេងៗ។ រួចភាគីត្រូវយកពាក្យបណ្តឹងលែងលះនោះទៅដាក់នៅក្រុមប្រឹក្សាឃុំ-សង្កាត់ ខាងលំនៅឋានប្តីប្រពន្ធ ឬទីសំណាក់ ឬក៏យកទៅដាក់នៅតុលាការដែលមានសមត្ថកិច្ច និងត្រូវបង់ពន្ធតាមការកំណត់នៃច្បាប់។[៦០]

#### ៣.១.១.១. ការសរសេរពាក្យបណ្តឹង

ពាក្យបណ្តឹងលែងលះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដែលអនុវត្តតាមបញ្ញត្តិ នៃមាត្រា៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ពីព្រោះថាចំណងអាពាហ៍ពិពាហ៍រវាងប្តីប្រពន្ធ មិនមែនជាកិច្ចសន្យាធម្មតានោះទេ ពោលគឺជាកិច្ចសន្យាដ៏ឱឡារិកមួយ ដែលធ្វើឡើងដោយប្តីប្រពន្ធតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាច

[៦០] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៦១។

វិលោយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួនបានឡើយ។[៦១] ហេតុដូច្នេះហើយ ទើបបណ្តឹងលែងលះចាំបាច់ គឺត្រូវតែដោះស្រាយតាមរយៈតុលាការដែលមានសមត្ថកិច្ច ដោយភាគីជាដើមចោទត្រូវដាក់ពាក្យបណ្តឹងទៅតុលាការ ដែលមានសមត្ថកិច្ច គឺតុលាការនៅទីលំនៅឋានរបស់សហព័ទ្ធណាម្ខាង។

នៅក្នុងពាក្យបណ្តឹងលែងលះ ត្រូវសរសេរបញ្ជាក់អំពី៖

- ឈ្មោះ និងអាសយដ្ឋានរបស់ភាគី និងឈ្មោះ និងអាសយដ្ឋានដែលច្បាប់បានកំណត់។
- ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ៖ សំដៅលើអត្ថន័យនៃសាលក្រមដែលដើមចោទចង់ឱ្យតុលាការសម្រេចសេចក្តីដូចក្នុងពាក្យបណ្តឹងរបស់ខ្លួន។ **ឧទាហរណ៍** នៅក្នុងរឿងក្តីលែងលះ ដែលជាបណ្តឹងទាមទារឱ្យរំលត់ទំនាក់ទំនងគតិយុត្ត ដូចនេះខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ គឺឱ្យដើមចោទ និងចុងចម្លើយលែងលះពីគ្នា ចាប់ពីពេលដែលសាលក្រមចូលជាស្ថាពរ។
- អង្គហេតុចាំបាច់ ដើម្បីបញ្ជាក់អំពីការទាមទារ៖ សំដៅលើអង្គហេតុ ដែលអាចធ្វើការកត់សម្គាល់កុំឱ្យមានការភាន់ច្រឡំរវាងសិទ្ធិ ឬទំនាក់ទំនងគតិយុត្តអះអាងដោយដើមចោទ និងសិទ្ធិ ឬសិទ្ធិ និងទំនាក់ទំនងគតិយុត្តផ្សេងទៀត។ **ឧទាហរណ៍** នៅក្នុងរឿងលែងលះ ដើមចោទត្រូវសរសេរបញ្ជាក់ឱ្យបានច្បាស់លាស់អំពី មូលហេតុនៃការលែងលះ។
- អង្គហេតុដែលជាមូលហេតុនៃការទាមទារ គឺជាអង្គហេតុដែលបង្កើតនូវសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលជាសិទ្ធិទាមទារតាមផ្លូវបណ្តឹង ពោលគឺដើម្បីបង្ហាញអំពីការកើតមានឡើងនៃការទាមទារតាមផ្លូវបណ្តឹងរបស់ដើមចោទ។
- អង្គហេតុសំខាន់ៗ ដែលពាក់ព័ន្ធ និងភស្តុតាង គឺជាអង្គហេតុដែលធ្វើឱ្យគេសន្និដ្ឋានអំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុចម្បង។
- ពាក្យបណ្តឹងដែលមានសរសេរអំពីមធ្យោបាយតទល់ ឬការពារខ្លួនត្រូវចាត់ទុកថាជាឯកសារត្រៀមផងដែរ។

### ៣.១.១.២. ការដាក់ពាក្យបណ្តឹង

ភាគីដែលមានបំណងចង់លែងលះ អាចធ្វើការដាក់ពាក្យសុំលែងលះគ្នាទៅក្រុមប្រឹក្សាឃុំ-សង្កាត់ខាងលំនៅឋាន ឬទីសំណាក់ បើពុំមានទីសំណាក់ ឬទីសំណាក់មិនពិតប្រាកដទេ ត្រូវកំណត់តាមលំនៅឋានចុងក្រោយ។ ក្នុងករណីនេះក្រុមប្រឹក្សាឃុំ-សង្កាត់អាចធ្វើការបញ្ចុះបញ្ចូលឱ្យសះជាគ្នាបានក្នុងអំឡុងពេល១៥

[៦១] ច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ៥៦ ក្រ, ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩, មាត្រា៣។

(ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំនោះ។ បើមិនអាចបញ្ចុះបញ្ចូលឱ្យសះជាគ្នាបានទេ ត្រូវចាត់ទុកថាមានពាក្យបណ្ដឹងលែងលះគ្នា ហើយក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវបញ្ជូនពាក្យបណ្ដឹងលែងលះនោះទៅតុលាការជាបន្ទាន់[៦២] ព្រោះក្រុមប្រឹក្សាឃុំ-សង្កាត់មិនមានសមត្ថកិច្ចក្នុងការសម្រេចសេចក្ដីឱ្យភាគីធ្វើការលែងលះ ឬមិនឱ្យមានការលែងលះឡើយ។

បណ្ដឹងទាមទារលែងលះគ្នា គឺជាបណ្ដឹងទាមទារឱ្យរលត់សិទ្ធិ និងទំនាក់ទំនងគតិយុត្ត ដែលមានមូលហេតុនៃការលែងលះទៅតាមបញ្ញត្តិនៃមាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ដោយត្រូវអនុលោមទៅតាមបទបញ្ញត្តិច្បាប់ស្ដីពី នីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ២០១០។ បើយោងទៅតាមមាត្រា១០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ និងមាត្រា៥ នៃច្បាប់ស្ដីពី នីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ២០១០ បណ្ដឹងលែងលះនេះត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្ដាច់មុខរបស់សាលាដំបូង ដែលមានសមត្ថកិច្ចនៅទីលំនៅរបស់ភាគីនៃទំនាក់ទំនងនឹងឋានៈបុគ្គលពាក់ព័ន្ធនឹងបណ្ដឹងនោះ ឬលំនៅ នៅពេលដែលភាគីនោះបានទទួលមរណៈភាព។

### ៣.១.១.៣. ការទទួលពាក្យបណ្តឹង

យោងតាមមាត្រា៦ ចំណុចទី១ នៃអនុក្រឹត្យលេខ២១ អនក្រ.បក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង បានផ្ដល់សមត្ថកិច្ចឱ្យការិយាល័យកិច្ចការតុលាការទទួលបន្ទុកលើការទទួលចាត់ចែងឯកសារចេញចូលរបស់សាលាដំបូង ចុះបញ្ជីពាក្យបណ្ដឹង និងចាត់ចែងបន្តតាមនីតិវិធី។ ហេតុដូចនេះ ភាគីដាក់ពាក្យបណ្ដឹងលែងលះអាចដាក់ពាក្យបណ្ដឹងនៅលេខាធិការដ្ឋានរដ្ឋបាលរបស់សាលាដំបូងដែលមានសមត្ថកិច្ចនោះ។

នៅពេលដែលដាក់ពាក្យបណ្ដឹង ត្រូវបង់ពន្ធលើពាក្យបណ្ដឹង ដែលមានចំនួនទឹកប្រាក់ដោយគណនាតាមតម្លៃនៃកម្មវត្ថុនៃបណ្ដឹង ដែលត្រូវបានកំណត់ដោយច្បាប់។ ការគណនាពន្ធលើពាក្យបណ្ដឹង គឺយកតម្លៃនៃកម្មវត្ថុបណ្ដឹងមកធ្វើជាមូលដ្ឋានដើម្បីធ្វើការគណនា ប៉ុន្តែដោយសារពាក្យបណ្ដឹងលែងលះនេះ គឺជាប្រភេទនៃកម្មវត្ថុបណ្ដឹងដែលទាមទារច្រើនចំណុចនឹងមានការពិបាកក្នុងការគណនាតម្លៃ ហេតុនេះតុលាការត្រូវកំណត់តម្លៃទាំងនោះ ដោយឆន្ទានុសិទ្ធិសមហេតុផល នោះត្រូវចាត់ទុកថាតម្លៃកម្មវត្ថុបណ្ដឹងមានចំនួន ៥.៥០០.០០០ (ប្រាំលានប្រាំសែន) រៀល ដែលដើមចោទត្រូវបង់ពន្ធលើពាក្យបណ្ដឹងនោះ ចំនួន ៥៥.០០០ (ប្រាំម៉ឺនប្រាំពាន់) រៀល។ ចំណែកឯការបង់ពន្ធលើប្រាក់ប្រដាប់ក្ដីតុលាការក្រៅពន្ធភាគី ឬបុគ្គលដែលទាក់ទងនឹងរឿងក្ដីត្រូវបង់

[៦២] ច្បាប់ស្ដីពី និតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០, មាត្រា៥។

ដែលមានចំនួនប្រែប្រួលទៅតាមការកំណត់របស់តុលាការនិងធ្វើការបង់ជាមុនសម្រាប់ការចំណាយរបស់តុលាការ ដែលធ្វើសកម្មភាពតាមនីតិវិធីបណ្តឹងដើម្បីឱ្យតុលាការ។

- ធ្វើការពិនិត្យភស្តុតាង ការបញ្ជូនឯកសារ ឬសកម្មភាពផ្សេងទៀតតាមនីតិវិធីបណ្តឹង។
- សោហ៊ុយធ្វើដំណើរ និងសោហ៊ុយស្នាក់នៅ ដែលចាំបាច់សម្រាប់ចៅក្រម និងក្រឡាបញ្ជីនៅក្នុងករណីដែលធ្វើការពិនិត្យភស្តុតាងការស្រាវជ្រាវអង្គហេតុ ឬសកម្មភាពផ្សេងទៀតដែលប្រព្រឹត្តិនៅក្រៅតុលាការ។ ក្នុងករណីដែលភាគីបានដាក់ពាក្យបណ្តឹងមិនបានបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធទេនោះ តុលាការនឹងលើកពាក្យបណ្តឹងចោលដោយដីកាសម្រេច។[៦៣]

### ៣.១.១.៤. ការពិនិត្យ និងបញ្ជូនពាក្យបណ្តឹង

នៅក្នុងការពិនិត្យពាក្យបណ្តឹងតុលាការត្រូវពិនិត្យមើលទៅលើថា ដើមចោទបានសរសេរនូវចំណុចដែលចាំបាច់ត្រូវសរសេរនៅក្នុងពាក្យបណ្តឹងគ្រប់គ្រាន់តាមមាត្រា៧៥ កថាខណ្ឌទី២ ហើយ ឬនៅ ហើយដើមចោទបានធ្វើការបង់ពន្ធលើពាក្យបណ្តឹងដូចដែលបានចែងក្នុងមាត្រា៦១ និងបានបង់ពន្ធប្រាក់ប្រដាប់ក្តីតុលាការក្រៅពន្ធតាមមាត្រា៦២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៦ ហើយ ឬនៅ។ នៅក្នុងករណីនេះដែរ បើមានចំណុចខ្វះខាតលើពាក្យបណ្តឹង និងមិនបានបំពេញល័ក្ខខ័ណ្ឌដូចខាងលើ តុលាការត្រូវកំណត់អំឡុងពេលសមរម្យ និងបង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតចំពោះពាក្យបណ្តឹងនោះក្នុងអំឡុងពេលនោះ។ បើភាគីមិនបានកែតម្រូវអំពីចំណុចខ្វះខាតនោះទេនោះ តុលាការត្រូវលើកពាក្យបណ្តឹងនោះចោលដោយដីកាសម្រេច។ ដីកាសម្រេចនេះអាចបណ្តឹងជំទាស់បាន។[៦៤]

នៅពេលដែលតុលាការបានពិនិត្យលើពាក្យបណ្តឹងលែងលះឃើញថាមានលក្ខណៈត្រឹមត្រូវតាមទម្រង់និងស្របតាមនីតិវិធីហើយ តុលាការបញ្ជូនពាក្យបណ្តឹងលែងលះឱ្យចុងចម្លើយជាចាំបាច់[៦៥] ព្រោះថាការបញ្ជូនពាក្យបណ្តឹង គឺជាការផ្តល់ឱកាសឱ្យភាគីចុងចម្លើយបានដឹងថាសហព័ទ្ធរបស់ខ្លួនបានប្តឹងសុំលែងលះ។ កិច្ចការបញ្ជូនត្រូវធ្វើឡើងដោយក្រឡាបញ្ជី ឬបុគ្គលិកប្រៃសណីយ៍ ឬអាជ្ញាសាលាជាដើម។[៦៦] ពាក្យបណ្តឹងត្រូវបានបញ្ជូនទៅដល់ចុងចម្លើយទើបបណ្តឹងនោះត្រូវបានចាត់ការ។ ក្នុងករណីដែលមិនអាចបញ្ជូនបណ្តឹងបានដោយសារមូលហេតុអាសយដ្ឋានរបស់ចុងចម្លើយ ដែលដើមចោទផ្តល់ឱ្យមិនមានភាពច្បាស់លាស់ ឬមានការផ្លាស់ប្តូរអាសយដ្ឋានជាដើម ឬតុលាការត្រូវបង្គាប់ឱ្យដើមចោទកែតម្រូវដោយទុកអំឡុងពេលសមរម្យ។

[៦៣] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៦២ កថាខណ្ឌទី៥។

[៦៤] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៧៨ កថាខណ្ឌទី៣។

[៦៥] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៧៩។

[៦៦] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា២៤៦។

### ៣.១.២. ការផ្សះផ្សា

ការផ្សះផ្សា គឺជាការសម្របសម្រួលដោយមានការចូលរួមអន្តរាគមន៍ពីសំណាក់មន្ត្រីមានសមត្ថកិច្ចជូនដល់ភាគីដើមចោទ និងចុងចម្លើយនៃបណ្តឹងលែងលះ ដើម្បីឱ្យយល់ព្រមសះជានឹងគ្នាព្រមទាំងបញ្ឈប់ពាក្យបណ្តឹងលែងលះពីតុលាការវិញ។ ជាទូទៅ ប្រសិនបើភាគីបានដាក់ពាក្យសុំទៅក្រុមប្រឹក្សាឃុំ-សង្កាត់នោះក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រាកដជាធ្លាប់ធ្វើការផ្សះផ្សាទៅដល់គូភាគីក្នុងរយៈពេល១៥ (ដប់ប្រាំ)ថ្ងៃ មុននឹងបញ្ជូនពាក្យបណ្តឹងលែងលះមកតុលាការ។ បើទោះបីជាធ្លាប់មាន ឬមិនធ្លាប់មាននូវការផ្សះផ្សានៅដំណាក់កាលក្រុមប្រឹក្សាឃុំ-សង្កាត់ក៏តុលាការធ្វើការផ្សះផ្សាដល់គូភាគីដែរ។ មួយវិញទៀត បើទោះបីជាភាគីម្ខាងទាមទារយ៉ាងខ្លាំងចំពោះការលែងលះគ្នាក៏ដោយ តុលាការអាចសាកល្បងធ្វើការផ្សះផ្សាឡើងវិញបាន។[៦៧] មូលហេតុនៃការផ្សះផ្សា គឺដោយសារតែការលែងលះធ្វើឱ្យអាចបាត់បង់នូវផលប្រយោជន៍ជាច្រើនដូចជា ពេលវេលាទ្រព្យសម្បត្តិ និងសុភមង្គលជាអាទិ៍។

### ៣.១.៣. ការចាត់ចែងរក្សាការពារ

ជាទូទៅនៅក្នុងដំណើរការនៃបណ្តឹងនៃការលែងលះទាមទារនូវពេលវេលាមួយយ៉ាងវែងបែបនេះដោយសារតែច្បាប់តម្រូវឱ្យមានការសាកល្បងធ្វើការផ្សះផ្សាគ្នា រួមទាំងនីតិវិធីរបស់តុលាការជាច្រើនទៀត នៅក្រោយពេលដែលផ្សះផ្សាគ្នារួចរាល់ហើយ។ ហេតុនេះទើបតុលាការអាចបង្គាប់ឱ្យមាន ការចាត់ចែងរក្សាការពារ (វិធានការបណ្តោះអាសន្ន) ដែលចាំបាច់ចំពោះការបំបែកលំនៅឋាន ការគ្រប់គ្រងថែរក្សាកូន ការគ្រប់គ្រងទ្រព្យសម្បត្តិ អាហារកិច្ចរបស់សហព័ទ្ធបន្ទុកសោហ៊ុយអាពាហ៍ពិពាហ៍ និងសោហ៊ុយចិញ្ចឹមបីបាច់កូនជាអាទិ៍តាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិបាន។ ការចាត់ចែងរក្សាការពារ គឺជាវិធានការដើម្បីធានាឱ្យជីវភាពរស់នៅក្នុងគ្រួសារអាចបន្តទៅទៀតបានដោយសមរម្យ សហព័ទ្ធទាំងសងខាងកំពុងតែប្តឹងទាមទារលែងលះគ្នាក៏ដោយ។ ទោះបីជាការចាត់ចែងរក្សាការពារ (វិធានការបណ្តោះអាសន្ន) មានលក្ខណៈជាបណ្តោះអាសន្ន ព្រោះវាមានប្រសិទ្ធភាពតែក្នុងរយៈពេលដំណើរការនៃរឿងក្តីប៉ុណ្ណោះ ពោលគឺនៅពេលដែលតុលាការចេញសាលក្រមស្ថានពររួចសាលក្រមនោះនឹងមកជំនួសឱ្យវិធានការបណ្តោះអាសន្នហើយរាល់វិធានការទាំងអស់នោះនឹងត្រូវអស់សុពលភាព។

#### ៣.១.៣.១. វិធានការដាក់ឱ្យសហព័ទ្ធរស់នៅបែកគ្នាជាបណ្តោះអាសន្ន

ច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៧ អនុញ្ញាតឱ្យតុលាការចេញវិធានការឱ្យភាគីទាំងពីរស់នៅបែកគ្នាបណ្តោះអាសន្ន នៅក្នុងអំឡុងពេលនៃនីតិវិធីលែងលះគ្នា ក្នុងករណីភាគីទាំងពីរមានប្រើអំពើ

[៦៧] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៩៨៤ កថាខណ្ឌទី១។

ហិង្សាក្នុងគ្រួសារ។ ប៉ុន្តែក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ មិនមានចែងអំពីវិធានការឱ្យសហព័ទ្ធនោះត្រូវតែរស់នៅបែកគ្នាបណ្ដោះអាសន្នទេ ក្នុងករណីភាគីទាំងពីរមានប្រើអំពើហិង្សាក្នុងគ្រួសារ និងបានប្ដឹងសុំលែងលះគ្នា។ ករណីនេះ ប្រហែលជាពួកគេពឹងផ្អែកទៅលើច្បាប់ស្ដីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះឆ្នាំ២០០៥ ដែលផ្ដល់អំណាចទៅឱ្យមេឃុំ-ចៅសង្កាត់ ក្នុងដំណាក់កាលនៃការជួយ អន្តរាគមន៍លើកដំបូង។ មាត្រា១៤ នៃច្បាប់ស្ដីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥ បានផ្ដល់សិទ្ធិអំណាចទៅដល់មេឃុំ-ចៅសង្កាត់អាចចាត់វិធានការបណ្ដោះអាសន្នដែលមានដូចជា៖

- ហាមប្រព្រឹត្តអំពើហិង្សានៅក្នុងគ្រួសារដោយខ្លួនឯងផ្ទាល់ ឬដោយអ្នកផ្សេង។
- ហាមបំផ្លាញទ្រព្យសម្បត្តិ ឬណែនាំកុំឱ្យចាត់ចែងលក់ទ្រព្យសម្បត្តិរួម ឬរបស់ជនរងគ្រោះ ឬរបស់ញាតិសាច់សាលោហិតរបស់ជនរងគ្រោះ។ ហាមជនមុខសញ្ញាចូលទៅជិត ឬចូលទៅក្នុងទីលំនៅរួម កន្លែងស្នាក់នៅ ឬកន្លែងធ្វើការរបស់ជនរងគ្រោះ បើគ្មានការអនុញ្ញាតពីជនរងគ្រោះ និងអាជ្ញាធរមានសមត្ថកិច្ច។
- ចាត់វិធានការស្របច្បាប់ផ្សេងទៀតដែលចាំបាច់សម្រាប់ការពារសុវត្ថិភាពជនរងគ្រោះ និងសមាជិកគ្រួសារ ឬជនបានដែលពាក់ព័ន្ធ។

ទន្ទឹមនឹងនេះដែរ ការធ្វើអន្តរាគមន៍របស់អាជ្ញាធរមានសមត្ថកិច្ចជនរងគ្រោះអាចធ្វើបណ្ដឹងនេះទៅតុលាការរាជធានី ខេត្ត ដើម្បីសុំចេញដីការក្សាការពារ។ តុលាការដែលទទួលបណ្ដឹង ដើម្បីចាត់ការអាចចេញដីការក្សាការពារដោយមានវត្តមាន ឬពុំចាំបាច់មានវត្តមានសហព័ទ្ធដែលបានប្រើអំពើហិង្សា។ ប្រសិនបើមានអំពើហិង្សាលើរូបរាងកាយប្រពន្ធ ឬកូន ឬក៏ក្នុងករណីមានអំពើឃោរឃៅលើស្មារតីធ្ងន់ធ្ងរ ពេលនោះប្រហែលជាប្រពន្ធចង់ស្នើសុំឱ្យ ភាគីទាំងពីររស់បែកគ្នាចាប់តាំងពីពេលចាប់ផ្ដើមនីតិវិធីលែងលះគ្នា។

ចំណាត់ការបែបនេះ គឺនៅក្នុងគោលបំណងការពារនូវសុវត្ថិភាពរបស់ភាគីទាំងសងខាង នៅពេលដំណើរការនៃរឿងក្ដី។ ម្យ៉ាងវិញទៀត ដើម្បីបញ្ចៀសនូវរាល់សកម្មភាពអវិជ្ជមាននានាទៅលើគ្នាទៅវិញទៅមកតាមរយៈការគុំគួនគ្នាធ្វើទុក្ខបុកម្នេញ ប្រើអំពើហិង្សារហូតអាចឈានទៅដល់ការបាត់បង់ជីវិតក៏ថាបាន។ ដូច្នេះការរស់នៅបែកលំនៅគ្នាអាចជាវិធានការដ៏ល្អក្នុងការបញ្ចៀសជម្លោះដោយសារតែពួកគេផ្សះផ្សាគ្នាលែងបាន ហើយ និងធ្វើឱ្យមានភាពងាយស្រួលចំពោះតុលាការផង។

**៣.១.៣.២. វិធានការថែរក្សាកូនជាបណ្ដោះអាសន្ន**

បញ្ហាកូន ក៏ជាប្រធានបទក្ដៅគគុកមួយចំពោះការលែងលះដែរ ពីព្រោះភាគច្រើននៃការលែងលះ ភាគីសុទ្ធតែប្ដឹងទាមទារកូនរៀងៗខ្លួន។ ដូច្នេះហើយ ដើម្បីការពារសុវត្ថិភាពកូនក៏ដូចជា ដើម្បីបញ្ចៀសនូវរាល់វិបត្តិផ្លូវចិត្តទៅលើកូនៗ តុលាការនឹងអនុញ្ញាតឱ្យមានវិធានការគ្រប់គ្រងកូន។ ជាតួយ៉ាង នៅពេលឪពុកម្ដាយប្ដឹងលែងលះគ្នា គឺជាបញ្ហាមួយយ៉ាងធ្ងន់ធ្ងរនៅក្នុងគ្រួសារសម្រាប់កូន ពោលគឺកូននឹងត្រូវបានបាត់បង់នូវភាពកក់ក្ដៅពីឪពុកម្ដាយ។ ដោយឡែក ការគ្រប់គ្រងកូនក៏អាចខាងប្រពន្ធមានអាទិភាពក្នុងការមើលថែទាំកូនជាងខាងប្ដី ប្រសិនកូន គឺជាទារកដែលនៅបៅទឹកដោះម្ដាយ ព្រោះត្រូវគិតគូរពីសុខភាពទារកផងដែរ។ ដូចដែលបានលើកឡើងនេះ ក៏ដូចជាការជៀសវាងនូវការបង្ខិតបង្ខំនានាទៅលើការសម្រេចចិត្តរបស់កូន។ តុលាការគួរគប្បីមានចំណាត់ការឱ្យមានអ្នកមើលថែរក្សាកូន ដែលយល់ឃើញថាសមរម្យទើបអាចឱ្យការសម្រេចសេចក្ដីមានយុត្តិធម៌ជាប្រយោជន៍ដល់កូន។

**៣.១.៣.៣. វិធានការថែរក្សាទ្រព្យជាបណ្ដោះអាសន្ន**

ទ្រព្យសម្បត្តិ ជាកម្មវត្ថុដ៏ចម្បងមួយទៀតនៃបណ្ដឹងលែងលះហើយដែលភាគីតែងតែខិតខំស្វែងរកកំហុសមកដាក់បន្ទុកឱ្យគ្នា ដើម្បីអាចទទួលបាននូវចំណែកនៃទ្រព្យសម្បត្តិច្រើនជាងគេ។ តុលាការ ឬភាគីត្រូវយកចិត្តទុកដាក់លើការចាត់ចែងរក្សាការពារទ្រព្យសម្បត្តិឱ្យបានគង់វង្សដែរ ដោយជៀសវាងនូវការលក់ដូរ ឬការបំផ្លិចបំផ្លាញរបស់ភាគីណាមួយ ដែលអាចធ្វើឱ្យចំណែកមួយនៃកម្មវត្ថុនៃបណ្ដឹងត្រូវបាត់បង់។ តាមការពិតការចាត់ចែងរក្សាការពារទ្រព្យសម្បត្តិនៅក្នុងល័ក្ខខ័ណ្ឌនេះ សំដៅតែលើការគ្រប់គ្រងទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធតែប៉ុណ្ណោះ ដោយតុលាការមិនអាចលូកដៃចូលទៅគ្រប់គ្រងទ្រព្យសម្បត្តិដោយឡែករបស់ភាគីម្ខាងៗនោះទេ។[៦៨]

**៣.១.៣.៤. វិធានការផ្គត់ផ្គង់សហព័ទ្ធ ឬកូនជាបណ្ដោះអាសន្ន**

វិធានការនេះ មានគោលបំណងរក្សាជីវភាពរស់នៅរបស់សហព័ទ្ធណាម្ខាង និងការផ្គត់ផ្គង់លើរាល់តម្រូវការរបស់កូនក្នុងអំឡុងពេលនៃនីតិវិធីលែងលះ។ ជាការពិតណាស់ គ្រួសារខ្លះមានសហព័ទ្ធម្ខាងជាអ្នកចេញទៅក្រៅផ្ទះរកចំណូលមកធ្វើការផ្គត់ផ្គង់គ្រួសារ ហើយសហព័ទ្ធម្ខាងទៀតជាអ្នកមើលការខុសត្រូវនៅក្នុងផ្ទះ។ ទោះបីជាយ៉ាងណា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានឱ្យតម្លៃការងារក្នុងផ្ទះស្មើនឹងតម្លៃការងារក្រៅផ្ទះដូចគ្នាដែរ។ ដូចនេះហើយសហព័ទ្ធដែលមានលទ្ធភាពមិនអាចបដិសេធកាតព្វកិច្ចសម្រាប់

[៦៨] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧,មាត្រា៩៨០។

ការផ្តត់ផ្គង់នេះបានទេ ព្រោះប្រសិនបើគ្មានការផ្តត់ផ្គង់ជាបណ្តោះអាសន្ននោះទេ វានឹងធ្វើឱ្យសហព័ទ្ធម្ខាងមានការលំបាកនៅក្នុងការទ្រទ្រង់ជីវភាព។ ជាទូទៅ តុលាការចាត់វិធានការនេះដោយផ្តោតសំខាន់លើសេចក្តីត្រូវការរបស់កូនលទ្ធភាពខាងហិរញ្ញវត្ថុរបស់ភាគីស្នើសុំ និងលទ្ធភាពហិរញ្ញវត្ថុរបស់អ្នកដែលត្រូវផ្តត់ផ្គង់។[៦៩]

### ៣.១.៣.៥. ធ្វើការរឹបអូសជាបណ្តោះអាសន្ន

ជាទូទៅនីតិវិធីនៃការលែងលះដោយគ្មានការព្រមព្រៀង ត្រូវឆ្លងកាត់នូវនីតិវិធីជាច្រើន ព្រមទាំងមានការសាកល្បងជាច្រើនលើក ដើម្បីផ្សះផ្សាសហព័ទ្ធទាំងពីរដែលជាហេតុធ្វើឱ្យមាននីតិវិធីនៃការលែងលះដោយគ្មានការព្រមព្រៀងត្រូវការពេលវេលាមួយយ៉ាងយូរផងដែរ។ ហេតុនេះហើយទើបតុលាការអាចចេញដីកាសម្រេចបង្គាប់ឱ្យធ្វើការចាត់ចែងរក្សាការពារ ចំពោះការបំបែកលំនៅឋាន ការគ្រប់គ្រងថែរក្សាកូន ការគ្រប់គ្រងទ្រព្យសម្បត្តិ អាហារកាតព្វកិច្ចរបស់សហព័ទ្ធ បន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍ និងសោហ៊ុយចិញ្ចឹមបីបាច់កូនជាអាទិ៍ តាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិបាន។[៧០]

ចំពោះការចាត់ចែងរក្សាការពារនេះផងដែរ មានលក្ខណៈជាបណ្តោះអាសន្ន ព្រោះវាមានប្រសិទ្ធភាពតែក្នុងអំឡុងពេលដែលដំណើរការនៃរឿងក្តីប៉ុណ្ណោះ ពោលគឺនៅពេលដែលតុលាការការដែលចេញសាលក្រមជាស្ថាពររួចសាលក្រមនោះនឹងមកជំនួសឱ្យវិធានការបណ្តោះអាសន្ន ហើយរាល់វិធានការទាំងអស់នោះនឹងត្រូវអស់សុពលភាព។

## ៣.១.៤. នីតិវិធីត្រៀមសម្រាប់ទាញហេតុផល

គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺតុលាការត្រូវរៀបចំនូវសេចក្តីអះអាងរបស់ភាគី ដើម្បីបំភ្លឺនូវចំណុចវិវាទនៃរឿងក្តីដែលគូភាគីមិនយល់ស្របគ្នា និងរៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចនៃរឿងក្តីលែងលះនោះ ដើម្បីអាចធ្វើការវិនិច្ឆ័យរឿងនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលឱ្យបានល្អិតល្អន់។ ដូចនេះ តុលាការអាចកោះហៅភាគីឱ្យមកធ្វើការបំភ្លឺម្នាក់ម្តងដែលកាលបរិច្ឆេទត្រូវកំណត់ទៅតាមពេលវេលាដែលគូភាគីអាចចូលរួមបាន។ ដោយសារតែរឿងក្តីលែងលះ គឺជាវិវាទដែលត្រូវតែមានវត្តមានរបស់គូភាគីទាំងសងខាង នៅក្នុងពេលស៊ើបសួរទើបញុំាងឱ្យការកាត់សេចក្តីរបស់តុលាការអាចធានាបានថាសមហេតុផលប្រកបដោយភាពសត្យានុម័ត។ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផល តុលាការអាចចេញដីកាសម្រេច ដែលទាក់ទងនឹងការស្នើសុំពិនិត្យភស្តុតាង ឬដីកាសម្រេចផ្សេងទៀត ដែលអាចសម្រេចបាន ក្រៅពីកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ និងអាចពិនិត្យភស្តុតាងឯកសារ

[៦៩] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា១០៣។

[៧០] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៨៣។

ដោយមានកម្រិតចាំបាច់ដើម្បីរៀបចំចំណុចវិវាទនៃរឿងក្តី និងភស្តុតាង។ ជាក់ស្តែងនៅគ្រប់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផល តុលាការត្រូវឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុដែលមានខ្លឹមសារពេញលេញដែលអាចឱ្យតុលាការយកធ្វើជាអំណះអំណាងនៅពេលសវនាការ។

### ៣.១.៥. នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

នៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានចប់សព្វគ្រប់ហើយតុលាការត្រូវកំណត់កាលបរិច្ឆេទ ដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅគូភាគីទាំងសងខាងមកចូលរួមសារជាថ្មីម្តងទៀត។ វាមានភាពចាំបាច់ច្រើនដែលទាមទារឱ្យមាននីតិវិធីនេះ ដែលតុលាការមិនអាចរំលងលើកលែងតែចំពោះរឿងក្តីណា ឬចំណុចណាដែលត្រូវសម្រេចដោយដីកាសម្រេចទើបតុលាការអាចកំណត់បានថាត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬមិនត្រូវធ្វើ។ ជារួមការទាញហេតុផលដោយផ្ទាល់មាត់មិនមានភាពខុសប្លែកគ្នាពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះទេ ពោលគឺនៅក្នុងនីតិវិធីនៃការទាញហេតុផលនេះ ភាគីត្រូវតែធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ព្រមទាំងអាចអះអាងបន្ថែមទៀតអំពីអង្គហេតុ និងដាក់ភស្តុតាងមកទៀតបាន ប្រសិនបើភាគីយល់ឃើញថាភស្តុតាងមិនទាន់គ្រប់គ្រាន់។ សម្រាប់ការពិនិត្យលើភស្តុតាងនៃរឿងក្តីលែងលះ ចៅក្រមត្រូវពិនិត្យទៅលើទំនាក់ទំនងប្តីប្រពន្ធស្របច្បាប់តាមរយៈការបង្ហាញនូវសំបុត្រអាពាហ៍ពិពាហ៍របស់អ្នកទាំងពីរនោះ ហើយកាលណាពិនិត្យឃើញថាគូក្តីពិតជាប្តីប្រពន្ធស្របច្បាប់មែនទើបអាចបន្តនីតិវិធីទៀត។ ប្តីប្រពន្ធដែលត្រឹមត្រូវស្របច្បាប់ត្រូវតែចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ហើយកិច្ចសន្យានេះត្រូវចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍ និងត្រូវចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន ព្រមទាំងផ្តិតមេដៃរបស់ប្តីប្រពន្ធ និងសាក្សីគ្រប់អាយុការចំនួន ២នាក់ រួចហើយត្រូវប្រគល់ឱ្យសាមីខ្លួនប្តីប្រពន្ធ នូវសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមមួយសន្លឹក និងព្រមទាំងចេញសេចក្តីចម្លងតាមការស្នើសុំសាមីខ្លួន។ រីឯទំនាក់ទំនងគតិយុត្តដែលភាគីប្តឹងទាមទារកូនក៏ដូចគ្នា ពោលគឺត្រូវមានសំបុត្រកំណើត ដែលបង្ហាញថាកូននោះពិតជាកូនរបស់គូក្តីទាំងពីរ ដែលចុះសៀវភៅកំណើតនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៅសាលាឃុំសង្កាត់នៃលំនៅឋានអចិន្ត្រៃយ៍របស់ឪពុកម្តាយ ដែលជាគូក្តីលែងលះនោះ។ ម្យ៉ាងវិញទៀត សម្រាប់ការដាក់ភស្តុតាងនៃម្ចាស់កម្មសិទ្ធិលើទ្រព្យសម្បត្តិ ជាបញ្ហាសំខាន់មួយទៀតដែលគូភាគីត្រូវបង្ហាញដូចជា ប្លង់កម្មសិទ្ធិលើអចលនទ្រព្យ ការបង្ហាញឱ្យដាច់ស្រឡះពីគ្នារវាងទ្រព្យរួម និងទ្រព្យដោយឡែក។ បន្ថែមលើការដាក់ភស្តុតាងឱ្យតុលាការនីតិវិធីស៊ើបសួរត្រូវប្រព្រឹត្តិទៅដោយការសាកសួរសាក្សី។ តុលាការអាចបង្គាប់ឱ្យនាំខ្លួនសាក្សីចំពោះសាក្សីណាដែលមានករណីយកិច្ចត្រូវតែចូលខ្លួនមកបំភ្លឺ តែមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តាមរយៈដីកាសម្រេចបាន។ ផ្ទុយទៅវិញ តុលាការក៏អាច

សួរសាក្សីនៅក្រៅតុលាការបានសាក្សី គឺគ្មានករណីយកិច្ចចូលខ្លួនទៅតុលាការដែលទទួលបណ្ដឹង ឬក៏មានមូលហេតុត្រឹមត្រូវដែលមិនអាចចូលខ្លួនទៅតុលាការបាន ឬការចូលខ្លួនរបស់សាក្សីបណ្ដាលឱ្យមានការចំណាយទៅលើពេលវេលាមិនសមរម្យ និងគូភាគីពុំមានការតវ៉ា។ ការស៊ើបសួររកឱ្យឃើញពីមូលហេតុនៃការលែងលះ និងថ្លឹងថ្លែងពីកំហុសរបស់ភាគី គឺជាចំណុចគន្លឹះដ៏ចម្បងក្នុងការវិនិច្ឆ័យរកខុសត្រូវរបស់តុលាការ។ ដូច្នេះហើយ ទើបចៅក្រមស៊ើបសួរមែងតែងតែយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើបញ្ហានេះ ពីព្រោះដើម្បីបញ្ចៀសឱ្យបាននូវការបែងចែកដោយអយុត្តិធម៌ដូចជា ភាគីដែលបានប្រព្រឹត្តិកំហុសច្រើនបែរជាទទួលបាននូវទ្រព្យសម្បត្តិ ឬកូនច្រើនជាងភាគីដែលមិនបានប្រព្រឹត្តិកំហុសទៅវិញ។ សរុបមកដំណាក់កាលនៃការស៊ើបសួរតាមរយៈនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការទាញហេតុផលដោយផ្ទាល់មាត់ ពិតជាអាចឱ្យតុលាការកំណត់បានរវាងភាពត្រឹមត្រូវ និងកំហុសដែលជួយកាត់បន្ថយភាពស្មុគស្មាញពេលបើកសវនាការ។ ហើយសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់នេះ គឺមិនធ្វើជាសារធាណៈឡើយ។ ប៉ុន្តែតុលាការ ក៏អាចធ្វើជាសាធារណៈ ឬអាចអនុញ្ញាតឱ្យជនណាដែលតុលាការយល់ឃើញថាសមរម្យក្នុងការចូលស្ដាប់ជាអ្នកសង្កេតការណ៍បានដែរ។

### ៣.១.៦. ការសម្រេចសេចក្ដី

រឿងក្ដីលែងលះដោយគ្មានការព្រមព្រៀងឈានមកដល់នីតិវិធីចុងក្រោយបង្អស់ គឺជាការចេញនូវសាលក្រមសម្រេចលើបណ្ដឹងទាមទារលែងលះ។ អនុលោមតាមស្មារតីនៃក្រមនីតិវិធីរដ្ឋប្បវេណី និងច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលបានបញ្ញត្តិថា ការសម្រេចសេចក្ដីលើបណ្ដឹងលែងលះ គឺត្រូវសម្រេចដោយការចេញសាលក្រមពីតុលាការ។

#### ៣.១.៦.១. ការចេញសាលក្រមលែងលះ

ក្នុងករណីដែលចៅក្រមយល់ឃើញថា ការព្រមព្រៀងលែងកើតចេញពីឆន្ទៈពិតប្រាកដរបស់គូភាគីដោយគ្មានវិការៈក្នុងការបង្ហាញឆន្ទៈនោះតុលាការនឹងសម្រេចឱ្យគូភាគីលែងលះ។[៧១] ផ្ទុយទៅវិញបើតុលាការយល់ឃើញថា ភាគីទាំងសងខាងមិនមានបំណងពិតប្រាកដក្នុងការផ្ដាច់ចំណងអាពាហ៍ពិពាហ៍ទេ តួយ៉ាងដូចជាការលែងលះក្លែងក្លាយជាអាទិ៍ តុលាការនឹងមិនអនុញ្ញាតឱ្យគូភាគីលែងលះគ្នាឡើយ។[៧២] ក្នុងករណីដែលតុលាការសម្រេចឱ្យគូភាគីលែងលះគ្នានោះ តុលាការត្រូវសម្រេចសេចក្ដីលើពាក្យសុំនោះដោយដីកាសម្រេច។ ដីកាសម្រេចឱ្យលែងលះតាមការព្រមព្រៀងត្រូវធ្វើជាលាយលក្ខណ៍អក្សរត្រូវមានសំអាងហេតុ និងសរសេរ

[៧១] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៧៩ កថាខណ្ឌទី១។
[៧២] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៧៩ កថាខណ្ឌទី២ និងកថាខណ្ឌទី៣។

សេចក្តីសម្រេចបញ្ចប់ហើយចៅក្រមត្រូវចុះហត្ថលេខាលើសេចក្តីសម្រេចនោះផងដែរ។[៧៣] ដីកាសម្រេចនេះអាចប្តឹងជំទាស់បានតាមបញ្ញត្តិនៃមាត្រា៣៩ នៃច្បាប់ស្តីពីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនបណ្តឹង ហើយដីកាសម្រេចនេះមានអានុភាពអនុវត្តដោយបង្ខំ។[៧៤]

ក្រៅពីការសម្រេចអំពីការលែងលះ ចៅក្រមនឹងធ្វើការពិចារណាទៅលើចំណុចផ្សេងទៀតនៃខ្លឹមសារនៃការទាមទារដែលបានសរសេរនៅក្នុងពាក្យសុំផងដែរ នៅក្នុងករណីមានការទាមទារផ្សេងទៀតដូចជា ការទាមទារឱ្យបែងចែកសិទ្ធិអំណាចមេបាការទទួលបន្ទុកសោហ៊ុយចំណាយ ដើម្បីចិញ្ចឹមបីបាច់ថែរក្សាកូន ការទាមទារឱ្យបែងចែកទ្រព្យជាអាទិ៍ តុលាការនឹងធ្វើការសម្រេចអំពីការទាមទារទាំងនោះ នៅផ្នែកសេចក្តីសម្រេចបញ្ចប់នៃដីកាសម្រេច។ ច្បាប់បានអនុញ្ញាតឱ្យភាគីប្តីប្រពន្ធ ដែលលែងលះគ្នាអាចធ្វើការពិភាក្សាគ្នាអំពីអ្នកមានអំណាចមេបាដោយកំណត់យកឪពុក ឬម្តាយណាម្ខាងតាមការពិភាក្សារបស់ឪពុកម្តាយ[៧៥] និងអាចកំណត់អំពីរបៀបចូលជួបប្រាស្រ័យទាក់ទងជាមួយកូន និងសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុក ដើម្បីគ្រប់គ្រងចិញ្ចឹមថែរក្សាកូន។[៧៦] ដោយឡែកនៅក្នុងរឿងលែងលះដោយការព្រមព្រៀងគូភាគីតែងតែព្រមព្រៀងគ្នាជាស្រេចមិនមានអ្វីដែលឱ្យតុលាការពិបាកសម្រេចឡើយ។ ការព្រមព្រៀងនេះ គឺស្ថិតនៅលើឆន្ទៈព្រមព្រៀងរបស់គូភាគីមិនថាភាគីម្ខាងណាបានតិច ឬភាគីម្ខាងបានច្រើនជាងទេ។ ក្នុងករណីនេះ ទោះបីជាទ្រព្យសម្បត្តិនោះជាទ្រព្យសម្បត្តិដោយឡែកក៏ដោយទ្រព្យសម្បត្តិរួមក៏ដោយ ពោលគឺឱ្យតែគូភាគីសុខចិត្តព្រមព្រៀងដោយមិនមានការបង្ខិតបង្ខំ។ ការបែងចែកនេះរួមបញ្ចូលទាំងទ្រព្យសកម្ម និងទ្រព្យអកម្មផងដែរ។

### ៣.១.៦.២. ទម្រង់នៃសាលក្រមនៃការលែងលះ

នៅពេលដែលខ្លឹមសារនៃសាលក្រមត្រូវបានបង្កើតឡើងខ្លឹមសារដែលតុលាការសម្រេចត្រូវសរសេរនៅក្នុងលិខិតសាលក្រមដែលមានទម្រង់ដូចខាងក្រោម៖[៧៧]

- តុលាការ
- ថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

[៧៣] ច្បាប់ស្តីពី នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០, មាត្រា៣៥។

[៧៤] ច្បាប់ស្តីពី នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០ មាត្រា៣៨។

[៧៥] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា១០៣៧ កថាខណ្ឌទី១។

[៧៦] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា១០៤០ កថាខណ្ឌទី២។

[៧៧] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា១៨៩។

- ឈ្មោះ និងអាសយដ្ឋានរបស់ភាគី ហើយនឹងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់
- អង្គហេតុ និងចំណុចវិវាទត្រូវសរសេរខ្លឹមសារសំខាន់ៗ ដោយផ្អែកលើសេចក្តីថ្លែងការណ៍របស់ភាគី
- នៅក្នុងលិខិតសាលក្រមត្រូវមានចុះហត្ថលេខារបស់ចៅក្រម ដែលបានចេញសាលក្រមនោះ។

ក្រៅពីចំណុចចាំបាច់សរសេរក្នុងលិខិតសាលក្រម ដែលបានរៀបរាប់រួចមកដូចខាងលើនេះ តុលាការត្រូវសរសេរអំពីចំណុចផ្សេងទៀតដូចជា លេខសំណុំរឿងប្រភេទនៃសាលក្រមជាដើម។ បើមិនបានសរសេរចំណុចចាំបាច់ណាមួយនាំឱ្យខុសពីទម្រង់សាលក្រម។[៧៨]

### ៣.១.៦.៣. ការប្រកាសសាលក្រម

បន្ទាប់ពីបានធ្វើលិខិតសាលក្រមតុលាការត្រូវធ្វើការប្រកាសសាលក្រម។ សាលក្រមមានអានុភាពដោយការប្រកាស ។[៧៩] ការប្រកាសសាលក្រមត្រូវធ្វើឡើងនៅក្នុងអំឡុងពេល ១(មួយ)ខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់នូវការទាញហេតុផលដោយផ្ទាល់មាត់។[៨០] ការទាញហេតុផលដោយផ្ទាល់មាត់នៅក្នុងរឿងលែងលះនេះ គឺមិនត្រូវធ្វើឡើងជាសាធារណៈបានឡើយ ការប្រកាសសាលក្រមនេះ គឺត្រូវធ្វើឡើងជាអសាធារណៈ។[៨១]

### ៣.១.៦.៤. ការចូលជាស្ថាពរនៃសាលក្រម

ដីកាសម្រេចនឹងមិនត្រូវចូលជាស្ថាពរទេ កាលណាមិនទាន់ផុតរយៈពេលសម្រាប់ការប្តឹងជំទាស់ ហើយដីកាសម្រេចមិនត្រូវមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរ គឺមានន័យថាបន្ទាប់ពីទទួលការជូនដំណឹងអំពីដីកាសម្រេចក្នុងរយៈពេល ២(ពីរ)សប្តាហ៍ ប្រសិនបើគ្មានបណ្តឹងឧបាស្រ័យណាមួយលើកឡើងទេ ដីកាសម្រេចលែងលះដោយការព្រមព្រៀងនឹងចូលជាស្ថាពរ។[៨២]

## ៣.២. អានុភាពនៃការលែងលះដោយគ្មានការព្រមព្រៀង

នៅពេលដែលសាលក្រមលែងលះចូលជាស្ថាពរហើយនាំឱ្យសេចក្តីសម្រេចនោះបង្កើតអានុភាពដល់ភាគីដែលសម្រេចលែងលះនោះ។ អានុភាពនៃការលែងលះមានដូចជា ការកាត់ផ្តាច់ទំនាក់ទំនងគតិយុត្ត និងសិទ្ធិ និងកាតព្វកិច្ចដែលបន្សល់ក្រោយការលែងលះ។

[៧៨] សេចក្តីកំណត់ ចំពោះមាត្រានីមួយៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០០៧, គន្លឹទី២, ទំព័រទី១៧៦។

[៧៩] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា១៨៦។

[៨០] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា១៨៧ កថាខណ្ឌទី១។

[៨១] ច្បាប់ស្តីពី នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០, មាត្រា១៦។

[៨២] ច្បាប់ស្តីពី នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០, មាត្រា៤០។

**៣.២.១. ការកាត់ផ្តាច់ទំនាក់ទំនងគតិយុត្ត**

ចំពោះការលែងលះដោយគ្មានការព្រមព្រៀងនេះ ក៏មិនខុសពីការលែងលះដោយការព្រមព្រៀងដែរ នៅពេលដែលសាលក្រមលែងលះចូលជាស្ថាពរ នោះនឹងធ្វើឱ្យមានការកាត់ផ្តាច់ទំនាក់ទំនងគតិយុត្ត ហើយចំពោះការកាត់ផ្តាច់ទំនាក់ទំនងទាំងនោះរួមមាន ការកាត់ផ្តាច់ចំណងគតិយុត្តរវាងសហព័ទ្ធ និងព្រមទាំងការកាត់ផ្តាច់ទំនាក់ញាតិពន្ធ។

**៣.២.២. សិទ្ធិ និងកាតព្វកិច្ចដែលបន្សល់ក្រោយការលែងលះ**

បើទោះបីជា ចំណងអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់ដោយការលែងលះក៏ដោយក៏ប៉ុន្តែអានុភាពនៃការលែងលះបានបន្សល់ទុកនូវសិទ្ធិ និងកាតព្វកិច្ចដល់គូភាគីដដែល។

**៣.២.២.១. សិទ្ធិដែលបន្សល់ទុកក្រោយការលែងលះ**

សិទ្ធិដែលបន្សល់ទុកក្រោយការលែងលះរួមមាន សិទ្ធិទទួលបានអត្តាធីនភាព សិទ្ធិក្នុងការប្រើប្រាស់នាមត្រកូល សិទ្ធិលើអំណាចមេបា សិទ្ធិលើទ្រព្យសម្បត្តិ និងសិទ្ធិក្នុងការបង្កើតអាពាហ៍ពិពាហ៍ថ្មី។ នៅក្នុងរឿងលែងលះដោយគ្មានការព្រមព្រៀង ការបែងចែកសិទ្ធិជាទូទៅតុលាការនឹងបែងចែកតាមឆន្ទៈព្រមព្រៀងរបស់ភាគី ក៏ប៉ុន្តែប្រសិនបើសិទ្ធិទាំងនោះភាគីមិនបានបែងចែកទេ ឬភាគីមិនអាចពិភាក្សាគ្នាបានជោគជ័យទៅលើការបែងចែកសិទ្ធិ នោះតុលាការនឹងធ្វើការបែងចែកសិទ្ធិទាំងនោះទៅឱ្យភាគីតាមមូលដ្ឋានច្បាប់។ យ៉ាងណាមិញ ចំពោះសិទ្ធិលើអំណាចមេបា និងសិទ្ធិលើទ្រព្យសម្បត្តិក្នុងករណីដែលភាគីមិនអាចធ្វើការពិភាក្សាគ្នាបាន ឬមិនបានធ្វើការទាមទារទេ តុលាការនឹងធ្វើការសម្រេចទៅការកំណត់របស់ច្បាប់។ ដោយឡែក ចំពោះសិទ្ធិនូវក្នុងការប្រើប្រាស់នាមត្រកូល នៅក្រោយការលែងលះចំពោះការលែងលះដោយគ្មានការព្រមព្រៀង ក៏មិនខុសគ្នាពីការលែងលះដោយការព្រមព្រៀងដែរ គឺអាស្រ័យទៅលើភាគី ដោយភាគីដែលបានប្រើប្រាស់នាមត្រកូលរបស់សហព័ទ្ធអាចបន្តប្រើប្រាស់នាមត្រកូលដែលបានផ្លាស់ប្តូរនៅក្រោយរៀបអាពាហ៍ពិពាហ៍នោះដដែល ឬអាចផ្លាស់ប្តូរនាមត្រកូលថ្មីនោះទៅនាមត្រកូលនៅមុនពេលរៀបអាពាហ៍ពិពាហ៍វិញក៏បាននៅពេលលែងលះគ្នា។

**ក. សិទ្ធិលើអំណាចមេបា**

នៅក្រោយការលែងលះ តុលាការនឹងសម្រេចអំពីអំណាចមេបាទៅលើកូនឱ្យភាគីណាម្ខាង ជាអ្នកមានអំណាចមេបាអាចជាឪពុក ឬម្តាយ។ ការប្រគល់អំណាចមេបា គឺជាការប្រគល់សិទ្ធិគ្រប់គ្រងឱ្យចិញ្ចឹមបីបាច់ថែរក្សា អប់រំកូនទៅភាគីណាមួយក្រោយពីបានលែងលះគ្នា។ នៅក្នុងការលែងលះដោយគ្មានព្រមព្រៀង ភាគីអាចធ្វើការពិភាក្សាអំពីការបែងចែកអំណាចមេបាបាននៅពេលលែងលះ។ ផ្ទុយទៅវិញ ប្រសិនបើឪពុក និងម្តាយពុំមានការព្រមព្រៀងគ្នាសម្រេចបែងចែកអំណាចមេបាទេ ភាគីត្រូវទាមទារអំណាចមេបានេះតាមរយៈ

ការទាមទារបន្ទាប់បន្សំនៅក្នុងបណ្តឹងលែងលះ ហើយទុកឱ្យតុលាការធ្វើការសម្រេចអំពីអ្នកដែលមានអំណាចមេបាចំពោះកូន។ តុលាការនឹងសម្រេចឱ្យភាគីមានអំណាចមេបា ដោយពិចារណាលើផលប្រយោជន៍របស់កូននោះ។[៩៣] ប៉ុន្តែប្រសិនបើកូនមានសមត្ថភាពគ្រប់គ្រាន់នៅក្នុងការយល់ដឹង និងមានការសម្រេចចិត្តផ្ទាល់ខ្លួនសមស្របក្នុងការសម្រេចចិត្ត តុលាការនឹងធ្វើការសម្រេចតាមឆន្ទៈរបស់កូន។

បន្ថែមពីនេះទៀត ចំពោះការលែងលះដោយការគ្មានការព្រមព្រៀងក៏មិនខុសពីការលែងលះដោយការព្រមព្រៀងដែរ ឪពុក ឬម្តាយដែលពុំទទួលបានអំណាចមេបាលើកូនតាមការសម្រេចរបស់តុលាការក្រោយការលែងលះ អាចធ្វើការពិភាក្សាអំពីសិទ្ធិក្នុងការចូលជួបប្រាស្រ័យទាក់ទងគ្នាជាមួយកូន និងករណីយកិច្ចលើសោហ៊ុយចាំបាច់សម្រាប់កូនពីភាគីដែលមិនមានអំណាចមេបា។[៩៤] ប៉ុន្តែប្រសិនការពិភាក្សាអំពីការកំណត់វិធីនៃការណាត់ជួបកូន និងករណីយកិច្ចលើសោហ៊ុយចាំបាច់កូនពុំបានលទ្ធផលសម្រេចទេនោះតុលាការត្រូវសម្រេចកំណត់អំពីវិធីនៃការចូលជួប និងករណីយកិច្ចទាំងនោះ។[៩៥] ដូច្នេះការលែងលះមានអានុភាពត្រឹមតែកាត់ផ្តាច់ទំនាក់ទំនងរវាងសហព័ទ្ធប៉ុណ្ណោះ ក៏ប៉ុន្តែការលែងលះមិនបានកាត់ផ្តាច់ទំនាក់ទំនងរវាងឪពុក ឬម្តាយជាមួយនឹងកូនៗទេ។ អានុភាពនៃការលែងលះនៅតែផ្តល់សិទ្ធិអំណាចមេបាដល់ភាគីឪពុក ឬម្តាយតាមឆន្ទៈតែភាគីបានព្រមព្រៀងគ្នា ឬតាមការឆន្ទៈរបស់កូន ឬតាមការសម្រេចដោយតុលាការ។ បញ្ជាក់ផងដែរថា នៅពេលដែលតុលាការធ្វើការដោះស្រាយទៅលើបណ្តឹងលែងលះ ទោះបីជាភាគីនៃបណ្តឹងលែងលះនេះ មិនបានទាមទារអំណាចមេបាទេ វិធីចូលជួបប្រាស្រ័យទាក់ទងកូន និងបន្ទុកសោហ៊ុយចាំបាច់គ្រប់គ្រងថែរក្សាកូន ហើយនៅក្នុងបណ្តឹងលែងលះក៏ដោយក៏តុលាការនៅតែមានសិទ្ធិក្នុងការសម្រេចដោយឆន្ទានុសិទ្ធិផងដែរ។[៩៦]

**ខ. សិទ្ធិលើទ្រព្យសម្បត្តិ**

ពាក់ព័ន្ធនឹងសិទ្ធិលើទ្រព្យសម្បត្តិនេះ ភាគីក៏មានសិទ្ធិក្នុងការពិភាក្សាគ្នាលើការបែងចែកទ្រព្យ ដូចការពិភាក្សាលើការបែងចែកអំណាចមេបាដែរ។ ក្នុងករណីដែលភាគីមានការព្រមព្រៀងគ្នា លើការបែងចែកទ្រព្យនោះតុលាការនឹងសម្រេចទៅតាមឆន្ទៈរបស់ភាគី។ ប៉ុន្តែផ្ទុយមកវិញ ប្រសិនបើភាគីដែលលែងលះមិនអាចធ្វើការពិភាក្សាគ្នាបានសម្រេចដល់ការបែងចែកទេ ឬភាគីមិនបានធ្វើការទាមទារឱ្យមានការបែងចែកទ្រព្យសម្បត្តិទេ នាំឱ្យការបែងចែកនេះនឹងត្រូវបានសម្រេចដោយតុលាការ។ យោងតាមមាត្រា៩៨០ នៃក្រមរដ្ឋប្បវេណីឆ្នាំ

[៩៣] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧,មាត្រា១០៣៧។

[៩៤] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧,មាត្រា១០៤០ កថាខណ្ឌទី២ និងកថាខណ្ឌទី៣។

[៩៥] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧,មាត្រា១០៤០ កថាខណ្ឌទី៤។

[៩៦] ច្បាប់ស្តីពី នីតិវិធីបណ្តឹងទាក់ទង និងឋានៈបុគ្គល, នស/រកម/០៦១០/០០៨, ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១០, មាត្រា២២។

២០០៧ បានផ្តល់អំណាចដល់តុលាការ ដើម្បីសម្រេចបែងចែកទ្រព្យសម្បត្តិជំនួសការព្រមព្រៀង គឺតាមវិធី ០៣ យ៉ាងនោះគឺ៖

- **សហព័ទ្ធនីមួយៗត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែក៖** ទ្រព្យសម្បត្តិដោយឡែកមានដូចជា៖[៨៧]
  - ទ្រព្យសម្បត្តិដែលសហព័ទ្ធមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍។
  - ទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។
  - ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដោយឡែក សហព័ទ្ធនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍។
- **មានសិទ្ធិទទួលយកពាក់កណ្តាលនៃទ្រព្យសម្បត្តិរួម៖** បន្ថែមពីលើនេះទៀត ទ្រព្យសម្បត្តិដោយឡែកនេះ សហព័ទ្ធនីមួយៗមានសិទ្ធិទទួលយក១ភាគ២ នៃទ្រព្យសម្បត្តិរួមដែលសហព័ទ្ធបានរកស៊ីជាមួយគ្នា។
- **ការបែងចែកទ្រព្យសម្បត្តិរួមដោយករណីពិសេស៖** នៅក្នុងករណីពិសេស និងមានការទាមទាររបស់ប្តី ឬប្រពន្ធណាម្ខាង តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួម ដោយត្រូវបានពិចារណាទៅលើស្ថានភាពផ្សេងៗដូចជាទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬការបង្កើនទ្រព្យក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពនៃការរស់នៅ នៅក្នុងពេលដែលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្ត និងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និងផលប្រយោជន៍របស់កូនជាអាទិ៍។ ការងារគេហកិច្ច ឬការងារមេផ្ទះ ក៏ត្រូវចាត់ថាមានតម្លៃស្មើនឹងការងារក្រៅផ្ទះដែរ។[៨៨]

### ៣.២.២.២. កាតព្វកិច្ចដែលបន្សល់ទុកក្រោយការលែងលះ

ក្រៅពីសិទ្ធិដូចដែលបានរៀបរាប់ខាងលើ ក្រោយការលែងលះក៏បន្សល់ទុកនូវកាតព្វកិច្ចមួយចំនួនផងដែរ ហើយកាតព្វកិច្ចដែលបន្សល់ទុកក្រោយការលែងលះដោយការគ្មានការព្រមព្រៀង មានលក្ខណៈខុសពីការលែងលះដោយការព្រមព្រៀងបន្តិចត្រង់ថាបន្ថែមពីការបញ្ចប់ករណីយកិច្ចសហព័ទ្ធ និងកាតព្វកិច្ចចំពោះតតិយជន បន្ទាប់ពីការលែងលះក៏អាចបន្សល់ទុកនូវកាតព្វកិច្ចសងជម្ងឺចិត្ត ក៏ដូចជាកាតព្វកិច្ចបង់អាហារកាតព្វកិច្ចផងដែរ។ ចំពោះការបញ្ចប់ករណីយកិច្ចសហព័ទ្ធ និងករណីយកិច្ចចំពោះតតិយជន មិន

[៨៧] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៧២។

[៨៨] រដ្ឋធម្មនុញ្ញ, ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣,មាត្រា៣៦។

ខុសពីករណីយកិច្ចនៅក្នុងការលែងលះដោយការព្រមព្រៀងដែរ នៅក្រោយការលែងលះ ករណីយកិច្ចសហព័ទ្ធ ដែលធ្លាប់មានពីមុនក៏ត្រូវបញ្ចប់ដូចគ្នា ប៉ុន្តែទោះបីជាចំណងអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់ក៏ដោយក៏ភាគីទាំងពីរនៅតែត្រូវមានកាតព្វកិច្ចទទួលខុសត្រូវចំពោះតតិយជន ដែលជាម្ចាស់បំណុលលើបំណុលទាំងឡាយណាដែលបានជំពាក់នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ជាមួយគ្នា ហើយក្នុងករណីបំណុលនោះជាបំណុលដោយឡែកនោះភាគីម្ខាងៗត្រូវទទួលខុសត្រូវលើបំណុលនោះរៀងៗខ្លួន។ ។

**ក. ភាគព្វកិច្ចសងជំងឺចិត្តអាចកើតមាន**

សំណងនៃការខូចខាត ដោយផ្អែកលើអំពើអនីត្យានុកូល ត្រូវបានទទួលស្គាល់ក្នុងករណីលែងលះនិងអាចទាមទារនៅក្នុងបណ្តឹងលែងលះបាន។[៥៩] ក្នុងករណីលែងលះភាគីដែលគ្មានកំហុស ហើយត្រូវបានភាគីម្ខាងទៀតបំពាន ភាគីដែលទទួលរងនូវការបំពានអាចទាមទារសំណងនៃការខូចខាតបាន។

**ខ. ភាគព្វកិច្ចបង់អាហារកាតព្វកិច្ច**

ការទាមទារអាហារកាត្វកិច្ចក្នុងករណីលែងលះពុំមានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ទេ ប៉ុន្តែគឺមានបញ្ញត្តិនៃមាត្រា៧៦ នៃច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៧ បានទទួលស្គាល់ការទាមទារអាហារកាតព្វកិច្ច ហើយបញ្ញត្តិនេះនៅមានអានុភាពអនុវត្តនៅឡើយ បើផ្អែកតាមរយៈមាត្រា៧៨ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។ អាហារកាតព្វកិច្ច ដែលតម្រូវឱ្យបុគ្គលណាម្នាក់ទៀត គឺសំដៅដល់កិច្ចដែលត្រូវបំពេញតាមច្បាប់ ឬតាមសេចក្តីសម្រេចរបស់តុលាការម្នាក់ ឬច្រើននាក់ត្រូវបង់ប្រាក់ ឬទ្រព្យដើម្បីទៅផ្គត់ផ្គង់ជីវភាពរស់នៅរបស់បុគ្គលផ្សេងទៀត ដែលបុគ្គលនោះមានទំនាក់ទំនងញាតិនឹងគ្នា។[៦០] អាហារកាតព្វកិច្ចនៅក្នុងការលែងលះ ភាគីអាចធ្វើការពិភាក្សាព្រមព្រៀងគ្នាលើកាតព្វកិច្ចនេះបានសម្រេចទេ ក៏ប៉ុន្តែប្រសិនបើភាគីមិនអាចពិភាក្សាលើការបែងចែកកាតព្វកិច្ចនេះ ភាគីអាចដាក់ជាចំណុចទាមទារបន្ទាប់បន្សំនៅក្នុងបណ្តឹងលែងលះ ហើយឱ្យតុលាការធ្វើការសម្រេចឱ្យបាន។[៦១] ការទាមទារអាហារកាតព្វកិច្ចត្រូវបានទទួលស្គាល់បានលុះត្រាតែភាគីគ្មានកំហុស ហើយមានការខ្វះខាតនៅក្នុងជីវភាពរស់នៅអាចទាមទារអាហារកាតព្វកិច្ចពីភាគីម្ខាងទៀតបាន។

[៥៩] ច្បាប់ស្តីពី នីតិវិធីបណ្តឹងទាក់ទង និងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១០,មាត្រា១១។

[៦០] សន្ធានុក្រម នៃក្រមរដ្ឋប្បវេណី, លេខ២០២។

[៦១] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា១១៤២។

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវលើសារណាមួយនេះនៅក្នុងទិដ្ឋភាពច្បាប់ និងទិដ្ឋភាពជាក់ស្ដែងនៅក្នុងសង្គម រួមទាំងដំណាក់កាលនៃនីតិវិធីនីមួយៗនៃប្រធានបទ "**ការលែងលះ**" រួចមក ក្រុមនាងខ្ញុំអាចយល់ដឹង និងមានចំណេះដឹងបន្ថែមអំពីលែងលះបានច្រើនជាងមុន។ ការលែងលះ គឺជាកត្តាមួយដែលមនុស្សក្នុងសង្គមតែងតែជួបប្រទះហើយជាបញ្ហាក្នុងគ្រួសារ ដែលធ្វើឱ្យភាគីជាសហព័ទ្ធត្រូវប្រឈមនឹងគុណវិបត្តិ និងមានភាពស្មុគស្មាញ និងបញ្ហាជាច្រើន។ ដោយឥទ្ធិពលនៃការលែងលះនេះធ្វើឱ្យប៉ះពាល់ទៅសង្គមជាតិ ព្រោះតែមិនចុះសម្រុងជាមួយគ្នារវាងប្ដីប្រពន្ធ។ ម្យ៉ាងវិញទៀត ក៏ព្រោះតែការលែងលះធ្វើឱ្យប្ដីប្រពន្ធមានការខាតបង់នូវថវិកា និងចំណាយពេលវេលាជាដើម ដែលជាហេតុអវិជ្ជមានមួយដែលធ្វើឱ្យមានការរាំងដំណើរការនៃការងារ និងព្រមទាំងវឌ្ឍនភាពក្នុងគ្រួសារ។

ចំពោះកូន គឺអាចមានភាពប៉ះពាល់ទៅលើផ្នែកស្មារតី និងផ្នែកសម្ភារៈជាដើម។ ដោយហេតុថា ឪពុកម្ដាយមិនមានពេលវេលាគ្រប់គ្រាន់ក្នុងការមើលថែ ចំណាយពេលវេលា អប់រំប្រៀនប្រដៅដល់កូនៗ។ ក្នុងពេលនោះវាអាចធ្វើឱ្យកូនៗមានអារម្មណ៍មួយថា ខ្វះភាពកក់ក្ដៅពីឪពុកម្ដាយ ពោលគឺបាត់បង់ភាពកក់ក្ដៅ មិនទទួលបាននូវការអប់រំ ប្រៀនប្រដៅ អាចធ្វើឱ្យកូនមិនអាចរៀន និងអាចឱ្យកូនៗរបស់សហព័ទ្ធធ្វើរឿងអ្វីដែលប្រាសចាកពីសង្គម។ ហេតុនេះហើយភាពកក់ក្ដៅពីឪពុកម្ដាយ គឺមានសំខាន់ណាស់សម្រាប់កូនៗដែល ព្រោះវាគឺជាកត្តាមួយនៃកម្លាំងចិត្តរបស់កូនៗ។

ការលែងលះបានបន្សល់ទុកនូវផលវិបាកដល់គ្រួសារ និងកូនជាច្រើនផង តែការលែងលះនេះធ្វើឱ្យភាគីសហព័ទ្ធរួចផុតពីចំណងអាពាហ៍ពិពាហ៍ ដែលមិនចុះសម្រុងគ្នាធ្វើឱ្យមានការកាត់ផ្ដាច់នូវអាពាហ៍ពិពាហ៍ដែលមានតែផលវិបត្តិ ទោះបីជានៅតែបន្តនោះអាចនាំឱ្យមានបញ្ហាទៅមុខជាពុំខាតអាចឈានដល់ការប្រើហិង្សា ដែលធ្វើឱ្យប៉ះពាល់ទៅដល់ផ្លូវកាយ និងផ្លូវចិត្ត ឬផ្លូវអារម្មណ៍ ដែលអាចធ្វើជាគំរូអាក្រក់ដល់កូនៗ រួមទាំងសង្គមជាក់ស្ដែង។ ដូចនេះការលែងលះ គឺជាវិធីមួយដែលល្អបំផុតទៅលើភាគីរងគ្រោះ ដែលអាចរកនូវជីវិតថ្មីមួយទៀតភ្លឺស្វាង និងជៀសខ្លួនពីទុក្ខទាំងឡាយដែលធ្លាប់ឆ្លងកាត់ពីមុនមកជាជាង នៅទ្រាំដែលវាអាចធ្វើឱ្យមានការប៉ះពាល់ដល់ផ្លូវកាយ និងផ្លូវចិត្ត។

សរុបសេចក្ដីមក ការរៀបអាពាហ៍ពិពាហ៍មិនអាចធ្វើឡើងតាមតែចំណង់ចិត្តនោះទេ មុនពេលដែលសម្រេចចិត្តថានឹងចាប់ផ្ដើមចំណងអាពាហ៍ពិពាហ៍នោះ យើងគួរគប្បីសិក្សាស្វែងយល់ ពិនិត្យ គិតពិចារណាពីគ្នាឱ្យបានស៊ីជម្រៅជាមុនសិន នៅក្នុងការរើសដៃគូជីវិតមួយដែលច្បាស់លាស់ ព្រោះថាប្រសិនបើយើងរើសដៃគូជីវិតខុសនោះអាចធ្វើឱ្យជួបទុក្ខលំបាកវេទនា ភាពគ្មានសុភមង្គលនៅក្នុងគ្រួសារ ថែមទាំងអាចឈានទៅ

ដល់ការលេងលះ។ ដូចនេះ យើងគួររួមគ្នាជួយកាត់បន្ថយការលេងលះ ដោយគ្រាន់តែចាប់ផ្តើមពីយើងខ្លួនឯងផ្ទាល់។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានសិក្សា និងធ្វើការស្រាវជ្រាវទៅលើសារណាលើប្រធានបទ "**ការលែងលះ**" រួចមក ក្រុមនាងខ្ញុំបានយល់ឃើញថាការលែងលះមានលក្ខណៈស្មុគស្មាញជាខ្លាំង ព្រមទាំងមានគុណវិបត្តិជាច្រើនដែលបន្សល់ទុកក្រោយពេលដែលលែងលះគ្នារួចហើយដូចជា មានការខាតបង់នូវទ្រព្យសម្បត្តិនៅពេលដែលមានការប្តឹងផ្តល់កើតមានឡើង ខាតបង់ពេលវេលា ព្រោះថានៅពេលដែលមានការប្តឹងផ្តល់នោះយើងនិងមានការឡើងចុះតុលាការជាញឹកញាប់ខាតពេលវេលាក្នុងការរកស៊ី ឬមួយក៏ធ្វើអ្វីផ្សេងក្រៅពីនោះទៀត។ បន្ថែមពីនេះទៀតនោះការលែងលះនេះ គឺធ្វើឱ្យកូនៗទទួលរងនូវសម្ពាធផ្លូវចិត្តដល់កូនៗ កូនៗចាប់ផ្តើមខ្វះភាពកក់ក្តៅពីឪពុក ម្តាយ ធ្វើឱ្យផ្លូវចិត្តរបស់កូនៗកាន់តែចុះខ្សោយម្តងបន្តិចៗ។

ដូច្នេះ ដោយសារបានឃើញនូវបញ្ហាមួយចំនួនខាងលើនេះហើយ ដើម្បីដោះស្រាយនិងបញ្ហាដែលកំពុងតែប្រឈមនឹងការកើតមានឡើង នាងខ្ញុំទាំងពីរនាក់សូមគោរពអនុញ្ញាតលើកឡើងនូវមតិយោបល់មួយចំនួនដូចតទៅៈ

- សូមស្នើសុំឱ្យប្រជាពលរដ្ឋគ្រប់រូបដែលបានរៀបអាពាហ៍ពិពាហ៍ គួរគប្បីចេះយោគយល់អត់ឱនឱ្យគ្នាព្រមទាំងអាធ្យាស្រ័យឱ្យគ្នាទៅវិញទៅមក មិនគួរចង់ឈ្នះចង់ចាញ់គ្នានោះឡើយ ត្រូវចេះគិតគូរឱ្យបានវែងឆ្ងាយមុននឹងសម្រេចចិត្តក្នុងការលែងលះគ្នា ព្រោះថាការលែងលះគ្នានេះវានឹងផ្តល់នូវគុណវិបត្តិជាច្រើន វិសេសទៅទៀតនោះ ប៉ះពាល់យ៉ាងខ្លាំងទៅលើកូនៗ។
- សូមឱ្យតុលាការគួរគប្បីមានការត្រួតពិនិត្យឱ្យបានម៉ត់ចត់ និងឱ្យបានច្រើនដងជាងនេះទៅទៀតក្នុងករណីការលែងលះដោយមានការព្រមព្រៀង ដើម្បីជៀសវាងពីការលែងលះដែលមានវិការៈ។
- រាជរដ្ឋាភិបាលគួរគប្បីផ្សព្វផ្សាយច្បាប់ឱ្យបានទូលំទូលាយជាងនេះទៅទៀត ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរទាំងអស់បានយល់ដឹងអំពីការលែងលះ ដូចជានីតិវិធីនៃការលែងលះ អានុភាពរបស់វា ដើម្បីឱ្យពួកគាត់មានភាពងាយស្រួយ ព្រោះថាប្រជាជនមួយចំនួននៅមិនទាន់ដឹងអំពីការលែងលះនៅឡើយទេ ជៀសវាងមានការភាន់ច្រឡំទៅលើអ្វីមួយ។

# ឯកសារយោង

# ឯកសារយោង

## ១. ឯកសារយោងជាលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ ២០០៧
- ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រម, លេខ នស/រកម/០២១ ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦
- ច្បាប់ ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០១១
- ច្បាប់ស្តីពី នីតិវិធីរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម, លេខ នស/រកម/០៧១០/០១៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០
- ច្បាប់ស្តីពី នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម, លេខ នស/ ០៦១០/០០៨ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០
- ច្បាប់ស្តីពី ឯកពន្ធភាព ប្រកាសឱ្យប្រើដោយព្រះរាជក្រម, លេខ នស/រកម/១០០៦/០២៦, ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦
- ច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ, លេខ នស/រកម/១០០៥/ ០៣១, ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៥
- ច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ ដែលប្រកាសឱ្យប្រើតាមក្រឹត្យ, លេខ ៥៦ក្រ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩
- អនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង, លេខ២១ អនក្រ. បក, ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៦
- សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ៣ រៀបរៀងដោយក្រុមការងារគ្រូបង្គោលនៅសាលាភូមិន្ទចៅក្រម, កែសម្រួលលើការបោះពុម្ពលើកទី១, រាជធានីភ្នំពេញ ខែមីនា ឆ្នាំ២០១៧
- សេចក្តីកំណត់ ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០០៧

- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៥៖ គន្ថីទី៧, រៀបរៀងដោយគណកម្មការទទួលបន្ទុកការពារសេចក្តីព្រាងច្បាប់ក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, ភ្នំពេញ ២០១០

## ២. ឯកសារយោងជាសៀវភៅតែងនិពន្ធ

- វចនានុក្រមខ្មែរ សម្តេចសង្ឃរាជ ជួន ណាត
- សន្ធានុក្រមពាក្យច្បាប់ ខ្មែរ~អង់គ្លេស~បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី, រៀបរៀងដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះពុម្ពដោយទីស្តីការគណៈរដ្ឋមន្ត្រី, ឆ្នាំ ២០០៧
- លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រី ចាំង ស៊ីណាត, សៀវភៅជំនួយស្មារតី នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ, បោះពុម្ពលើកទី២ ឆ្នាំ២០២២
- បណ្ឌិត ឥន ឃឿន, សៀវភៅនីតិគ្រួសារ និងអាពាហ៍ពិពាហ៍, ភាគ១ បោះពុម្ពលើកទី២ ឆ្នាំ២០២១
- បណ្ឌិត ឥន ឃឿន, សៀវភៅនីតិគ្រួសារ និងអាពាហ៍ពិពាហ៍, ភាគ២ បោះពុម្ពលើកទី១ ឆ្នាំ២០១៣

## ៣. ឯកសារយោងជាគេហទំព័រ

- គេហទំព័រ ក្រសួងយុត្តិធម៌ https://search.app/HBAkTEquSrTcwywV6
- គេហទំព័រ https://search.app/?link=https%3A%2F%2Fkhmer4eversite.wordpress.com%2Fwp-content%2Fuploads%2F2016%2F06%2Fproject-of-law.pdf&utm_source=igadl%2Cigatpdl%2Csh%2Fx%2Fgs%2Fm2%2F5

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធគតិយុត្ត

**ឧបសម្ព័ន្ធទី១៖** ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧

**ឧបសម្ព័ន្ធទី២៖** ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រម, លេខ នស/រកម/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦

**ឧបសម្ព័ន្ធទី៣៖** ច្បាប់ស្តីពី នីតិវិធីរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម, លេខនស/រកម/០៧១០/០១៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០១០

**ឧបសម្ព័ន្ធទី៤៖** ច្បាប់ស្តីពី នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលប្រកាសឱ្យប្រើដោព្រះរាជក្រម, លេខ នស/០៦១០/០០៨ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០

**ឧបសម្ព័ន្ធទី៥៖** អនុក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង, លេខ២១ អនក្រ.បក, ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៦

## ២. ឧបសម្ព័ន្ធទាក់ទងនឹងការលែងលះដោយមានការព្រមព្រៀង

**ឧបសម្ព័ន្ធទី១៖** គំរូនៃសំបុត្រអាពាហ៍ពិពាហ៍

**ឧបសម្ព័ន្ធទី២៖** គំរូនៃកិច្ចព្រមព្រៀងលែងលះ

**ឧបសម្ព័ន្ធទី៣៖** គំរូនៃលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

**ឧបសម្ព័ន្ធទី៤៖** គំរូនៃពាក្យសុំលែងលះ

**ឧបសម្ព័ន្ធទី៥៖** គំរូនៃដីកាសម្រេចរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង

**ឧបសម្ព័ន្ធទី៦៖** គំរូនៃលិខិតបញ្ជាក់ការចូលជាស្ថាពរនៃដីកាសម្រេច

**ឧបសម្ព័ន្ធទី៧៖** គំរូនៃបង្កាន់ដៃបង់ប្រាក់ថ្លៃដាក់លិខិតបញ្ជាក់ចូលជាស្ថាពរនៃដីកាសម្រេច

## ៣. ឧបសម្ព័ន្ធទាក់ទងនឹងការលែងលះដោយគ្មានការព្រមព្រៀង

**ឧបសម្ព័ន្ធទី១៖** គំរូនៃពាក្យបណ្តឹងលែងលះ

**ឧបសម្ព័ន្ធទី២៖** គំរូនៃបង្កាន់ដៃបង់ថ្លៃពាក្យបណ្តឹង

**ឧបសម្ព័ន្ធទី៣៖** គំរូនៃលិខិតប្រគល់សិទ្ធិអំណាចដោយអាណត្តិ

**ឧបសម្ព័ន្ធទី៤៖** គំរូនៃសាលក្រមលែងលះ

**ឧបសម្ព័ន្ធទី៥៖** គំរូនៃលិខិតចូលជាស្ថាពរនៃសាលក្រម

**ឧបសម្ព័ន្ធទី៦៖** គំរូនៃពាក្យបណ្តឹងឧទ្ធរណ៍

# ឧបសម្ព័ន្ធទី១ គតិយុត្ត

# ច្បាប់ស្តីពីនីតិវិធីនៃការពិន័យស៊ីវិល

# ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល

# និង

# ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែន

# ជាបណ្តឹង

# ព្រមទាំង

# សេចក្តីកំណត់ចំពោះមាត្រានីមួយៗ

រៀបចំដោយ

គណៈកម្មការទទួលបន្ទុកកិច្ចការផ្នែកច្បាប់រដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណីកម្ពុជា

និង

ក្រុមការងារជប៉ុនទទួលបន្ទុករៀបចំសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

ក្រសួងយុត្តិធម៌

ភ្នំពេញ ២០១១

# ព្រះរាជក្រម

នស/រកម/០៧១០/០១៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### មាត្រា ១.- គោលដៅនៃច្បាប់នេះ

ច្បាប់នេះមានគោលដៅបញ្ញត្តនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ។

### មាត្រា ២.- គោលបំណងនៃច្បាប់នេះ

ច្បាប់នេះមានគោលបំណងធានាការអនុវត្តឲ្យបានត្រឹមត្រូវនូវនីតិវិធីក្នុងការដោះស្រាយរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ។

### មាត្រា ៣.- វិសាលភាពនៃច្បាប់នេះ

១- ក្នុងចំណោមចំណុចដែលស្ថិតនៅក្រោមសិទ្ធិអំណាចរបស់តុលាការ ដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ចំពោះចំណុចដែលកំណត់ក្នុងផ្នែកនីមួយៗ នៃតារាងឧបសម្ព័ន្ធ តុលាការត្រូវសម្រេចសេចក្តីតាមបញ្ញត្តិនៃច្បាប់នេះ លើកលែងតែករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ផ្សេង ។

២- ការសម្រេចសេចក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើឡើងដោយដីកាសម្រេច ។

៣- ក្រៅពីករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់នេះ បញ្ញត្តិស្តីពីដីកាសម្រេច ដូចមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ ។

## ជំពូកទី ២
## តុលាការ
## ផ្នែកទី ១
## សមត្ថកិច្ចសាលាជម្រះក្តី

### មាត្រា ៤.- តុលាការដែលមានសមត្ថកិច្ច

១- រឿងក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) ខាងលើនេះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ ។

២- សមត្ថកិច្ចសាលាជម្រះក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវកំណត់ដោយយកពេលដាក់ពាក្យសុំ ។

**មាត្រា ៥.– ការកំណត់តុលាការដែលមានសមត្ថកិច្ច**

១- ក្នុងករណីដែលតុលាការមានសមត្ថកិច្ច មិនអាចអនុវត្តសិទ្ធិសម្រេចសេចក្តីបាន ដោយសារច្បាប់ ឬ ហេតុការណ៍ពិត ឬ ករណីដែលសមត្ថកិច្ចសាលាជម្រះក្តីមិនអាចកំណត់បាន ដោយសារដែនសមត្ថកិច្ចនៃតុលាការមិនពិតប្រាកដ តុលាការកំពូលត្រូវកំណត់តុលាការដែលមានសមត្ថកិច្ច ដោយដីកាសម្រេចតាមពាក្យសុំ ។

២- ចំពោះដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចប្តឹងឧបាស្រ័យបានឡើយ ។

**មាត្រា ៦.– ការចាត់ចែងរឿងក្តីខុសសមត្ថកិច្ច**

១- ប្រសិនបើតុលាការយល់ឃើញថា រឿងក្តីណាមួយមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនទេ តុលាការនេះត្រូវផ្ទេររឿងក្តីនោះទៅតុលាការដែលមានសមត្ថកិច្ច តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិ ។

២- ពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ លើកលែងតែករណីដែលមានការដាក់ពាក្យសុំនៅកាលបរិច្ឆេទ ។ នៅពេលដាក់ពាក្យសុំនេះ ត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់អំពីមូលហេតុនៃពាក្យសុំនោះ ។

**មាត្រា ៧.– សមត្ថកិច្ចជាអាទិភាព និង ការផ្ទេរ**

១- ក្នុងករណីមានតុលាការច្រើនមានសមត្ថកិច្ចលើរឿងក្តីណាមួយ តុលាការដែលទទួលពាក្យសុំមុនគេចំពោះរឿងក្តីនោះ ត្រូវមានសមត្ថកិច្ច ។

២- ក្នុងករណីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើយល់ឃើញថាសមរម្យដើម្បីចាត់ចែងរឿងក្តី តុលាការអាចផ្ទេររឿងក្តីនោះទៅតុលាការផ្សេងដែលមានសមត្ថកិច្ចតាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិបាន ។

៣- ពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ លើកលែងតែករណីដែលមានការដាក់ពាក្យសុំនៅកាលបរិច្ឆេទ។

ROYAUME DU CAMBODGE PALAIS ROYAL

Ksl

អ្នកតំណាងដោយផ្អែកលើការអនុញ្ញាតរបស់តុលាការដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ១៩ (លក្ខណសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ) ខាងលើនេះ ។

**មាត្រា ២១.- ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីសិទ្ធិតំណាងដោយអាណត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី**

បញ្ញត្តិនៃមាត្រា ៥៥ (ករណីដែលសិទ្ធិតំណាងដោយអាណត្តិមិនរលត់) មាត្រា ៥៦ (ហេតុនៃការរលត់នូវសិទ្ធិតំណាងដោយអាណត្តិ) និង មាត្រា ៥៧ (វិធានការក្នុងករណីនៃការខ្វះសិទ្ធិតំណាង) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកតំណាងដោយអាណត្តិ ។

## ជំពូកទី ៤
## ប្រាក់ប្រដាប់ក្តី

**មាត្រា ២២.- បន្ទុកនៃប្រាក់ប្រដាប់ក្តី**

១- ដើម្បីដាក់ពាក្យសុំតាមនីតិវិធីនៃរឿងក្តីដែលកំណត់ក្នុងច្បាប់នេះ ត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល ។

២- បញ្ញត្តិនៃមាត្រា ៦២ (ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ) និង មាត្រា ៦៣ (ប្រាក់ប្រដាប់ក្តីភាគី) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះប្រាក់ប្រដាប់ក្តីក្រៅពីពន្ធដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ។

៣- ប្រាក់ប្រដាប់ក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ គឺជាបន្ទុករបស់អ្នកដាក់ពាក្យសុំ លើកលែងតែក្នុងករណីដែលមានកំណត់ពិសេសអំពីអ្នកទទួលបន្ទុកនោះក្នុងច្បាប់នេះ ។

៤- ចំពោះរឿងក្តីដែលតំណាងអយ្យការបានដាក់ពាក្យសុំ ឬ រឿងក្តីដែលតុលាការបានចាប់ផ្តើមដោយឆន្ទានុសិទ្ធិរបស់ខ្លួន ប្រាក់ប្រដាប់ក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ ជាបន្ទុករបស់រដ្ឋ ។

៥- បញ្ញត្តិនៃកថាខណ្ឌទី ៣ មាត្រា ៦៤ (ភាគដែលត្រូវទទួលបន្ទុក និង ការសងវិញនូវប្រាក់ប្រដាប់ក្តីដែលបានបង់រួចហើយ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានជនច្រើននាក់ដែលត្រូវទទួលបន្ទុកប្រាក់ប្រដាប់ក្តីដោយរួមគ្នា ។

៣- បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣០៥ (ការផ្អាកអានុភាពនៃដីកាសម្រេចដើម) នៃក្រមនីតិវិធីរដ្ឋប្បវេណីត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានបណ្តឹងជំទាស់ ចំពោះដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តី ។

**មាត្រា ២៥.- ការបង់ប្រាក់ប្រដាប់ក្តីជំនួសជាមុន**

ចំពោះប្រាក់ប្រដាប់ក្តីសម្រាប់ការពិនិត្យភស្តុតាង ការកោះហៅ ការជូនដំណឹង និង ការចាត់ចែងចាំបាច់ផ្សេងទៀត ដែលធ្វើឡើងដោយឆន្ទានុសិទ្ធិរបស់តុលាការ រដ្ឋត្រូវបង់ជំនួសជាមុន ប៉ុន្តែចំពោះសកម្មភាពដែលត្រូវការប្រាក់ប្រដាប់ក្តី តុលាការអាចបង្គាប់ឲ្យជនពាក់ព័ន្ធបង់ប្រាក់ប្រដាប់ក្តីនោះជាមុនបាន ។

## ជំពូកទី ៥
## ការវិនិច្ឆ័យ

**មាត្រា ២៦.- របៀបដាក់ពាក្យសុំ និងចំណុចដែលត្រូវសរសេរក្នុងពាក្យសុំ**

១- ពាក្យសុំអាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់បាន លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ឬ ច្បាប់ផ្សេងទៀត ។

២- នៅក្នុងលិខិតនៃពាក្យសុំត្រូវសរសេរបញ្ជាក់នូវចំណុចខាងក្រោមនេះ ៖

ក- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ- ខ្លឹមសារនៃដីកាសម្រេច ឬ សកម្មភាពផ្សេងទៀតរបស់តុលាការដែលអ្នកដាក់ពាក្យសុំទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ ។

៣- ដើម្បីដាក់ពាក្យសុំដោយផ្ទាល់មាត់ អ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្តីថ្លែងការណ៍នូវចំណុចនីមួយៗ ដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ នៅចំពោះមុខក្រឡាបញ្ជី ។ ក្នុងករណីនេះ ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុ និង ចុះហត្ថលេខា ។ កំណត់ហេតុនោះត្រូវបានចាត់ទុកជាលិខិតពាក្យសុំ ។

៤- ក្នុងករណីដែលមានឯកសារជាភស្តុតាង អ្នកដាក់ពាក្យសុំត្រូវភ្ជាប់នូវឯកសារដើម ឬ ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ជាមួយនឹងលិខិតនៃពាក្យសុំ ឬ ត្រូវដាក់ជូនឯកសារទាំងនោះទៅតុលាការនៅពេលដាក់ពាក្យសុំ ។

ROYAUME DU CAMBODGE ★ LE MINISTÈRE DU PALAIS ROYAL ★

**មាត្រា ២៧.- ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ និង ការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ**

១- តុលាការអាចយកអង្គហេតុដែលមិនបានអះអាងដោយអ្នកដាក់ពាក្យសុំ ឬ ដោយភាគីម្ខាងទៀតមកធ្វើជាមូលដ្ឋាននៃដីកាសម្រេចបាន ។

២- ប្រសិនបើយល់ឃើញថាចាំបាច់ តុលាការត្រូវធ្វើការស្រាវជ្រាវអង្គហេតុ និង ធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ ។

**មាត្រា ២៨.- ការទាញហេតុផលដោយផ្ទាល់មាត់ និងការសួរដោយឆន្ទានុសិទ្ធិ**

១- ដើម្បីចេញដីកាសម្រេចអំពីរឿងក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ តុលាការពុំចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ឡើយ ។

២- ក្នុងករណីដែលមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចសួរអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬ ជនផ្សេងទៀតដែលតុលាការយល់ឃើញថាចាំបាច់បាន ។ ក្នុងករណីនេះ តុលាការអាចអនុញ្ញាតឲ្យអ្នកដែលតុលាការយល់ថាសមរម្យ ចូលស្តាប់ជាអ្នកសង្កេតការណ៍បាន ។

**មាត្រា ២៩.- ករណីយកិច្ចបង្ហាញខ្លួនរបស់សាមីខ្លួន**

១- តុលាការអាចកោះហៅអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬ ជនផ្សេងទៀត ដែលតុលាការយល់ឃើញថាចាំបាច់បាន ដោយកំណត់កាលបរិច្ឆេទ ។

២-ក្នុងករណីជនដែលត្រូវបានកោះហៅដោយតុលាការ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនបានបង្ហាញខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវទេ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ១.០០០.០០០ (មួយលាន) រៀល បាន ។

**មាត្រា ៣០.- ការចូលរួមរបស់តំណាងអយ្យការ និង ការជូនដំណឹង**

១- ប្រសិនបើយល់ឃើញថាចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ តុលាការត្រូវជូនដំណឹងទៅតំណាងអយ្យការអំពីរឿងក្តី និង កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ ក្នុងកាលបរិច្ឆេទនៃការសួរ ។

ROYAUME DU CAMBODGE ✦ LE MINISTRE DU PALAIS ROYAL

២- ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ប្រសិនបើអ្នកដាក់ពាក្យសុំ ឬភាគីម្ខាងទៀត ទាមទារឲ្យប្រគល់នូវឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬឯកសារដកស្រង់នៃលិខិតដីកាសម្រេច ឬ ទាមទារឲ្យប្រគល់នូវលិខិតបញ្ជាក់អំពីចំណុចទាក់ទងនឹងរឿងក្តី ក្រឡាបញ្ជីត្រូវប្រគល់ឯកសារ ឬ លិខិតនោះ ។

**មាត្រា ៣៤.- ការអនុវត្តដូចគ្នាតាមក្រមនីតិវិធីរដ្ឋប្បវេណី**

១- បញ្ញត្តិស្តីពីកាលបរិច្ឆេទ អំឡុងពេល វិធីធ្វើសេចក្តីបញ្ជាក់ដំបូង នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីដែលកំណត់ក្នុងច្បាប់នេះ លើកលែងតែមានភាពផ្ទុយគ្នានឹងលក្ខណៈនៃនីតិវិធីនេះ ។

២- បញ្ញត្តិស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ ការសាកសួរសាក្សី ការសាកសួរភាគី កោសលវិច័យ ការត្រួតពិនិត្យ និងភស្តុតាងជាឯកសារ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវអនុវត្តដូចគ្នាផងដែរចំពោះករណីដែលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ នៅក្នុងនីតិវិធីដែលកំណត់ក្នុងច្បាប់នេះ លើកលែងតែមានភាពផ្ទុយគ្នានឹងលក្ខណៈនៃនីតិវិធីនេះ ។

## ជំពូកទី ៦
## ការសម្រេចសេចក្តី

**មាត្រា ៣៥.- វិធីសម្រេចសេចក្តី**

ដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ត្រូវសរសេរសំអាងហេតុ និងសេចក្តីសម្រេចបញ្ចប់ ហើយចៅក្រមត្រូវចុះហត្ថលេខាលើសេចក្តីសម្រេចនេះ ។

**មាត្រា ៣៦.- ការជូនដំណឹងអំពីដីកាសម្រេច**

ដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ ត្រូវជូនដំណឹងទៅជនដែលត្រូវទទួលដីកាសម្រេចនេះ ។ ការជូនដំណឹងអំពីដីកាសម្រេចនេះត្រូវធ្វើឡើងតាមរយៈការបញ្ជូន ឬ ការផ្ញើជូនឯកសារចម្លងយថាភូតនៃដីកាសម្រេចនោះ ។

**មាត្រា ៣៧.- ការចូលជាស្ថាពរ និង ការបង្កើតអានុភាពនៃដីកាសម្រេច**

១- ដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ មិនត្រូវចូលជាស្ថាពរនៅមុនពេលផុតអំឡុងពេលសម្រាប់ការប្តឹងជំទាស់ដែលកំណត់ក្នុងមាត្រា ៤០ (អំឡុងពេលសម្រាប់ប្តឹងជំទាស់) នៃច្បាប់នេះ ។

២- ការចូលជាស្ថាពរនៃដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានបង្អាក់ដោយការប្តឹងជំទាស់ ដែលត្រូវបានធ្វើឡើងនៅក្នុងអំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ១ នោះ ។

៣- ដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរទេ ។

**មាត្រា ៣៨.- អានុភាពអនុវត្តនៃដីកាសម្រេច**

ដីកាសម្រេចបង្គាប់ឲ្យបង់ប្រាក់ ប្រគល់វត្ថុ អនុវត្តករណីយកិច្ចចុះបញ្ជី ឬ ផ្តល់តាវកាលិកផ្សេងទៀតដែលចូលជាស្ថាពរ ត្រូវក្លាយជាលិខិតអនុវត្តដែលកំណត់ក្នុងមាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## ជំពូកទី ៧
## បណ្តឹងឧបាស្រ័យ

**មាត្រា ៣៩.- បណ្តឹងជំទាស់**

១- បុគ្គលទទួលឥទ្ធិពលដែលខូចប្រយោជន៍ដល់សិទ្ធិ ឬ ឋានៈគតិយុត្តរបស់ខ្លួនដោយសារដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ អំពីរឿងក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ អាចប្តឹងជំទាស់ចំពោះដីកាសម្រេចនោះបាន លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ។

២- ក្នុងករណីដែលត្រូវចេញដីកាសម្រេចតាមតែពាក្យសុំប៉ុណ្ណោះ មានតែជនដែលបានដាក់ពាក្យសុំទេ ដែលអាចប្តឹងជំទាស់ចំពោះដីកាសម្រេចលើកចោលពាក្យសុំបាន ។

**មាត្រា ៤០.- អំឡុងពេលសម្រាប់ប្តឹងជំទាស់**

១- ប្រសិនបើជនដែលអាចប្តឹងជំទាស់ បានទទួលនូវការជូនដំណឹងអំពីដីកាសម្រេច បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃបានទទួលការជូនដំណឹងអំពីដីកាសម្រេចនោះ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

២- ប្រសិនបើជនដែលអាចប្តឹងជំទាស់ មិនមែនជាជនដែលត្រូវទទួលនូវការជូនដំណឹងអំពីដីកាសម្រេច ដោយយោងតាមបញ្ញត្តិនៃមាត្រា ៣៦ (ការជូនដំណឹងអំពីដីកាសម្រេច) នៃច្បាប់នេះទេ បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលជនដាក់ពាក្យសុំបានទទួលការជូនដំណឹងអំពីដីកាសម្រេចនោះ ។

៣- ចំពោះរឿងក្តីដែលបានចាប់ផ្តើមឡើងដោយឆន្ទានុសិទ្ធិ អំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ ត្រូវគណនាពីថ្ងៃដែលជនបានទទួលក្រោយគេនូវការជូនដំណឹង បានទទួលដំណឹងនោះ ។

៤- អំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ពុំអាចពន្យារបានឡើយ ។

## មាត្រា ៤១.- ការបំពេញនូវសកម្មភាពប្តឹងជំទាស់ ក្រោយពីអំឡុងពេលសម្រាប់ប្តឹងជំទាស់បានកន្លងផុត

១- ក្នុងករណីដែលជនដែលអាចប្តឹងជំទាស់ មិនបានគោរពតាមអំឡុងពេលសម្រាប់ប្តឹងជំទាស់ ដោយគ្មានកំហុសរបស់ខ្លួន ជននោះអាចប្តឹងជំទាស់បានក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍ ក្រោយពេលមូលហេតុនោះបានរលត់ហើយ ចំពោះជនដែលនៅបរទេសវិញ អំឡុងពេលនោះមានចំនួន ២ (ពីរ) ខែ។

២- អំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំអាចពន្យារបានឡើយ ។

## មាត្រា ៤២.- នីតិវិធីនៃការជំនុំជម្រះលើបណ្តឹងជំទាស់

ក្រៅពីបញ្ញត្តិនៃជំពូកទី ៥ (ការវិនិច្ឆ័យ) នៃច្បាប់នេះ បញ្ញត្តិនៃជំពូកទី ៤ (បណ្តឹងជំទាស់) គន្ថីទី ៣ (បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងជំទាស់ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសនៅក្នុងជំពូកទី ៧ នេះ ។

# ជំពូកទី ៨
# ការចាត់ចែងរក្សាការពារ

## មាត្រា ៤៣.- នីតិវិធីនៃការចាត់ចែងរក្សាការពារ

១-ក្នុងករណីមានពាក្យសុំអំពីរឿងក្តីដែលកំណត់ក្នុងច្បាប់នេះ តុលាការអាចបង្គាប់ឲ្យធ្វើការរឹបអូសជាបណ្តោះអាសន្ន ការចាត់ចែងជាបណ្តោះអាសន្ន ការជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ព្រះរាជក្រម

នស/រកម/០៦១០/០០៩

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

អំពីអត្ថិភាពនៃមាតុភាពពីម្តាយ) នៃក្រមរដ្ឋប្បវេណី ។

ជ- បណ្តឹងទាមទារកាត់កាល់ តាមបញ្ញត្តិនៃមាត្រា១០១៦ (ការកាត់កាល់នៃសុំកូនពេញលេញ) នៃក្រមរដ្ឋប្បវេណី ។

ឈ- បណ្តឹងទាមទារកាត់កាល់ តាមបញ្ញត្តិនៃមាត្រា ១០៣១ (មូលហេតុនៃការកាត់កាល់) នៃក្រមរដ្ឋប្បវេណី។

៣- បណ្តឹងផ្សេងទៀតដែលមានគោលបំណងបង្កើត បញ្ជាក់អត្ថិភាព ឬ នត្ថិភាពនៃទំនាក់ទំនងនឹងឋានៈបុគ្គល។

## ជំពូកទី ២
## ការចូលរួមរបស់តំណាងអយ្យការ

**មាត្រា ៤.-** ការអះអាងអង្គហេតុដោយតំណាងអយ្យការ ជាអាទិ៍

ចំពោះបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ក្នុងករណីដែលតំណាងអយ្យការបានចូលរួមក្នុងនីតិវិធីតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៦ (ការចូលរួមរបស់តំណាងអយ្យការ) នៃក្រមនីតិវិធីរដ្ឋប្បវេណី តំណាងអយ្យការនោះ អាចធ្វើការអះអាងអង្គហេតុ ឬ អាចស្នើសុំឱ្យពិនិត្យភស្តុតាងបាន ។

## ជំពូកទី ៣
## តុលាការ

**មាត្រា ៥.-** សមត្ថកិច្ច

១- បណ្តឹងទាក់ទងនឹងឋានៈបុគ្គលត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់សាលាដំបូងដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ភាគីនៃទំនាក់ទំនងនឹងឋានៈបុគ្គលពាក់ព័ន្ធនឹងបណ្តឹងនោះ ឬ លំនៅឋាននៅពេលដែលភាគីនោះទទួលមរណភាព ។

២- បើលំនៅឋានដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ លំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាមិនពិតប្រាកដទេ សមត្ថកិច្ចសាលាជម្រះក្តីត្រូវកំណត់តាមទីសំណាក់ ។ បើពុំមានទីសំណាក់ ឬ ទីសំណាក់មិនពិតប្រាកដទេ សមត្ថកិច្ចនោះ ត្រូវកំណត់តាមលំនៅឋានចុងក្រោយ ។

៣- ក្នុងករណីមិនអាចកំណត់តុលាការមានសមត្ថកិច្ច តាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ បណ្តឹងទាក់ទងនឹងឋានៈបុគ្គលត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់សាលាដំបូងរាជធានីភ្នំពេញ ។

ROYAUME DU CAMBODGE CABINET DU PALAIS

Kol

# ជំពូកទី ៦
# នីតិវិធីនៃបណ្តឹង

**មាត្រា ១១.-** ការរួមបញ្ចូលការទាមទារដែលពាក់ព័ន្ធ

ការទាមទារពាក់ព័ន្ធនឹងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល និង ការទាមទារពាក់ព័ន្ធនឹងសំណងការខូចខាតដែលកើតមានឡើងដោយអង្គហេតុដែលជាមូលហេតុនៃការទាមទារ ពាក់ព័ន្ធនឹងបណ្តឹងទាក់ទងនឹងឋានៈបុគ្គលនោះ អាចធ្វើដោយបណ្តឹងតែមួយបាន ទោះបីមានបញ្ញត្តិមាត្រា ៧៧ (ការបញ្ចូលការទាមទារច្រើនចំណុចទៅក្នុងបណ្តឹងតែមួយ) នៃក្រមនីតិវិធីរដ្ឋប្បវេណីក៏ដោយ ។

**មាត្រា ១២.-** ការបន្ថែម ឬ ការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង និង បណ្តឹងតប

ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ៤ នៃមាត្រា ៨៤ (ការបន្ថែម ឬ ការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង) កថាខណ្ឌទី ១ នៃមាត្រា ៨៦ (បណ្តឹងតប) និង មាត្រា ២៧៦ (ការដាក់ពាក្យបណ្តឹងតប) នៃក្រមនីតិវិធីរដ្ឋប្បវេណីក៏ដោយ នៅក្នុងនីតិវិធីពាក់ព័ន្ធនឹងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដើមចោទអាចបន្ថែម ឬ ផ្លាស់ប្តូរនូវការទាមទារ ឬ មូលហេតុនៃការទាមទារបាន ហើយចុងចម្លើយអាចប្តឹងតបបានរហូតដល់ពេលចប់ ការទាញហេតុផលដោយផ្ទាល់មាត់នៃការជម្រះក្តីលើកទី ១ ឬ ការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ។

**មាត្រា ១៣.-** បញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីដែលមិនត្រូវយកមកអនុវត្ត

១- មាត្រា ៩៤ (ការលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួនដែលបានដាក់យឺតយ៉ាវមិនត្រូវនឹងពេលសមរម្យ) កថាខណ្ឌទី ១នៃមាត្រា ៩៦ (ការចាត់ទុកថាបានសារភាព) កថាខណ្ឌទី ២ នៃមាត្រា ១៤០ (ការសាកសួរសាមីភាគី) មាត្រា ១៥៣ (អានុភាពនៅក្នុងករណីដែលភាគីមិនអនុវត្តតាមដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ជាអាទិ៍) កថាខណ្ឌទី ៤ នៃមាត្រា ១៥៦ (ការបញ្ជាក់ដោយប្រៀបធៀបអក្សរដែលសរសេរដោយដៃ) មាត្រា ២០០ (សាលក្រមកំបាំងមុខដើមចោទ) កថាខណ្ឌទី ២ នៃមាត្រា ២០១ (សាលក្រមកំបាំងមុខចុងចម្លើយ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រមទាំងផ្នែកទាក់ទងនឹងអង្គហេតុដែលភាគីបានសារភាពចំពោះមុខតុលាការ នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ១២៣ (គោលការណ៍សម្រេចសេចក្តីដោយភស្តុតាង) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយ ចំពោះនីតិវិធីបណ្តឹងនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ។

២- បញ្ញត្តិពីមាត្រា ២២០ (ការផ្សះផ្សាលើបណ្តឹង) ដល់មាត្រា ២២២ (អានុភាពនៃកំណត់ហេតុស្តីពីការសះជា ជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយ ចំពោះកម្មវត្ថុនៃបណ្តឹង នៅក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ។

**មាត្រា ១៤.-** ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ

នៅក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល តុលាការអាចយកអង្គហេតុដែលមិនបានអះអាងដោយភាគីមកធ្វើជាមូលដ្ឋាននៃសាលក្រមបាន ។ ក្នុងករណីនេះ តុលាការត្រូវសួរមតិពីភាគីអំពីអង្គហេតុនោះ ។

**មាត្រា ១៥.-** ការបង្គាប់ឱ្យសាមីភាគីមកបង្ហាញខ្លួន ជាអាទិ៍

១- នៅក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ក្នុងករណីដែលសាកសួរសាមីភាគី តុលាការអាចបង្គាប់ឱ្យភាគីនោះមកបង្ហាញខ្លួនតាមកាលបរិច្ឆេទបាន ។

២- បញ្ញត្តិពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៤ នៃមាត្រា ១៣២ (ករណីយកិច្ចរបស់សាក្សី) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលភាគីដែលត្រូវបានបង្គាប់ឱ្យមកបង្ហាញខ្លួន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនបានបង្ហាញខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ ។

**មាត្រា១៦.-** ការមិនធ្វើជាសាធារណៈនៃការទាញហេតុផលដោយផ្ទាល់មាត់

១- ការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល មិនត្រូវធ្វើជាសាធារណៈឡើយ ។

២- ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏តុលាការអាចធ្វើការទាញហេតុផលដោយផ្ទាល់មាត់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដោយធ្វើជាសាធារណៈ ឬ អាចអនុញ្ញាតឱ្យជនណាដែលតុលាការយល់ឃើញថាសមរម្យ ចូលស្តាប់ជាអ្នកសង្កេតការណ៍បានដែរ ។

**មាត្រា ១៧.-** វិសាលភាពនៃបុគ្គលដែលទទួលនូវអានុភាពនៃសាលក្រម ឬ សាលដីកាស្ថាពរ

១- ទោះបីជាមានបញ្ញត្តិនៃមាត្រា ១៩៨ (វិសាលភាពបុគ្គលដែលត្រូវទទួលអានុភាពរបស់សាលក្រមស្ថាពរ) នៃក្រមនីតិវិធីរដ្ឋប្បវេណីក៏ដោយ ក៏សាលក្រម ឬ សាលដីកាស្ថាពរនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលមានអានុភាពចំពោះតតិយជនដែរ ។

២-ក្នុងករណីដែលមានការទាមទារឱ្យលុបចោលនូវអាពាហ៍ពិពាហ៍ដោយយកមូលហេតុផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៩៤៩ (ការហាមឃាត់មិនឱ្យមានទ្វេពន្ធភាព) នៃក្រមរដ្ឋប្បវេណី ហើយបើការទាមទារនេះត្រូវបានច្រានចោល ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏សាលក្រម ឬ សាលដីកាស្ថាពរដែលច្រានចោលការទាមទារនោះ មានអានុភាពចំពោះសហព័ទ្ធនៃអាពាហ៍ពិពាហ៍មុន លុះត្រាតែសហព័ទ្ធនៃអាពាហ៍ពិពាហ៍មុននោះ បានចូលរួមអន្តរាគមន៍ក្នុងបណ្តឹងដែលពាក់ព័ន្ធនឹងការទាមទារនោះ ដោយយោងតាមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ROYAUME DU CAMBODGE * LE MINISTERE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

Ksl

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : ២១ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង

www.moj.gov.kh
២០១៦

មាតិកា

# មាតិកា

អនុក្រឹត្យលេខ ២១ អនក្រ.បក ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង
នេះមានចំនួន ០៤ជំពូក និង ០៩មាត្រា


| |
|---|
| **ជំពូកទី ១ បទប្បញ្ញត្តិទូទៅ**<br>(មាត្រា១ ដល់ មាត្រា៣) |
| **ជំពូកទី ២ គោលការណ៍**<br>(មាត្រា៤ ដល់ មាត្រា៦) |
| **ជំពូកទី ៣ អន្តរប្បញ្ញត្តិ**<br>(មាត្រា៧) |
| **ជំពូកទី៤ អវសានប្បញ្ញត្តិ**<br>(មាត្រា៨ ដល់ មាត្រា៩) |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៧១...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ស ម្រេ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងពង្រឹងយន្តការគ្រប់គ្រងការងាររដ្ឋបាលរបស់សាលាដំបូង និងអយ្យការអមសាលាដំបូង ដើម្បីធានាគុណភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការផ្តល់សេវា និងបង្កើនជំនឿទុកចិត្តពីប្រជាពលរដ្ឋក្នុងវិស័យយុត្តិធម៌។

- រៀបចំ និងបញ្ជូនរបាយការណ៍ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុប្រចាំខែ ត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំជូនទៅក្រសួងយុត្តិធម៌
- បំពេញការកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រធានសាលាដំបូង និងព្រះរាជអាជ្ញាអមសាលាដំបូង ប្រគល់ឱ្យ។

ដើម្បីធានាដល់ប្រសិទ្ធភាពនៃកិច្ចដំណើរការការងារ លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងមាន "ត្រាផ្លូវការ" សម្រាប់អនុវត្តការកិច្ចរបស់ខ្លួន។

**មាត្រា ៥.-**

លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងត្រូវមានទំនាក់ទំនង និងកិច្ចសហការល្អជាមួយអាជ្ញាធររដ្ឋបាលដែនដីដែលខ្លួនតាំងនៅ។

**មាត្រា ៦.-**

លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងមានការិយាល័យចំណុះចំនួន ០៤(បួន) ដូចខាងក្រោម៖
- ការិយាល័យកិច្ចការរដ្ឋបាល និងបុគ្គលិក
- ការិយាល័យកិច្ចការហិរញ្ញវត្ថុ
- ការិយាល័យកិច្ចការតុលាការ
- ការិយាល័យកិច្ចការអយ្យការ។

ការិយាល័យនីមួយៗនៃលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។ ការិយាល័យ នៃលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង មានថ្នាក់ស្មើនឹងការិយាល័យថ្នាក់កណ្តាលនៃក្រសួងយុត្តិធម៌។

អង្គការលេខរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

១. ការិយាល័យកិច្ចការរដ្ឋបាល និងបុគ្គលិក ទទួលបន្ទុក ៖
- ទទួល និងចាត់ចែងឯកសារចេញ-ចូលរបស់សាលាដំបូង អយ្យការអមសាលាដំបូង និងលេខាធិការ-ដ្ឋានរដ្ឋបាលសាលាដំបូង
- គ្រប់គ្រងការងាររដ្ឋបាលទូទៅ និងការងារបុគ្គលិករបស់សាលាដំបូង និងអយ្យការអមសាលាដំបូង
- ទទួល គ្រប់គ្រង ធ្វើចរាចរឯកសាររដ្ឋបាលផ្សេងៗ និងរក្សាប្រព័ន្ធសន្តិសុខឯកសារ
- ទទួល និងចុះបញ្ជីពាក្យបណ្តឹង និងចាត់ចែងបន្តតាមនីតិវិធី
- គ្រប់គ្រងសំណុំរឿងដែលចាត់ការរួច ទិន្នន័យ សាលក្រម និងដីកាព្រឹត្តិបត្រ
- គណនាកំណត់ចំនួនប្រាក់តម្កល់ដាក់ពាក្យសុំ និងប្រាក់ផ្សេងទៀតតាមច្បាប់កំណត់
- តម្កល់ឯកសាររឿងក្តីសំណៅដើម និងថតចម្លងឯកសាររឿងក្តី ជូនអង្គភាពពាក់ព័ន្ធ
- គ្រប់គ្រងព័ត៌មានវិទ្យាសម្រាប់ដំណើរការរដ្ឋបាល និងរដ្ឋបាលនីតិវិធីសំណុំរឿង
- ចាត់ចែង និងសម្របសម្រួលការបញ្ជូនដីកា សាលក្រម ឬលិខិតផ្សេងៗដល់ភាគី និងអ្នកពាក់ព័ន្ធក្នុងរឿងក្តី ស្របតាមនីតិវិធី
- សម្របសម្រួល និងទំនាក់ទំនងសេវាបកប្រែ និងសេវាចាំបាច់ផ្សេងៗ
- សម្របសម្រួលការរក្សាជនល្មើស សាក្សី និងអ្នកពាក់ព័ន្ធ

- គ្រប់គ្រង ថែរក្សាវត្ថុតាងដែលមិនទាន់ចូលជាស្ថាពរ និងសម្របសម្រួលចលនាវត្ថុតាងតាមដំណើរការរឿងក្តី ក្រោមការទទួលខុសត្រូវរបស់សាលាដំបូង ឬអយ្យការអមសាលាដំបូង តាមច្បាប់កំណត់
- គ្រប់គ្រងត្រារបស់លេខាធិការដ្ឋានរដ្ឋបាល
- គ្រប់គ្រង រៀបចំការងារសន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យទូទៅ
- គ្រប់គ្រង រៀបចំ ទីតាំង អគារ សួនច្បារ អគ្គិសនី ទឹក និងកែលម្អសោភ័ណភាពផ្សេងៗ
- ផ្តល់ព័ត៌មានអំពីនីតិវិធីបឋមនៃសេវាសាធារណៈដល់សាធារណជន និងអង្គភាពពាក់ព័ន្ធ
- ស្រាវជ្រាវ និងលើកយោបល់ធ្វើទំនើបកម្មអំពីការផ្តល់សេវាយុត្តិធម៌
- រៀបចំ និងគ្រប់គ្រងបណ្ណាល័យ
- ប្រមូលផ្តុំព័ត៌មាន ចងក្រងឯកសារ រូបភាព វីដេអូ និងឯកសារសំខាន់ៗសម្រាប់ជាប្រយោជន៍ដល់ការលើកកម្ពស់ប្រសិទ្ធភាពការងាររបស់អង្គការតុលាការ និងអង្គការអយ្យការ
- ចាត់ចែង សម្របសម្រួល និងសហការបញ្ជូនសាលក្រម សេចក្តីសម្រេច និងឯកសារផ្សេងៗជូនទៅក្រសួងយុត្តិធម៌ និងស្ថាប័នពាក់ព័ន្ធផ្សេងៗ តាមច្បាប់កំណត់
- រៀបចំកិច្ចប្រជុំ សន្និបាត សិក្ខាសាលា កិច្ចការពិធីការ និងពិធីបុណ្យផ្សេងៗ
- គ្រប់គ្រងបុគ្គលិក រៀបចំផែនការ តារាងបៀវត្ស និងស្ថិតិបុគ្គលិក ព្រមទាំងរៀបចំសំណុំលិខិតរដ្ឋបាលសម្រាប់គ្រប់គ្រងអាជីព
- រៀបចំសំណើជ្រើសរើស ដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ព្រមទាំងរៀបចំសំណើផ្តល់មេដាយការងារ និងគ្រឿងឥស្សរិយយសផ្សេងៗ
- ចូលរួមរៀបចំផែនការ ប្រមូលផ្តុំព័ត៌មានគ្រប់គ្រងធនធានមនុស្ស កម្មវិធីការងារទូទៅ និងកម្មវិធីពង្រឹងសមត្ថភាពវិជ្ជាជីវៈរបស់បុគ្គលិក
- រៀបចំ និងបូកសរុបរបាយការណ៍របស់សាលាដំបូង និងអយ្យការអមសាលាដំបូង
- លើកគម្រោងថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំរបស់ការិយាល័យ
- រៀបចំរបាយការណ៍អំពីសកម្មភាព និងលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- អនុវត្តការកិច្ចផ្សេងទៀតដែលប្រធានលេខាធិការដ្ឋានប្រគល់ឱ្យ។

២. ការិយាល័យកិច្ចការហិរញ្ញវត្ថុ ទទួលបន្ទុក ៖

- គ្រប់គ្រងការងារផែនការ ថវិកា លទ្ធកម្ម បេឡា គណនេយ្យ សារពើភ័ណ្ឌ និងការងារហិរញ្ញវត្ថុទាំងឡាយរបស់សាលាដំបូង និងអយ្យការអមសាលាដំបូង
- ទទួល និងបូកសរុបផែនការសកម្មភាព និងផែនការថវិកាពីគ្រប់ការិយាល័យ និងអង្គភាពនានា ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់សាលាដំបូង និងអយ្យការអមសាលាដំបូង
- រៀបចំ និងគ្រប់គ្រង ការអនុវត្តថវិកា ដោយមានចុះកិច្ចបញ្ជិកាគណនេយ្យ
- រៀបចំបែបបទ សម្របសម្រួល គ្រប់គ្រង និងអនុវត្តកិច្ចលទ្ធកម្មសាធារណៈ តាមនីតិវិធីជាធរមាន
- រៀបចំបែបបទទូទាត់កិច្ចចំណាយដំណើរការរដ្ឋបាលផ្សេងៗ និងចំណាយកិច្ចលទ្ធកម្ម

- រៀបចំរបាយការណ៍អំពីសកម្មភាព និងលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- អនុវត្តការកិច្ចផ្សេងទៀតដែលប្រធានលេខាធិការដ្ឋានប្រគល់ឱ្យ។

៤. ការិយាល័យកិច្ចការអយ្យការ ទទួលបន្ទុក ៖

- គ្រប់គ្រងនិងចាត់ចែងបន្តលើសំណុំរឿងនិងការងារទាំងឡាយក្នុងសមត្ថកិច្ចអយ្យការអមសាលាដំបូងពីការិយាល័យកិច្ចការរដ្ឋបាល និងបុគ្គលិក
- សម្របសម្រួលកិច្ចការចរាចរឯកសារសំណុំរឿង និងប្រមូលព័ត៌មានទាក់ទងនឹងចំណាត់ការបណ្ដឹង និងដំណើរការនីតិវិធីសំណុំរឿងក្ដីព្រហ្មទណ្ឌ
- រៀបចំការបញ្ជូនសាលក្រមស្ថាពរទៅសាលាជម្រះក្ដី និង/ឬ ពន្ធនាគារដែលមានសមត្ថកិច្ច
- សម្របសម្រួលជាមួយចៅក្រម ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ក្រឡាបញ្ជី អាជ្ញាសាលា មន្ត្រីជំនួយយុត្តិធម៌ អ្នកជំនាញការ និងអាជ្ញាធរពាក់ព័ន្ធក្នុងកិច្ចដំណើរការរឿងក្ដី
- ចូលរួមរក្សា និងតម្កល់ឯកសាររឿងក្ដី ព្រមទាំងចូលរួមធានាប្រព័ន្ធសុវត្ថិភាពនៃឯកសារសំណុំរឿង
- ប្រមូល និងចងក្រងសាលក្រមស្ថាពរក្នុងរឿងព្រហ្មទណ្ឌ
- សម្របសម្រួលការអនុវត្តសាលក្រម ឬសាលដីកាស្ថាពរ ឬសេចក្ដីសម្រេចនានា
- សហការរៀបចំសិក្ខាសាលាពាក់ព័ន្ធនឹងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ
- សម្របសម្រួលរៀបចំកម្មវិធីសវនាការព្រហ្មទណ្ឌ ដើម្បីធានាកិច្ចដំណើរការល្អ
- សម្របសម្រួលការថតចម្លងឯកសាររឿងក្ដីព្រហ្មទណ្ឌ
- លើកគម្រោងថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំរបស់ការិយាល័យ
- រៀបចំរបាយការណ៍អំពីសកម្មភាព និងលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំ ជូនថ្នាក់ដឹកនាំ
- អនុវត្តការកិច្ចផ្សេងទៀតដែលប្រធានលេខាធិការដ្ឋានប្រគល់ឱ្យ។

## ជំពូកទី ៣
## អន្តរប្បញ្ញត្តិ

**មាត្រា ៧.-**

ក្នុងករណីដែលការិយាល័យណាមួយ នៃលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងណាមួយ មិនទាន់អាចដំណើរការបាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចចេញប្រកាសធ្វើការប្រគល់ភារកិច្ចរបស់ការិយាល័យនោះ ឱ្យទៅការិយាល័យណាមួយផ្សេងទៀតបាន។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចចេញប្រកាសធ្វើការកែសម្រួល និងបង្កើតការិយាល័យ ឬអង្គភាពមួយចំនួន ចំណុះឱ្យលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងបាន។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**អង្គ វង្សវឌ្ឍានា**

**<u>កន្លែងទទួល ៖</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី២
# ទាក់ទងការលែងលះ
# ដោយមានការព្រមព្រៀង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង រាជធានី(១) ---- ភ្នំពេញ ----
ស្រុក ខណ្ឌ (២) ---- ឫស្សីកែវ ----
ឃុំ សង្កាត់ (៣) ---- បាក់ខែង ----

លេខ (៤)------០៩------------------------
សៀវភៅអាពាហ៍ពិពាហ៍លេខ (៥)-០១/២០១២
ឆ្នាំ (៦)------ ២០១២ ------------------

# សំបុត្រអាពាហ៍ពិពាហ៍

| អំពីប្តី ប្រពន្ធ | | ប្តី | ប្រពន្ធ |
|---|---|---|---|
| នាមត្រកូល (៧) | | | |
| នាមខ្លួន (៨) | | | |
| ជាអក្សរឡាតាំង (៩) | នាមត្រកូល | | |
| | នាមខ្លួន | | |
| សញ្ជាតិ (១០) | | ខ្មែរ | ខ្មែរ |
| ថ្ងៃ ខែ ឆ្នាំកំណើត (១១) | | ថ្ងៃពុធ ទី២៧ ខែសីហា ឆ្នាំ១៩៨៣ | ថ្ងៃច័ន្ទ ទី១៧ ខែមករា ឆ្នាំ១៩៨៥ |
| ទីកន្លែងកំណើត (១២) ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្ត ក្រុង ប្រទេស | | ភូមិពញាឮ ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្តាល ប្រទេសកម្ពុជា | ភូមិក្តីចាស់ ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្តាល ប្រទេសកម្ពុជា |
| មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៣) | | សាស្ត្រាចារ្យ | គ្រូពេទ្យ |
| ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៤) | | ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា | ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ (១៥) | | ថ្ងៃ សុក្រ ទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២ | |
| ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ (១៦) | | សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | |
| **អំពីឪពុក ម្តាយ** | | **ខាងប្តី** | **ខាងប្រពន្ធ** |
| នាមត្រកូល និង នាមខ្លួនឪពុក (១៧) | | | |
| ជាអក្សរឡាតាំង (១៨) | | | |
| សញ្ជាតិ (១៩) | | ខ្មែរ | ខ្មែរ |
| ថ្ងៃ ខែ ឆ្នាំកំណើត (២០) | | ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៤៦ | ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥៥ |
| នាមត្រកូល និង នាមខ្លួនម្តាយ (២១) | | | |
| ជាអក្សរឡាតាំង (២២) | | | |
| សញ្ជាតិ (២៣) | | ខ្មែរ | ខ្មែរ |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៤) | | ថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៤៨ | ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៥០ |

(២៥) ធ្វើនៅ... បាក់ខែង .... ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២

(២៦) មន្ត្រីអត្រានុកូលដ្ឋាន

មេឃុំ

(២៧) ហត្ថលេខា និងត្រា

កែវ សុទី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀងលែងលះដោយស្ម័គ្រចិត្ត

**រវាង**

ខ្ញុំបាទឈ្មោះ :....................................ឆ្នាំកំណើត..............ជនជាតិ..............កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ............................មានទីលំនៅផ្ទះលេខ..............ផ្លូវលេខ..............ឃុំ/សង្កាត់ ......................ស្រុក/ខណ្ឌ ....................ខេត្ត.............។

**និង**

នាងខ្ញុំឈ្មោះ :....................................ឆ្នាំកំណើត..............ជនជាតិ..............កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ............................មានទីលំនៅផ្ទះ..............ផ្លូវលេខ..............ឃុំ/សង្កាត់....... ......................ស្រុក/ខណ្ឌ ....................ខេត្ត.............។

**ដោយហេតុថា**

យើងខ្ញុំទាំងពីរនាក់ប្តី - ប្រពន្ធបានអស់មនោសញ្ចេតនារួមរស់ជាមួយគ្នា ជាប្តីប្រពន្ធតទៅទៀតហេតុនេះ យើងខ្ញុំទាំងពីរនាក់បានសំរេចចិត្តសុំមកកុលាការ ដើម្បីសម្រេចអោយយើងខ្ញុំទាំងពីរនាក់បានលែងលះគ្នា ដោយស្ម័គ្រចិត្ត ស្របទៅតាមច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ នៃព្រះរាជាណាចក្រកម្ពុជា និងធ្វើការបែងចែកទ្រព្យសម្បត្តិព្រមទាំងកូនតាមលក្ខខណ្ឌ ដូចខាងក្រោម៖

## ប្រការ១. ការលែងលះ

<u>ប្រការ១</u> : ខ្ញុំបាទ....................................ជាប្តី និង នាងខ្ញុំ......................................ជាប្រពន្ធ យើងខ្ញុំទាំងពីរនាក់យល់ព្រមលែងលះគ្នា ដោយស្ម័គ្រចិត្តគ្នា នការគំរាមកំហែង គ្មា នការបង្ខិតបង្ខំ ដោយមូលហេតុថា យើងខ្ញុំទាងពីរនាក់រស់នៅមិនចុះសំរុងនឹងគ្នា ធ្វើឱ្យអស់មនោសញ្ចេតនាក្នុងការរួមរស់ជាមួយគ្នា ជាប្តី - ប្រពន្ធតទៅទៀត ។

## ប្រការ២. ទ្រព្យសម្បត្តិ

១.ប្តីយល់ព្រមប្រគល់ ទ្រព្យសម្បត្តិ............................................................................ឱ្យទៅប្រពន្ធ(មានស្នា មមេដៃភ្ជា ប់ក្នុងឯកសារ)។ ប្រពន្ធយល់ព្រមប្រគល់............................................ ....................................ទៅប្តី(មានស្នា មមេដៃភ្ជា ប់ក្នុងឯកសារ)។

២. គូភាគីជានាថា មុនថ្ងៃចុះកិច្ចព្រមព្រៀងលែងលះ រហូតដល់ត្រឹមថ្ងៃចុះកិច្ចព្រមព្រៀងនេះគឺពុំមានជាប់ពាក់ព័ន្ធនឹងបំណុ លឡើយ ហេតុនេះ គិតចាប់ពីថ្ងៃចុះកិច្ចព្រមព្រៀងលែងលះគ្នា នេះ គឺគូភាគីទាំង

ពីរពុំទទួលស្គាល់បំណុលដែលភាគីណាមួយបង្កនោះឡើយ។ ក្នុងករណី បើមានភាគីណាមួយបង្កឡើង ភាគីនោះជាអ្នកទទួលខុសត្រូវទាំងស្រុង ដោយពុំជាប់ពាក់ព័ន្ធនឹងភាគីម្ខាងទៀតឡើយ ។

**ប្រការ៣. ការថែទាំកូន**

ភាគីខាងប្តីគឺលោក..............................................យល់ព្រមប្រគល់កូន........................ ឈ្មោះ:...................................ឆ្នាំកំណើត....................................ឱ្យភាគីខាងប្រពន្ធ គឺលោកស្រី ....................................ដើម្បីគ្រប់គ្រង និងចិញ្ចឹមបីបាច់ថែរក្សារហូតពេញវ័យតាមផ្លូវច្បាប់ ។

**ប្រការ៤. អាហារកិច្ច**

ភាគីខាងប្តី គឺលោក....................................យល់ព្រមបង់ប្រាក់អាហារកិច្ចចិញ្ចឹមកូន....... ............ឈ្មោះ:...................................ឆ្នាំកំណើត....................................ក្នុងមួយខែចំនួ......... ........... (........................ដុល្លាអាមេរិច ) រហូតដល់ពេញនីតិភាព (គ្រប់អាយុ ១៨ ឆ្នាំ )ដល់ភាគីខាងប្រពន្ធ គឺលោកស្រី .....................................។

**ប្រការ៥. ការសហការ**

បន្ទាប់ពីភាគីទាំងពីរព្រមព្រៀងលែងលះគ្នា តាមប្រការ ១ ខាងលើរួចហើយ ភាគីទាំងពីរត្រូវគោរពសិទ្ធិគ្នាទៅវិញទៅមក មិនត្រូវរំខាន ឬ បង្ករបញ្ហាផ្សេងៗទៀត ធ្វើអោយប៉ះពាល់ដល់ភាគីណាមួយឡើយ។ ក្នុងករណីបើភាគីណាមួយមិនគោរព ភាគីនោះត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ ដែលកើតចេញពីអំពើរបស់ខ្លួន ។

**ប្រការ៦. អវសានបទ**

ភាគីទាំងពីរបានអាន និង ពិនិត្យចប់សព្វគ្រប់ ហើយឯកភាពអនុវត្តតាមលក្ខខណ្ឌខាងលើព្រមទាំងផ្តិតស្នាមមេដៃទុកជាភស្តុតាង ដោយពុំមានល្មើសត្រង់ចំនុចណាមួយឡើយ ហើយសុខចិត្តទទួលខុសត្រូវចំពោះមុខច្បាប់នូវកំហុសខ្លួនបានប្រព្រឹត្ត ។

កិច្ចព្រមព្រៀងនេះធ្វើឡើងជាភាសាខ្មែរ ចំនួន..........ច្បាប់ដើម មានអត្ថន័យ-ខ្លឹមសារ និង សុពលភាពដូចៗគ្នា និងរក្សាទុកនៅ៖

- លោក.................................... ចំនួន..........ច្បាប់
- លោកស្រី ................................... ចំនួន..........ច្បាប់
- មេធាវី.................................... ចំនួន..........ច្បាប់

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ..........ឆ្នាំ២០....

**ស្នាមមេដៃស្តាំ** **ស្នាមមេដៃស្តាំ**

**<u>បានឃើញ និងបញ្ជាក់</u>**

គូភាគីទាំងពីរខាងលើនេះបានព្រមព្រៀង

ផ្តិតស្នាមមេដៃចំពោះមុខ....................ប្រាកដមែន ។

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ..........ឆ្នាំ ២០......

**ហត្ថលេខា និង ត្រា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គំរូ
ពាក្យសុំលែងលះ
ដោយព្រមព្រៀង

## ពាក្យស្នើសុំលែងលះតាមការព្រមព្រៀង

**ដើមចោទ** ៖ ឈ្មោះ.................... ភេទ......... អាយុ...... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ.............. មានទីលំនៅបច្ចុប្បន្ន...........................................................។

**ចុងចម្លើយ** ៖ ឈ្មោះ.................... ភេទ......... អាយុ...... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ.............. មានទីលំនៅបច្ចុប្បន្ន...........................................................។

**សូមគោរពចូលមក**

**ឯកឧត្តមប្រធានសាលាដំបូង**..........................

**កម្មវត្ថុ** ៖ សុំឲ្យតុលាការចេញដីកាសម្រេច មានខ្លឹមសារដូចខាងក្រោម ៖

១- ឲ្យ ដើមចោទ និងចុងចម្លើយ ផ្តាច់សមត្ថសង្វាស់ តាមផ្លូវច្បាប់ ។

២-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ..........

៣-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) បង់អាហារកាតព្វកិច្ច និងអាចចូលសួរសុខទុក្ខកូនតាមច្បាប់កំណត់ ។

៤-សម្រេចឲ្យ ដើមចោទ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖

..........................................................................................................

..........................................................................................................

៥-សម្រេចឲ្យ ចុងចម្លើយ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖

..........................................................................................................

..........................................................................................................

៦-សម្រេចឲ្យ ដើមចោទ សងបំណុលដូចខាងក្រោម៖

(បើមានសូមសរសេរ)........................................................................

..........................................................................................................

៧-សម្រេចឲ្យ ចុងចម្លើយ សងបំណុលដូចខាងក្រោម៖

(បើមានសូមសរសេរ)........................................................................

..........................................................................................................

**យោង** ៖ -សំបុត្រអាពាហ៍ពិពាហ៍លេខ.......ចុះថ្ងៃទី...................... របស់.......................។

- ..........................................................................................................

តបតាមកម្មវត្ថុខាងលើ យើងខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា ៖ យើងខ្ញុំបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅសាលាសង្កាត់.......................... តាមលិខិតលេខ............ ចុះថ្ងៃទី.................... ។ នៅពេលនេះ យើងខ្ញុំបានអស់មនោសញ្ចេតនាក្នុងការរស់នៅជាប្តីប្រពន្ធនឹងគ្នាទៀតហើយ ។ យើងខ្ញុំបានព្រមព្រៀងលែងលះគ្នាដោយស្ម័គ្រចិត្ត ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនិងសម្រេចតាមការស្នើសុំខាងលើដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ធ្វើនៅ................. ថ្ងៃទី......... ខែ......... ឆ្នាំ២០១.....

ស្នាមមេដៃស្តាំចុងចម្លើយ
(ស្នាមមេដៃស្តាំ)

..................

ស្នាមមេដៃស្តាំដើមចោទ
(ស្នាមមេដៃស្តាំ)

....................

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## លិខិតប្រគល់សិទ្ធិជាមេធាវីតំណាងដោយអាណត្តិ

**អាណត្តិទាយក៖** ឈ្មោះ.................... ភេទ.......... កាន់អត្តសញ្ញាណប័ណ្ណលេខ....................
ចុះថ្ងៃទី...... ខែ...... ឆ្នាំ.......... មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ.............. ភូមិ..........
ឃុំ/សង្កាត់.................. ស្រុក/ខណ្ឌ.................... រាជធានី/ខេត្ត.................... ។

**តាមរយៈលិខិតនេះ ខ្ញុំសូមប្រគល់សិទ្ធិតំណាងដោយអាណត្តិជូនមេធាវីធ្វើសកម្មភាពតាមផ្លូវច្បាប់នូវកិច្ចការទាំងឡាយដែលពាក់ព័ន្ធរឿងក្ដីដូចមាន កំណត់ដូចខាងក្រោម៖**

**មេធាវី** : **មេធាវី នៃក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ**
**ការិយាល័យ** : **ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ** (C.I.C LAW GROUP)
**អាសយដ្ឋាន** : អគារលេខ៤៥៣៥ ផ្លូវលេខ១០០៣ ស្ថិតក្នុងភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ ភ្នំពេញ ។

**១. រឿងក្ដី** (..........................................)

**ក. គូភាគី:** ..........................................................................
**ខ. យុត្តាធិការ:** ....................................................................
**គ. ការបង្ហាញរឿងក្ដី:** ..............................................................

**២. ចំណុចដែលត្រូវផ្ទេរផ្ដាក់ឲ្យធ្វើជាអាណត្តិ៖**

ក. ប្រគល់សិទ្ធិពេញលេញក្នុងការធ្វើសកម្មភាពតំណាងឲ្យអាណត្តិទាយកឈ្មោះ..............................។
ខ. ដាក់ និងដកពាក្យបណ្ដឹង បណ្ដឹងតប ពាក្យសុំ ពាក្យតវ៉ា ទាំងស្រុង ឬមួយផ្នែក។
គ. ការដាក់ ឬដកខ្លួនចេញពីបណ្ដឹងអន្តរាគមន៍ ការទទួលស្គាល់ ឬការបដិសេធការទាមទារ ការចាត់ចែងរក្សាការពារ ការអនុវត្តដោយបង្ខំ ចូលរួមចរចា ធ្វើការផ្សះផ្សា ការសះជា ឬការដោះស្រាយក្រៅប្រព័ន្ធតុលាការ។
ឃ. ការធ្វើបណ្ដឹងឧបាស្រ័យ ឬបណ្ដឹងតវ៉ាចំពោះការលើកចោល ឬអាយទទួលបណ្ដឹងឧបាស្រ័យ។
ង. ធ្វើសេចក្ដីថ្លែងការណ៍ទាមទារ ការឆ្លើយដោះសារចំពោះបណ្ដឹង ឬបណ្ដឹងតប។
ច. ការចាត់តាំងអនុតំណាងដោយអាណត្តិជាមេធាវី ឬ ការទទួលនូវការសង និងការទូទាត់ផ្សេងៗ។
ឆ. រាល់សកម្មភាពរបស់មេធាវីតំណាងដោយអាណត្តិ ធ្វើក្នុងនាមអាណត្តិទាយក និងដើម្បីផលប្រយោជន៍របស់អាណត្តិទាយក។

**ចំណាំ៖** ការចំណាយលើពន្ធតុលាការ និងសោហ៊ុយផ្សេងៗ ទៀតក្នុងបណ្ដាកិច្ចការខាងលើ ជាបន្ទុករបស់អាណត្តិទាយកទាំងស្រុង។ក្នុងករណីមិនគោរពកាតព្វកិច្ចនេះអាណត្តិទាយកសុខចិត្តទទួលខុសត្រូវនូវរាល់ការបាត់បង់ផលប្រយោជន៍នានា ដោយខ្លួនឯងផ្ទាល់ ។

ធ្វើនៅ.................... ថ្ងៃទី...... ខែ........ ឆ្នាំ..............

| | |
|---|---|
| **បានឃើញ និងយល់ព្រម** | **ស្នាមមេដៃស្ដាំអាណត្តិទាយក** |

ទទួលសិទ្ធិតំណាងដោយអាណត្តិឲ្យអាណត្តិទាយក
ឈ្មោះ..............................
ធ្វើនៅ.................... ថ្ងៃទី...... ខែ........ ឆ្នាំ..............
**ហត្ថលេខា និងត្រា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

លេខ : ៣៤២/២០ តកក.......

**ប្រធានតុលាការកំពូល**
**ជម្រាបមក**
**លោក លោកស្រី ក្រឡាបញ្ជីតុលាការកំពូល**

**កម្មវត្ថុ:** សេចក្តីណែនាំស្តីពីការបញ្ជាក់ការចូលជាស្ថាពរនៃសាលដីការដ្ឋប្បវេណី និងការផ្តល់រូបមន្តអនុវត្ត

**យោង:** មាត្រា ១៩៥ មាត្រា ៣៥៤ និងមាត្រា ៣៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

កន្លងមក តុលាការកំពូលកត់សម្គាល់ឃើញថា ក្រោយពេលក្រឡាបញ្ជីចេញរូបមន្តអនុវត្តជាលិខិតមួយដាច់ដោយឡែកពីសាលដីកាស្ថាពរ ភាគីចាញ់ក្តីភាគច្រើនបានដាក់ពាក្យប្តឹងតវ៉ាចំពោះរូបមន្តអនុវត្តនោះក្នុងចេតនា រារាំងដល់ការអនុវត្តសាលដីកាស្ថាពរប្រកបដោយប្រសិទ្ធិភាព ធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធិភាពនៃការអនុវត្តច្បាប់ និងជំនឿទុកចិត្តលើប្រព័ន្ធតុលាការ។

ដើម្បីពង្រឹងប្រសិទ្ធិភាពនៃការអនុវត្តច្បាប់ និងជំនឿទុកចិត្តលើប្រព័ន្ធតុលាការក្នុងការអនុវត្តសាលដីកាស្ថាពរឱ្យបានសម្រេច ខ្ញុំសូមធ្វើការណែនាំ លោក លោកស្រីក្រឡាបញ្ជី ដូចតទៅ៖

នៅក្នុងសាលដីកាស្ថាពរ ក្រឡាបញ្ជីទទួលបន្ទុកសំណុំរឿងត្រូវសរសេរនៅផ្នែកខាងក្រោមនៃសាលដីកាតម្លងយថាភូត(អក្សរ khmer Kep 12 និង Khmer OS Muol 12)ដូចខាងក្រោម៖

> "យើង..................ក្រឡាបញ្ជីតុលាការកំពូល បញ្ជាក់ថា សាលដីកានេះបានចូលជាស្ថាពរ និងមានអានុភាពអនុវត្ត ចាប់ពីថ្ងៃទី..........ខែ..........ឆ្នាំ.........។"
>
> **"សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាទ្រង់ត្រាស់បង្គាប់មកអ្នកអនុវត្តសាលដីកាឱ្យសម្រេចតាមសាលដីកានេះ និងឱ្យអាជ្ញាធរគ្រប់តំណែងគ្រប់ថ្នាក់ ជួយអនុវត្តសាលដីកានេះ បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។"**
>
> ថ្ងៃ........ ខែ..... ឆ្នាំ..... ទោស័ក ព.ស.......
>
> រាជធានីភ្នំពេញ ថ្ងៃទី.... ខែ.... ឆ្នាំ .......
>
> **ក្រឡាបញ្ជី**

(យកកាលបរិច្ឆេទប្រកាសសាលដីកា) (សូមមើលគំរូភ្ជាប់នេះ)។

មហាវិថី សម្តេចសុធារស, សង្កាត់ចតុមុខ, ខណ្ឌដូនពេញ, កម្ពុជា ទូរស័ព្ទ: ៨៥៥-២៣-២១២ ៨២៦ ទូរសារ : ៨៥៥-២៣-២១២ ៨២៦
Sothearos Blvd, Sangkat Chatomuk, Khan Daun Penh, Cambodia Tel : 855-23-212 826 Fax : 855-23-212-826

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

-សំណុំរឿងរដ្ឋប្បវេណីមិនមែនជា
បណ្តឹងលេខ
ចុះថ្ងៃទី ខែ ឆ្នាំ
ដីកាសម្រេច
លេខ.
ចុះថ្ងៃទី ខែ ឆ្នាំ

## ដីកាសម្រេច
## រឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

យើង **តាំង ស៊ុនឡាយ** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ មាត្រា៣ និងមាត្រាពាក់ព័ន្ធនឹងច្បាប់ស្តីពីនីតិវិធី នៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១០/០១៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០។

-បានឃើញ មាត្រា ៩៧៩ និងមាត្រាពាក់ព័ន្ធ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

-បានឃើញ សំណុំរឿងរដ្ឋប្បវេណីមិនមែនជាបណ្តឹងលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមាន៖

**-ភាគីអ្នកដាក់ពាក្យសុំ ឈ្មោះ** ភេទ កើតថ្ងៃទី ខែ ឆ្នាំ កាន់ ចុះថ្ងៃទី ខែ ឆ្នាំ អាសយដ្ឋានស្ថិតនៅផ្ទះលេខ ផ្លូវលំ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ លោក** អត្តលេខ ជាមេធាវី មានការិយាល័យ ផ្ទះលេខ ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

**-ភាគីម្ខាងទៀត ឈ្មោះ** ភេទ កើតថ្ងៃទី ខែ ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ អាសយដ្ឋានស្ថិតនៅផ្ទះលេខ ផ្លូវលំ ភូមិ សង្កាត់ រាជធានីភ្នំពេញ។

## អង្គហេតុ និងចំណុចវិវាទ

**១-ខ្លឹមសារនៃដីកាសម្រេចដែលភាគីអ្នកដាក់ពាក្យសុំទាមទារឱ្យតុលាការចេញ៖**

១.១.ឱ្យភាគីអ្នកដាក់ពាក្យសុំឈ្មោះ ភេទ កើតថ្ងៃទី ខែ ឆ្នាំ និងភាគីម្ខាងទៀតឈ្មោះ ភេទ កើតថ្ងៃទី ខែ ឆ្នាំ លែងលះតាមការព្រមព្រៀង។

១.២.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីអ្នកដាក់ពាក្យសុំ។

**២-ដំណើររឿងក្តី**

កាលពីអំឡុងឆ្នាំ ភាគីអ្នកដាក់ពាក្យសុំឈ្មោះ បានរៀបអាពាហ៍ពិពាហ៍ជាមួយភាគីម្ខាងទៀតឈ្មោះ ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ចុះថ្ងៃទី ខែ ឆ្នាំ

នៅមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ ។ នៅក្នុងចំណងអាពាហ៍ពិពាហ៍ភាគីទាំងពីរពុំមានកូន ទ្រព្យសម្បត្តិរួម និងបំណុលឡើយ។ ដោយការរស់នៅជាមួយគ្នាកន្លងមកមិនចុះសម្រុងនឹងគ្នា រហូតដល់គូភាគីអស់មនោសញ្ចេតនាជាប្ដីប្រពន្ធតទៅទៀត ទើបភាគីទាំងពីរដាក់ពាក្យសុំលែងលះតាមការព្រមព្រៀងមកតុលាការ។

**៣-អង្គហេតុដែលអះអាងដោយភាគីអ្នកដាក់ពាក្យសុំ**

ភាគីអ្នកដាក់ពាក្យសុំឈ្មោះ បានអះអាងថា ខ្លួនស្នើរសុំឱ្យតុលាការចេញដីកាសម្រេច៖

-លែងលះតាមការព្រមព្រៀងរវាងអ្នកដាក់ពាក្យសុំឈ្មោះ និងភាគីម្ខាងទៀតឈ្មោះ ។

-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីអ្នកដាក់ពាក្យសុំ។

ចំពោះអង្គហេតុគឺ ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ កាលពីឆ្នាំ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ចុះថ្ងៃទី ខែ ឆ្នាំ ត្រឹមត្រូវតាមច្បាប់។ ក្នុងចំណងអាពាហ៍ពិពាហ៍រហូតមកដល់សព្វថ្ងៃពុំមានកូន ទ្រព្យសម្បត្តិរួម និងបំណុលរួមនោះទេ។ មូលហេតុនៃការលែងលះ គឺដោយហេតុថាខ្លួន និងភាគីម្ខាងទៀតរស់នៅមិនចុះសម្រុងនឹងគ្នា រហូតដល់បណ្ដាលឱ្យអស់មនោសញ្ចេតនាជាប្ដីប្រពន្ធតទៅទៀត ដែលធ្វើឱ្យចំណាក់ចំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់មិនអាចធ្វើបដិសន្ធានវិញបាន។ ចំពោះកិច្ចព្រមព្រៀងលែងលះចុះថ្ងៃទី ខែ ឆ្នាំ គឺកើតចេញពីឆន្ទៈពិតប្រាកដរបស់ខ្លួន មិនមានការបង្ខិតបង្ខំឡើយ ហើយស្នាមម្រាមដៃលើកិច្ចព្រមព្រៀងគឺពិតជាស្នាមម្រាមដៃរបស់ខ្លួនប្រាកដមែន ដូច្នេះខ្លួនសុំឱ្យតុលាការសម្រេចតាមពាក្យសុំរបស់ខ្លួន។

**៤-អង្គហេតុដែលអះអាងដោយភាគីម្ខាងទៀត**

ភាគីម្ខាងទៀតឈ្មោះ បានអះអាងថាខ្លួនឯកភាពលែងលះជាមួយភាគីអ្នកដាក់ពាក្យសុំឈ្មោះ ។ ចំពោះអង្គហេតុ និងមូលហេតុ ដែលភាគីអ្នកដាក់ពាក្យសុំបានលើកឡើងគឺពិតជាត្រឹមត្រូវខ្លួនមិនមានការជំទាស់ឡើយ ចំណែកកិច្ចព្រមព្រៀងលែងលះ ចុះថ្ងៃទី ខែ ឆ្នាំ គឺកើតចេញពីឆន្ទៈពិតប្រាកដរបស់ខ្លួនមិនមានការបង្ខិតបង្ខំឡើយ ហើយស្នាមម្រាមដៃលើកិច្ចព្រមព្រៀងគឺ ពិតជាស្នាមម្រាមដៃរបស់ខ្លួនប្រាកដមែន ដូច្នេះខ្លួនសុំឱ្យតុលាការសម្រេចតាមច្បាប់។

## ការពិនិត្យភស្តុតាង

**១-ភស្តុតាងជាឯកសាររបស់ភាគីអ្នកដាក់ពាក្យសុំ**

-កិច្ចព្រមព្រៀងលែងលះ ចុះថ្ងៃទី ខែ ឆ្នាំ រវាងឈ្មោះ និងឈ្មោះ ។

-សំបុត្រអាពាហ៍ពិពាហ៍លេខ ចុះថ្ងៃទី ខែ ឆ្នាំ ក្នុងសៀវភៅអាពាហ៍ពិពាហ៍ លេខ ចេញដោយមន្ត្រីអត្រានុកូលដ្ឋាន សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

- លេខ របស់ឈ្មោះ ។

**២-ភស្តុតាងជាឯកសាររបស់ភាគីម្ខាងទៀត**

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី របស់ឈ្មោះ ។

## សំអាងហេតុ

១-តាមសេចក្ដីថ្លែងការណ៍របស់ភាគីអ្នកដាក់ពាក្យសុំឈ្មោះ និងភាគីម្ខាងទៀតឈ្មោះ នាពេលសាកសួរ ព្រមទាំងសំបុត្រអាពាហ៍ពិពាហ៍ លេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់មន្ត្រី

អគ្រានុកូលដ្ឋាន សង្កាត់ ក្នុងខណ្ឌ រាជធានីភ្នំពេញ បានបង្ហាញឱ្យឃើញថា រវាងភាគីអ្នកដាក់ពាក្យសុំឈ្មោះ និងភាគីម្ខាងទៀតឈ្មោះ ពិតជាប្តីប្រពន្ធស្របច្បាប់ដែលបានរៀបអាពាហ៍ពិពាហ៍ ទទួលស្គាល់ដោយមន្ត្រីអគ្រានុកូលដ្ឋានសង្កាត់ ប្រាកដមែន។

២-តាមការអះអាងរបស់ភាគីអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត នៅក្នុងកំណត់ហេតុសាកសួរ ដែលភាគីទាំងពីរបានបញ្ជាក់មូលហេតុដែលឈានដល់ការលែងលះតាមការព្រមព្រៀង តុលាការយល់ឃើញថាអាពាហ៍ពិពាហ៍រវាងឈ្មោះ និងឈ្មោះ ពិតជាបានបាក់បែកមិនអាចធ្វើបដិទានវិញបាន ហើយភាគីទាំងពីរពិតជាមានឆន្ទៈពិតប្រាកដក្នុងការលែងលះ ទោះបីជាតុលាការបានខិតខំផ្សះផ្សារយ៉ាងណាក៏ដោយ ភាគីនៅតែទាមទារតុលាការឱ្យសម្រេចអំពីការលែងលះ គប្បីតុលាការពិនិត្យ និងសម្រេចអំពីការលែងលះនេះតាមបញ្ញត្តិមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី។

៣-នាពេលសាកសួរភាគីទាំងពីរបានអះអាងថា ក្នុងចំណងអាពាហ៍ពិពាហ៍គូភាគីពុំមានកូន ទ្រព្យសម្បត្តិរួម និងបំណុលរួម ដែលត្រូវធ្វើការបែងចែកឡើយ **ដូចនេះ តុលាការមិនលើកយកចំនុចទាំងនេះមកពិចារណា និងសម្រេចឡើយ។**

៤-ភាគីអ្នកដាក់ពាក្យសុំបានស្នើសុំទទួលបន្ទុកប្រាក់ប្រដាប់ក្តី ដូចនេះគប្បីតុលាការពិចារណា និងសម្រេចអំពីបន្ទុកនៃប្រាក់ប្រដាប់ក្តីទៅតាមបញ្ញត្តិមាត្រា២២ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។

## **សេចក្តីសម្រេចបញ្ចប់**

១-ឱ្យភាគីអ្នកដាក់ពាក្យសុំឈ្មោះ ភេទ កើតថ្ងៃទី ខែ ឆ្នាំ និងភាគីម្ខាងទៀតឈ្មោះ ភេទ កើតថ្ងៃទី ខែ ឆ្នាំ លែងលះតាមការព្រមព្រៀង។

២-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីអ្នកដាក់ពាក្យសុំ។

**ចៅក្រម**

**ហត្ថលេខា និងត្រា: តាំង ស៊ុនឡាយ**

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ ខែ ឆ្នាំ ព.ស.

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

**ក្រឡាបញ្ជី**

**ឈិន ចិន្តា**

**បានឃើញ**

**ចៅក្រម**

តាំង_ស៊ុនឡាយ

គំរូលេខ 09 សហវ/ចមក

260-1- 00203712

MEF20882604121

ក្រសួងយុត្តិធម៌

អង្គភាព [illegible]

# បង្កាន់ដៃបង់ប្រាក់

(ប្រគល់ជូនអ្នកបង់ប្រាក់)

ទទួលពី [illegible] អង្គភាព [illegible]

ចំនួនទឹកប្រាក់ជាលេខ [illegible]

ជាអក្សរ [illegible]

អត្ថន័យចំណូល [illegible] មាតិកាថវិកា

ថ្ងៃទី. ខែ. ឆ្នាំ.

អ្នកប្រមូលចំណូល

[illegible]

បង្កាន់ដៃនេះត្រូវបានបោះពុម្ព និងគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្របតាមអនុក្រឹត្យលេខ ៨២អនក្រ. ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥

# ឧបសម្ព័ន្ធទី៣
# ទាក់ទងការលែងលះ
# ដោយគ្មានការព្រមព្រៀង

គំរូ
ពាក្យសុំលែងលះ
គ្មានការព្រមព្រៀង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យបណ្តឹងលែងលះ

**ដើមចោទ** ៖ ឈ្មោះ.................... ភេទ......... អាយុ...... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ.............. មានទីលំនៅបច្ចុប្បន្ន.............................................................។

**ចុងចម្លើយ** ៖ ឈ្មោះ.................... ភេទ......... អាយុ...... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ.............. មានទីលំនៅបច្ចុប្បន្ន.............................................................។

**សូមគោរពចូលមក**
**ឯកឧត្តមប្រធានសាលាដំបូង**........................

**កម្មវត្ថុ** ៖ សុំឲ្យតុលាការចេញដីកាសម្រេច មានខ្លឹមសារដូចខាងក្រោម ៖
១- ឲ្យ ដើមចោទ និងចុងចម្លើយ ផ្តាច់សម្ពន្ធសង្វាស់ តាមផ្លូវច្បាប់ ។
២-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ.........
៣-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) បង់អាហារកាតព្វកិច្ច និងអាចចូលសួរសុខទុក្ខកូនតាមច្បាប់កំណត់ ។
៤-សម្រេចឲ្យ ដើមចោទ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖
.......................................................................................................
៥-សម្រេចឲ្យ ចុងចម្លើយ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖
.......................................................................................................
៦-សម្រេចឲ្យ ដើមចោទ សងបំណុលដូចខាងក្រោម៖
(បើមានសូមសរសេរ)...........................................................................
៧-សម្រេចឲ្យ ចុងចម្លើយ សងបំណុលដូចខាងក្រោម៖
(បើមានសូមសរសេរ)...........................................................................

**យោង** ៖ -សំបុត្រអាពាហ៍ពិពាហ៍លេខ......ចុះថ្ងៃទី.................... របស់......................។
- ..............................................................................................

កាលពីថ្ងៃទី.....ខែ....ឆ្នាំ..... នាងខ្ញុំ/ខ្ញុំបាទ បាចចអាពាហ៍ពិពាហ៍ ជាឈ្មោះ........................ ។ ប៉ុន្តែក្នុងកំឡុងពេលអាពាហ៍ពិពាហ៍ ឈ្មោះនេះ (សរសេរពីមូលហេតុដែលនាំឲ្យមានការទាមទារ) .........................................................................................................................................................................។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាទទួល និងសម្រេចតាមការប្តឹងសុំខាងលើដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ធ្វើនៅ................ ថ្ងៃទី........ ខែ........ ឆ្នាំ២០១.....

| | |
|---|---|
| ស្នាមមេដៃស្តាំចុងចម្លើយ | ស្នាមមេដៃស្តាំដើមចោទ |
| (ស្នាមមេដៃស្តាំ) | (ស្នាមមេដៃស្តាំ) |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## លិខិតប្រគល់សិទ្ធិជាមេធាវីតំណាងដោយអាណត្តិ

**អាណត្តិទាយក** ៖ឈ្មោះ.................... ភេទ.............. កាន់អត្តសញ្ញាណប័ណ្ណលេខ....................

ចុះថ្ងៃទី...... ខែ........ ឆ្នាំ.............. មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ................ ភូមិ..............

ឃុំ/សង្កាត់.................. ស្រុក/ខណ្ឌ.................... រាជធានី/ខេត្ត.................... ។

**តាមរយៈលិខិតនេះ ខ្ញុំសូមប្រគល់សិទ្ធិតំណាងដោយអាណត្តិជូនមេធាវីធ្វើសកម្មភាពតាមផ្លូវច្បាប់នូវកិច្ចការទាំងឡាយដែលពាក់ព័ន្ធរឿងក្ដីដូចមាន កំណត់ដូចខាងក្រោម៖**

**មេធាវី** : **មេធាវី នៃក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ**

**ការិយាល័យ** : **ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ** (C.I.C LAW GROUP)

**អាសយដ្ឋាន** : អគារលេខ៤៥៣៥ ផ្លូវលេខ១០០៣ ស្ថិតក្នុងភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ ភ្នំពេញ ។

**១. រឿងក្ដី** (..........................................)

**ក. គូភាគី:** ..........................................................................

**ខ. យុត្តាធិការ:** ..........................................................................

**គ. ការបង្ហាញរឿងក្ដី:** ..........................................................................

**២. ចំណុចដែលត្រូវផ្ទុកផ្ដាក់ឲ្យធ្វើជាអាណត្តិ:**

ក. ប្រគល់សិទ្ធិពេញលេញក្នុងការធ្វើសកម្មភាពតំណាងឲ្យអាណត្តិទាយក ឈ្មោះ.................................. ។

ខ. ដាក់ និងដកពាក្យបណ្ដឹង បណ្ដឹងតប ពាក្យសុំ ពាក្យតវ៉ា ទាំងស្រុង ឬមួយផ្នែក។

គ. សុំដាក់ ឬដកខ្លួនចេញពីបណ្ដឹងអន្តរាគមន៍ ការទទួលស្គាល់ ឬការបដិសេធការទាមទារ ការចាត់ចែងរក្សាការពារ ការអនុវត្តដោយបង្ខំ ចូលរួមចរចា ធ្វើការផ្សះផ្សា ការសះជា ឬការដោះស្រាយក្រៅប្រព័ន្ធតុលាការ។

ឃ. ការធ្វើបណ្ដឹងឧបាស្រ័យ ឬបណ្ដឹងតវ៉ាចំពោះការលើកចោល ឬអោយទទួលបណ្ដឹងឧបាស្រ័យ។

ង. ធ្វើសេចក្ដីថ្លែងការណ៍ទាមទារ ការឆ្លើយដោះសារចំពោះបណ្ដឹង ឬបណ្ដឹងតប។

ច. ការចាត់តាំងអនុតំណាងដោយអាណត្តិជាមេធាវី ឬ ការទទួលនូវការសង និងការទូទាត់ផ្សេងៗ។

ឆ. រាល់សកម្មភាពរបស់មេធាវីតំណាងដោយអាណត្តិ ធ្វើក្នុងនាមអាណត្តិទាយក និងដើម្បីផលប្រយោជន៍របស់អាណត្តិទាយក។

**ចំណាំ៖** ការចំណាយលើពន្ធតុលាការ និងសោហ៊ុយផ្សេងៗ ទៀតក្នុងបណ្ដាកិច្ចការខាងលើ ជាបន្ទុករបស់អាណត្តិទាយកទាំងស្រុង។ក្នុងករណីមិនគោរពកាតព្វកិច្ចនេះអាណត្តិទាយកសុខចិត្តទទួលខុសត្រូវនូវរាល់ការបាត់បង់ផលប្រយោជន៍នានា ដោយខ្លួនឯងផ្ទាល់ ។

ធ្វើនៅ.................... ថ្ងៃទី........ ខែ.......... ឆ្នាំ..............

**បានឃើញ និងយល់ព្រម** — **ស្នាមមេដៃស្ដាំអាណត្តិទាយក**

ទទួលសិទ្ធិតំណាងដោយអាណត្តិឲ្យអាណត្តិទាយក

ឈ្មោះ..............................

ធ្វើនៅ.................... ថ្ងៃទី........ ខែ.......... ឆ្នាំ..............

**ហត្ថលេខា និងត្រា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ឆ្នាំង**
សំណុំរឿងរដ្ឋប្បវេណី
លេខ:២១៤ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២
**សាលក្រមលេខ: ១២ (ក)**
ថ្ងៃពុធ ១២រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក
ព.ស២៥៦៧ ត្រូវនឹងថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣

**តាមនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តកំពង់ឆ្នាំង**

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣

**រៀបក្រមជំនុំជម្រះ**

-ឯកឧត្តម គីម កែ្តណារិន ប្រធានសាលាដំបូងខេត្តកំពង់ឆ្នាំង

**ក្រឡាបញ្ជីសវនាការ**

-លោក ឡុច សាមីធី ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ឆ្នាំង

-ដើមចោទឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៩០ ជាតិខ្មែរ របររកស៊ីមេផ្ទះ អាសយដ្ឋាន ភូមិព្រៃមាន់ ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted] (រស់) ប្តីឈ្មោះ [redacted] (រស់) មានកូន០២នាក់ ។

ដើមចោទមានមេធាវីតំណាងដោយអាណត្តិឈ្មោះ [redacted] ភេទស្រី អត្តលេខ:៥៨៦ ក្រុមមេធាវីអឹម អេស អិន អាសយដ្ឋានផ្ទះលេខ:៣៦$E_0$ ផ្លូវលេខ:៩៩ ក្រុម៦ សង្កាត់បឹងត្របែក ខណ្ឌចំការមន ។

-ចុងចម្លើយឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៨៩ ជាតិខ្មែរ របររកស៊ីប៉ូលីស អាសយដ្ឋានផ្ទះលេខ ២២ ផ្លូវបេតុង ភូមិ៥ សង្កាត់ច្រាំងចំរេះទី២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ អោម សី (រស់) ម្តាយឈ្មោះ [redacted] (រស់) ប្រពន្ធឈ្មោះ [redacted] (រស់) មានកូន០២នាក់ ។

ចុងចម្លើយមានមេធាវីតំណាងដោយអាណត្តិឈ្មោះ [redacted] ភេទប្រុស អត្តលេខ: ១១៨៦ ក្រុមហ៊ុនមេធាវីឈ្មោះសុភាចារស្មាក្តីអង្គរ មានអាសយដ្ឋានស្ថិតនៅបុរីភ្នំពេញថ្មីផាកផ្ទះលេខ:F៦៣៧ វិថីឧកញ៉ាខូវតឹមប៉ាក ភូមិ៥ សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ។

## អង្គហេតុ និងចំណុចពិចារណា

**១-ការទាមទារ:** ដើមចោទសុំលែងលះប្តី ។

**២-ការពន្យល់ត្រួសៗអំពីរឿងក្តី**

ដើមចោទឈ្មោះ នូវ សុភារី បានរៀបការជាមួយចុងចម្លើយឈ្មោះ សាន់ ម៉ាឡៃ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១១ ក្នុងការរួមរស់នៅជាមួយគ្នា គូភាគីមានកូន មានទ្រព្យសម្បត្តិរួម និងមានបំណុលជំពាក់ធនាគារ គូភាគីបានស្ម័គ្រចិត្តលែងលះគ្នា ដោយសាររស់នៅមិនចុះសម្រុងនឹងគ្នា ភាគីដើមចោទក៏បានដាក់ពាក្យសុំលែងលះ បែងចែកទ្រព្យសម្បត្តិរួម បែងចែកបំណុល និងសុំគ្រប់គ្រងកូនទាំងពីរ ។ នៅក្នុងពេលផ្សះផ្សារនៃនីតិវិធីត្រៀមទាញហេតុផល គូភាគីបានធ្វើការព្រមព្រៀងគ្នាបែងចែកកូន ទ្រព្យសម្បត្តិរួម និងសល់ពីការព្រមព្រៀងគ្នា ភាគីដើមចោទសុំគ្រប់គ្រង រីឯភាគីចុងចម្លើយសុំគ្រប់គ្រងពាក់កណ្តាលម្នាក់ បំណុលសុំលក់ទ្រព្យសម្បត្តិសងទៅធនាគារ ។

**៣-ចំណុចវិវាទ:** ដើមចោទសុំគ្រប់គ្រងក្រុមហ៊ុនសាលាបើកបរដែលជាប់មានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មសាលាបង្រៀនបើកបរយានយន្តលេខ: ៧១៩ ដជត ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២ និងចុងចម្លើយសុំសិទ្ធិគ្រប់គ្រងក្រុមហ៊ុននេះពាក់កណ្តាល ។

**៤-ការអះអាងរបស់ភាគី :**

- ដើមចោទបានថ្លែងថា ខ្លួនរៀបអាពាហ៍ពិពាហ៍កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១០ និង បានចុះសំបុត្រអាពាហ៍ពិពាហ៍ កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១០ ដោយក្នុងចំណងអាពាហ៍ពិពាហ៍ ខ្លួនមានកូនចំនួនពីរនាក់ កូនទីមួយឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១ និង កូនទីពីរឈ្មោះ សាន់ អង្គារិទ្ធបញ្ញារើន ភេទប្រុស កើតថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៥ ដោយមិនទាមទារសោហ៊ុយសម្រាប់ចិញ្ចឹមកូនឡើយ និង មានទ្រព្យសម្បត្តិរួមៈ

១-ផ្ទះថ្មលេខ: R២២ មួយល្វែងពីរជាន់កន្លះមានទំហំទទឹង ៤.០១ម៉ែត្រ គុណនឹងបណ្តោយ១៦ម៉ែត្រ មានទីតាំងស្ថិតនៅផ្លូវលំ ភូមិ៩១ សង្កាត់ច្រាំងចំរេះ២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ: ភព ៣៣៧៤៤ ចុះថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០១៦ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និង សុរិយោដីលោក [redacted] ។

២-ដីទំហំ ២៧៨៩ម៉ែត្រការ៉េ មានក្បាលដីលេខ:១០៣ មានទីតាំងស្ថិតនៅភូមិព្រៃមាន់ ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:០៤០៦១១០៩-០១០៣ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី លោក [redacted] ។

៣-ដីឡូត៍ទំហំទទឹង១៤.៥ម៉ែត្រ និងបណ្តោយ២០ម៉ែត្រ មានទីតាំងស្ថិតនៅភូមិទី៤ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។

៤-ដីទំហំ ១៨៤ម៉ែត្រការ៉េ មានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ:១៧៨/១៦ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ចេញដោយមេឃុំសំបូរមាស មានទីតាំងស្ថិតនៅភូមិអន្លង់ស្នែង ឃុំសំបូរមាស ស្រុកមុខកំពូល ខេត្តកណ្តាល ។

៥-ដីទំហំ ២(ពីរ)ហិចតា នៅខាងកើតវត្តព្រះឃ្លាំង មានទីតាំងស្ថិតនៅភូមិសិលា ឃុំស្វាយជ្រុំ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង (ឯកសារដីនៅចុងចម្លើយ) ។

៦-ក្រុមហ៊ុនសាលាបើកបរដៃចំណាប់ មានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម សាលាបង្រៀនបើកបរយានយន្តលេខ: ៧១៩ ដជត ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២ ចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន ។

៧- រថយន្តកាម៉ារី ពណ៌ទឹកប្រាក់ ស៊េរីឆ្នាំ២០០៧ ពាក់ស្លាកលេខ:ភ្នំពេញ 2BA ៨០៥២ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ ។

៨- រថយន្តម៉ាកហាយឡិនឌ័រ ពណ៌ទឹកប្រាក់ ស៊េរីឆ្នាំ២០០៣ ពាក់ស្លាកលេខ: ភ្នំពេញ ២AO ៥៦៥៨ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ ។

៩-រថយន្តកាម៉ារី ចាឡែន ពណ៌ទឹកប្រាក់ ស៊េរីឆ្នាំ២០០២ ពាក់ស្លាកលេខ ភ្នំពេញ ២AC ២៥០៦ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ។

១០-រថយន្តកាម៉ារីឆ្លាម ពណ៌ទឹកមាស ស៊េរីឆ្នាំ១៩៩៧ ពាក់ស្លាកលេខ: ២I ០៨៣១ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ ។

១១- រថយន្តកាម៉ារី ពណ៌បៃតងចាស់ ពាក់ស្លាកលេខ: ភ្នំពេញ ២G ៣៦៥៧ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្ត ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០២ ។

១២- រថយន្តកាម៉ារី ស៊ូត ពណ៌ខ្មៅ ពាក់ស្លាកលេខ: ររ០៣៥៩ ភព២ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តនៅចុងចម្លើយ ។

១៣- រថយន្តលុចស៊ុស ៣៣០ ពណ៌ទឹកមាស សេរីឆ្នាំ២០០៥ ពាក់ស្លាកលេខៈភ្នំពេញ ២BL ២៦៨៣ ចំនួនមួយគ្រឿង មានប័ណ្ណសំគាល់យានយន្តនៅចុងចម្លើយ ។

និងមានបំណុលជំពាក់ធនាគារអេស៊ីលីដា ។

-ចុងចម្លើយបានថ្លែងថាខ្លួនក៏សុខចិត្តលែងប្រពន្ធផងដែរ តែចំពោះខ្លួនសុំគ្រប់គ្រងកូនប្រុសឈ្មោះ [redacted] បញ្ញាវើន ភេទប្រុស កើតថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៥ រីឯកូនស្រីឈ្មោះ [redacted] កើតថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១ សុំប្រគល់ទៅឱ្យប្រពន្ធជាអ្នកមានអំណាចមេបា ដោយមិនទាមទារសោហ៊ុយសម្រាប់ចិញ្ចឹមកូនឡើយ។ ដោយឡែកទ្រព្យសម្បត្តិរួម ខ្លួនទទួលស្គាល់ថាមានចំនួនដូចខាងលើ ។

-ដើមចោទ និងចុងចម្លើយបានថ្លែងថា ខ្លួនទាំងពីរនាក់ ក៏បានព្រមព្រៀងគ្នាផងដែរ គឺរថយន្តដែលត្រូវឱ្យប្រពន្ធមានៈ

-រថយន្តម៉ាកហាយឡិនឌ័រ ពណ៌ទឹកប្រាក់ សេរីឆ្នាំ២០០៣ ពាក់ស្លាកលេខៈ ភ្នំពេញ ២AO ៥៦៥៨ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ ។

-រថយន្តកាម៉ារី បាឡែន ពណ៌ទឹកប្រាក់ សេរីឆ្នាំ២០០២ ពាក់ស្លាកលេខៈ ភ្នំពេញ ២AC ២៥០៦ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ។

-រថយន្តកាម៉ារី ពណ៌បៃតងចាស់ពាក់ស្លាកលេខៈ ភ្នំពេញ ២G ៣៦៥៧ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០២ ។

និងរថយន្តដែលត្រូវបានខ្លួនជាប្ដីមានៈ

- រថយន្តកាម៉ារី ពណ៌ទឹកប្រាក់ សេរីឆ្នាំ២០០៧ ពាក់ស្លាកលេខៈ ភ្នំពេញ 2BA ៨០៥២ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ ។

-រថយន្តកាម៉ារីឆ្លាម ពណ៌ទឹកមាស សេរីឆ្នាំ១៩៩៧ ពាក់ស្លាកលេខៈ ២I ០៨៣១ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ ។

ទ្រព្យសម្បត្តិរួមសល់ពីររថយន្តបែងចែកគ្នាដូចខាងលើត្រូវលក់សងធនាគារ លើកលែងតែដីទំហំ២៧៨៩ម៉ែត្រការ៉េ មានក្បាលដីលេខៈ១០៣ មានទីតាំងស្ថិតនៅភូមិព្រៃមាន់ ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៤០៦១១០៩-០១០៣ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និង សុរិយោដី លោក [redacted] ទុកសម្រាប់កូនទាំងពីរនាក់មានកូនស្រីឈ្មោះ [redacted] សេរីវត្ន និងកូនប្រុសឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៥។ និងសូមបញ្ជាក់ថាដីទំហំ២(ពីរ)ហិចតា នៅខាងកើតវត្តព្រះឃ្លាំង មានទីតាំងស្ថិតនៅភូមិសិលា ឃុំស្វាយជ្រុំ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង និងរថយន្តកាម៉ារីស៊្លិត ពណ៌ខ្មៅ ពាក់ស្លាកលេខៈ ៩០៣៥៩ ភព២ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តនៅចុងចម្លើយ និងរថយន្តលុចស៊ុស ៣៣០ ពណ៌ទឹកមាស សេរីឆ្នាំ២០០៥ ពាក់ស្លាកលេខៈ ភ្នំពេញ ២BL ២៦៨៣ ចំនួនមួយគ្រឿង មានប័ណ្ណសំគាល់យានយន្តនៅចុងចម្លើយ ត្រូវបានខ្លួនជាចុងចម្លើយបានលក់ហើយ ហើយទ្រព្យដែលនៅសល់ពីការលក់នេះ ខ្លួនទាំងពីរនាក់ ព្រមព្រៀងគ្នាលក់សងបំណុលធនាគារអេស៊ីលីដា សល់ពីការសងធនាគារបែងចែកជាពីរចំណែកស្មើគ្នា ។

-ដើមចោទបានថ្លែងថា ខ្លួនសុំគ្រប់គ្រង ក្រុមហ៊ុនសាលាបើកបរវៃចំណាប់ មានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម សាលាបង្រៀនបើកបរយានយន្តលេខ:៧១៥ ជជត ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២ ចេញដោយក្រសួងសាធារណការ និង ដឹកជញ្ជូន ដោយសារក្រុមហ៊ុននេះ មានឈ្មោះខ្លួនជាម្ចាស់ក្រុមហ៊ុន ។

-ចុងចម្លើយបានថ្លែងថា ខ្លួនសុំសិទ្ធិក្រុមហ៊ុនពាក់កណ្ដាល ដល់កូនមានអាយុ១៨ឆ្នាំ សុំប្រគល់ទៅឱ្យកូនទាំងពីរនាក់ ដែលមានឈ្មោះ សាន់ ហេងច័ន្ទសេរីរ័ត្ន ភេទស្រី និងឈ្មោះ សាន់ អង្គារិទ្ធបញ្ញារើន ភេទប្រុស កើតថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៥ ដោយសារតែខ្លួនជាអ្នកបង្កើតទាំងអស់ មានតាំងពីការបង្កើតផ្លាក ឡោហ្គោ លើកយីហោ និង ចាត់ចែងការងារផ្ទៃក្នុង ។

## សំអាងហេតុ

តាមលទ្ធផលនៃការសាកសួរសាមីភាគី ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល , ការទាញហេតុផលដោយផ្ទាល់មាត់ និង ការពិនិត្យភស្តុតាងឃើញថា:

-តាមពាក្យបណ្ដឹងចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២ របស់ដើមចោទមានលក្ខណៈត្រឹមត្រូវ បញ្ជាក់ឱ្យឃើញថា សាលាដំបូងខេត្តកំពង់ឆ្នាំង មានសមត្ថកិច្ចដើម្បីវិនិច្ឆ័យស្របច្បាប់នូវពាក្យបណ្ដឹង ហើយចេញសាលក្រមបានតាមមាត្រា ៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

-តាមពាក្យបណ្ដឹងចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២ ក៏ដូចជាការថ្លែងរបស់ដើមចោទទាមទារ :

១-សុំលែងលះ ។

២-សុំសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរួមទាំងអស់ ។

៣-សុំសិទ្ធិគ្រប់គ្រងកូនពីរនាក់ ។

៤-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ។

-តាមសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍លេខ:៣៤៨ ច.ល ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ របស់មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋានស្រុករលាប្អៀរ បញ្ជាក់ឱ្យឃើញថា ដើមចោទ និង ចុងចម្លើយ ពិតជាប្ដីប្រពន្ធនឹងគ្នាមែន ។

-តាមអង្គហេតុដែលនាំឱ្យគូភាគីលែងលះគ្នាកើតចេញពីការរស់នៅមិនចុះសម្រុងនឹងគ្នា អស់មនោសញ្ចេតនានឹងគ្នា ចំណុចនេះជាមូលហេតុដែលធ្វើឱ្យគូភាគី មិនអាចយកគ្នាជាប្ដីប្រពន្ធបានតទៅទៀត ។

-ទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបានឡើយ ដូចនេះ ការព្រមព្រៀងលែងលះគ្នារបស់ប្ដីប្រពន្ធតុលាការអាចពិចារណាបាន តាមមាត្រា៩៧៩នៃក្រមរដ្ឋប្បវេណី ដោយហេតុថា គូភាគីមានបំណងពិតប្រាកដ ក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ ។

-ក្នុងចំណងប្ដីប្រពន្ធគូភាគីមានកូនពីរនាក់ គឺកូនឈ្មោះ សាន់ ហេងច័ន្ទសេរីរ័ត្ន ភេទស្រី កើតថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១ និងកូនឈ្មោះ សាន់ អង្គារិទ្ធបញ្ញារើន ភេទប្រុស កើតថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៥ នៅអនីតិជននៅឡើយ ដែលគូភាគីបានព្រមព្រៀងគ្នា កូនស្រីឈ្មោះ សាន់ ហេងច័ន្ទសេរីរ័ត្ន ត្រូវបានគ្រប់គ្រងដោយ ដើមចោទជាម្ដាយជាអ្នកមានអំណាចមេបា និងកូនប្រុសឈ្មោះ សាន់ អង្គារិទ្ធបញ្ញារើន ត្រូវបានគ្រប់គ្រងដោយចុងចម្លើយជាឪពុកជាអ្នកមានអំណាចមេបា ដោយមិនទាមទារសោហ៊ុយសម្រាប់ចិញ្ចឹមកូននោះទេ ដែលតប្បីតុលាការយកការយកការព្រមព្រៀងរបស់គូភាគីទុកជាបានការ ។

-បើទោះបីជាដើមចោទជាម្ដាយ និងចុងចម្លើយជាឪពុក ពុំមានអំណាចមេបាគ្រប់គ្រង ចិញ្ចឹមបីបាច់ថែរក្សាកូនណាមួយក៏ដោយ ក៏ដើមចោទជាម្ដាយ និង ចុងចម្លើយជាឪពុក នៅតែមានសិទ្ធិក្នុងការចូលជួបប្រាស្រ័យទាក់ទងសួរសុខទុក្ខកូនបានគ្រប់ពេលវេលា ហើយគូភាគី ត្រូវបង្ករលក្ខណៈងាយស្រួលដល់គ្នាទៅវិញទៅមកផងដែរ តាមមាត្រា១០៤០ និង មាត្រា១០៤១នៃក្រមរដ្ឋប្បវេណី ។

-ក្នុងចំណោមប្តីប្រពន្ធគូភាគីមានទ្រព្យសម្បត្តិរួមគឺ:

១-ផ្ទះថ្មលេខ: R២២ មួយល្វែងពីរជាន់កន្លះមានទំហំទទឹង ៤.០១ម៉ែត្រ គុណនឹងបណ្តោយ១៦ម៉ែត្រ មានទីតាំងស្ថិតនៅផ្លូវលំ ភូមិខ១ សង្កាត់ច្រាំងចំរេះ២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ: ភព ៣៣៧៤៤ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និង សុរិយោដី លោក សារិន វណ្ណា ។

២-ដីទំហំ ២៧៨៩ម៉ែត្រការ៉េ មានក្បាលដីលេខ:១០៣ មានទីតាំងស្ថិតនៅភូមិព្រៃមាន់ ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:០៤០៦១១០៥-០១០៣ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី លោក លី សុភា ។

៣-ដីឡូត៍ទំហំទទឹង១៤.៥ម៉ែត្រ និងបណ្តោយ២០ម៉ែត្រ មានទីតាំងស្ថិតនៅភូមិទី៤ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។

៤-ដីទំហំ ១៨៤ម៉ែត្រការ៉េ មានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ:១៧៨/១៦ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០១៦ ចេញដោយមេឃុំសំបួរមាស មានទីតាំងស្ថិតនៅភូមិអន្លង់ស្លែង ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល ។

៥-ដីទំហំ ២(ពីរ) ហិចតា នៅខាងកើតវត្តព្រះឃ្លាំង មានទីតាំងស្ថិតនៅភូមិសិលា ឃុំស្វាយជ្រុំ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង (ឯកសារដីនៅចុងចម្លើយ) ។

៦-ក្រុមហ៊ុនសាលាបើកបរដៃចំណាប់ មានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម សាលាបង្រៀនបើកបរយានយន្តលេខ: ៧១៥ ដជផ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២ ចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន ។

៧- រថយន្តកាម៉ារី ពណ៌ទឹកប្រាក់ ស៊េរីឆ្នាំ២០០៧ ពាក់ស្លាកលេខ:ភ្នំពេញ 2BA ៨០៥២ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ ។

៨- រថយន្តម៉ាកហាយឡិនឌ័រ ពណ៌ទឹកប្រាក់ ស៊េរីឆ្នាំ២០០៣ ពាក់ស្លាកលេខ: ភ្នំពេញ ២ AO ៥៦៥៨ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ ។

៩-រថយន្តកាម៉ារី បាឡែន ពណ៌ទឹកប្រាក់ ស៊េរីឆ្នាំ២០០២ ពាក់ស្លាកលេខ ភ្នំពេញ ២ AC ២៥០៦ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ។

១០-រថយន្តកាម៉ារីឆ្មាម ពណ៌ទឹកមាស ស៊េរីឆ្នាំ១៩៩៧ ពាក់ស្លាកលេខ: ២I ០៨៣១ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ ។

១១- រថយន្តកាម៉ារី ពណ៌បៃតងចាស់ ពាក់ស្លាកលេខ: ភ្នំពេញ ២G ៣៦៥៧ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្ត ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០២ ។

១២- រថយន្តកាម៉ារីស្ទិត ពណ៌ខ្មៅ ពាក់ស្លាកលេខ: អ០៣៥៩ ភព២ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តនៅចុងចម្លើយ ។

១៣- រថយន្តលុចស៊ីស ៣៣០ ពណ៌ទឹកមាស ស៊េរីឆ្នាំ២០០៥ ពាក់ស្លាកលេខ: ភ្នំពេញ ២BL ២៦៨៣ ចំនួនមួយគ្រឿង មានប័ណ្ណសំគាល់យានយន្តនៅចុងចម្លើយ ។

**គូភាគីបានព្រមព្រៀងចែកគ្នារួមមាន:**

**ក-ភាគីដើមចោទត្រូវបានមាន:**

១-រថយន្តម៉ាកហាយឡិនឌ័រ ពណ៌ទឹកប្រាក់ សេរីឆ្នាំ២០០៣ ពាក់ស្លាកលេខៈភ្នំពេញ ២ AO ៥៦៥៨ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ ។

២-រថយន្តកាម៉ារី បាឡែន ពណ៌ទឹកប្រាក់ សេរីឆ្នាំ២០០២ ពាក់ស្លាកលេខៈ ភ្នំពេញ ២ AC ២៥០៦ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ។

៣-រថយន្តកាម៉ារី ពណ៌បៃតងចាស់ពាក់ស្លាកលេខៈភ្នំពេញ២G ៣៦៥៧ ចំនួន១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០២ ។

**ខ-ភាគីចុងចម្លើយត្រូវបានមានៈ**

១- រថយន្តកាម៉ារី ពណ៌ទឹកប្រាក់ សេរីឆ្នាំ២០០៧ ពាក់ស្លាកលេខៈ ភ្នំពេញ 2BA ៨០៥២ ចំនួន១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ ។

២-រថយន្តកាម៉ារីឆ្មាម ពណ៌ទឹកមាស សេរីឆ្នាំ១៩៩៧ ពាក់ស្លាកលេខៈ ២I០៨៣១ ចំនួន១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ ។

**គ-ទ្រព្យសម្បត្តិព្រមព្រៀងលក់យកប្រាក់ សងធនាគារ និងសល់ពីសងធនាគារចែកគ្នាពាក់កណ្ដាលម្នាក់មានៈ**

១-ផ្ទះថ្មលេខៈR២២ មួយល្វែងពីរជាន់កន្លះមានទំហំទទឹង ៤.០១ម៉ែត្រ គុណនឹងបណ្ដោយ១៦ម៉ែត្រ មានទីតាំងស្ថិត នៅផ្លូវលំភូមិ៩១ សង្កាត់ច្រាំងចំរេះ២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខៈ ភព ៣៣៧៤៤ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និង សុរិយោដី លោក សារិន វណ្ណា ។

២-ដីឡូតិ៍ទំហំទទឹង ១៤.៥ម៉ែត្រ និងបណ្ដោយ២០ម៉ែត្រ មានទីតាំងស្ថិតនៅភូមិ៤ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។

៣-ដីទំហំ១៨៤ម៉ែត្រការ៉េ មានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខៈ ១៧៨/១៦ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ចេញដោយមេឃុំសំបូរមាស មានទីតាំងស្ថិតនៅភូមិអន្លង់ស្វែង ឃុំសំបូរមាស ស្រុកមុខកំពូល ខេត្តកណ្ដាល ។

**ឃ-ទ្រព្យសម្បត្តិប្រគល់ឱ្យកូនទាំងពីរមានៈ**

១-ដីទំហំ២៧៨៩ម៉ែត្រការ៉េ មានក្បាលដីលេខៈ១០៣ មានទីតាំងស្ថិតនៅភូមិព្រៃមាន់ ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។

ដែលគប្បីតុលាការយកការព្រមព្រៀងគ្នានេះទុកជាបានការ ។

-ដោយឡែកទ្រព្យសម្បត្តិ ដែលគូភាគីមិនបានព្រមព្រៀងគ្នាមានៈ ក្រុមហ៊ុនសាលាបើកបរដៃចំណាប់ មានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម សាលាបង្រៀនបើកបរយានយន្តលេខៈ ៧១៩ជជគ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២ ចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន និងត្រូវបានព្យួរលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មរយៈពេល៦ខែ កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៣ គូភាគីមិនមានការព្រមព្រៀងគ្នាឡើយ តែមានឈ្មោះដើមចោទជាម្ចាស់អាជីវកម្ម បង្ហាញឱ្យឃើញថានេះជាទ្រព្យសម្បត្តិដោយឡែករបស់ដើមចោទ ហេតុនេះគប្បីតុលាការធ្វើការសម្រេច ដោយផ្អែកលើមាត្រា ៩៨០នៃក្រមរដ្ឋប្បវេណី ។

-តាមការអះអាងរបស់គូភាគីបានបង្ហាញថា ដើមចោទ និង ចុងចម្លើយមានជំពាក់បំណុលធនាគារអេស៊ីលីដា មិនទាន់បានសងរួចនៅឡើយ តែគូភាគីបានព្រមព្រៀងគ្នារួមគ្នាចេញសងទៅធនាគារ ហេតុនេះតុលាការគប្បីយកការព្រមព្រៀងគ្នាទុកជាបានការ ។

-ដើមចោទបានថ្លែងថា ខ្លួនសុំគ្រប់គ្រង ក្រុមហ៊ុនសាលាបើកបរដៃចំណាប់ មានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម សាលាបង្រៀនបើកបរយានយន្តលេខ:៧១៥ ដជត ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២ ចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន ដោយសារក្រុមហ៊ុននេះ មានឈ្មោះខ្លួនជាម្ចាស់ក្រុមហ៊ុន ។

-ចុងចម្លើយបានថ្លែងថា ខ្លួនសុំសិទ្ធិក្រុមហ៊ុនពាក់កណ្តាល ដល់កូនមានអាយុ១៨ឆ្នាំ សុំប្រគល់ទៅឱ្យកូនទាំងពីរនាក់ ដែលមានឈ្មោះ សាន់ ហេងច័ន្ទសេរីវ័ត្ត ភេទស្រី និងឈ្មោះ សាន់ អង្គារិទ្ធបញ្ញារើន ភេទប្រុស កើតថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៥ ដោយសារតែខ្លួនជាអ្នកបង្កើតទាំងអស់ មានតាំងពីការបង្កើតផ្លាក លោហ្គោ លើកយីហោ និង ចាត់ចែងការងារផ្ទៃក្នុង ។

## សំអាងហេតុ

តាមលទ្ធផលនៃការសាកសួរសាមីភាគី ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល , ការទាញហេតុផលដោយផ្ទាល់មាត់ និង ការពិនិត្យភស្តុតាងឃើញថា:

-តាមពាក្យបណ្តឹងចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២ របស់ដើមចោទមានលក្ខណៈត្រឹមត្រូវ បញ្ជាក់ឱ្យឃើញថា សាលាដំបូងខេត្តកំពង់ឆ្នាំង មានសមត្ថកិច្ចដើម្បីវិនិច្ឆ័យស្របច្បាប់នូវពាក្យបណ្តឹង ហើយចេញសាលក្រមបានតាមមាត្រា ៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

-តាមពាក្យបណ្តឹងចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២ ក៏ដូចជាការថ្លែងរបស់ដើមចោទទាមទារ :

១-សុំលែងលះ ។

២-សុំសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរួមទាំងអស់ ។

៣-សុំសិទ្ធិគ្រប់គ្រងកូនពីរនាក់ ។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

-តាមសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍លេខ:៣៤៨ ច.ល ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ របស់មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋានស្រុករលាប្អៀរ បញ្ជាក់ឱ្យឃើញថា ដើមចោទ និង ចុងចម្លើយ ពិតជាប្តីប្រពន្ធនឹងគ្នាមែន ។

-តាមអង្គហេតុដែលនាំឱ្យគូភាគីលែងលះគ្នាកើតចេញពីការរស់នៅមិនចុះសម្រុងនឹងគ្នា អស់មនោសញ្ចេតនានឹងគ្នា ចំណុចនេះជាមូលហេតុដែលធ្វើឱ្យគូភាគី មិនអាចយកគ្នាជាប្តីប្រពន្ធបានតទៅទៀត ។

-ទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបានឡើយ ដូចនេះ ការព្រមព្រៀងលែងលះគ្នារបស់ប្តីប្រពន្ធតុលាការអាចពិចារណាបាន តាមមាត្រា៩៧៩នៃក្រមរដ្ឋប្បវេណី ដោយហេតុថា គូភាគីមានបំណងពិតប្រាកដ ក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ ។

-ក្នុងចំណងប្តីប្រពន្ធគូភាគីមានកូនពីរនាក់ គឺកូនឈ្មោះ សាន់ ហេងច័ន្ទសេរីវ័ត្ត ភេទស្រី កើតថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១ និងកូនឈ្មោះ សាន់ អង្គារិទ្ធបញ្ញារើន ភេទប្រុស កើតថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៥ នៅអនីតិជននៅឡើយ ដែលគូភាគីបានព្រមព្រៀងគ្នា កូនស្រីឈ្មោះ សាន់ ហេងច័ន្ទសេរីវ័ត្ត ត្រូវបានគ្រប់គ្រងដោយ ដើមចោទជាម្តាយជាអ្នកមានអំណាចមេបា និងកូនប្រុសឈ្មោះ សាន់ អង្គារិទ្ធបញ្ញារើន ត្រូវបានគ្រប់គ្រងដោយចុងចម្លើយជាឪពុកជាអ្នកមានអំណាចមេបា ដោយមិនទាមទារសោហ៊ុយសម្រាប់ចិញ្ចឹមកូននោះទេ ដែលតប្បីតុលាការយកការយកការព្រមព្រៀងរបស់គូភាគីទុកជាបានការ ។

-បើទោះបីជាដើមចោទជាម្តាយ និងចុងចម្លើយជាឪពុក ពុំមានអំណាចមេបាគ្រប់គ្រង ចិញ្ចឹមបីបាច់ថែរក្សាកូនណាមួយក៏ដោយ ក៏ដើមចោទជាម្តាយ និង ចុងចម្លើយជាឪពុក នៅតែមានសិទ្ធិក្នុងការចូលជួបប្រាស្រ័យទាក់ទងសួរសុខទុក្ខកូនបានគ្រប់ពេលវេលា ហើយគូភាគី ត្រូវបង្ករលក្ខណៈងាយស្រួលដល់គ្នាទៅវិញទៅមកផងដែរ តាមមាត្រា១០៤០ និង មាត្រា១០៤១នៃក្រមរដ្ឋប្បវេណី ។

-ក្នុងចំណោមប្តីប្រពន្ធគូភាគីមានទ្រព្យសម្បត្តិរួមគឺ:

១-ផ្ទះថ្មលេខ: R២២ មួយល្វែងពីរជាន់កន្លះមានទំហំទទឹង ៤.០១ម៉ែត្រ គុណនឹងបណ្តោយ១៦ម៉ែត្រ មានទីតាំងស្ថិតនៅផ្លូវលំ ភូមិ១១ សង្កាត់ច្រាំងចំរេះ២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ: ភព ៣៣៧៤៤ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និង សុរិយោដី លោក សារិន វណ្ណា ។

២-ដីទំហំ ២៧៨៩ម៉ែត្រការ៉េ មានក្បាលដីលេខ:១០៣ មានទីតាំងស្ថិតនៅភូមិព្រៃមាន់ ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:០៤០៦១១០៥-០១០៣ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី លោក លី សុភា ។

៣-ដីឡូត៍ទំហំទទឹង១៤.៥ម៉ែត្រ និងបណ្តោយ២០ម៉ែត្រ មានទីតាំងស្ថិតនៅភូមិទី៤ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។

៤-ដីទំហំ ១៨៤ម៉ែត្រការ៉េ មានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ:១៧៨/១៦ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០១៦ ចេញដោយមេឃុំសំបូរមាស មានទីតាំងស្ថិតនៅភូមិអន្លង់ស្លែង ឃុំសំបូរមាស ស្រុកមុខកំពូល ខេត្តកណ្តាល ។

៥-ដីទំហំ ២(ពីរ) ហិចតា នៅខាងកើតវត្តព្រះឃ្លាំង មានទីតាំងស្ថិតនៅភូមិសិលា ឃុំស្វាយជ្រុំ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង (ឯកសារដីនៅចុងចម្លើយ) ។

៦-ក្រុមហ៊ុនសាលាបើកបរដៃចំណាប់ មានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម សាលាបង្រៀនបើកបរយានយន្តលេខ: ៧១៩ ដជត ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២ ចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន ។

៧- រថយន្តកាម៉ារី ពណ៌ទឹកប្រាក់ សេរីឆ្នាំ២០០៧ ពាក់ស្លាកលេខ:ភ្នំពេញ 2BA ៨០៥២ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ ។

៨- រថយន្តម៉ាកហាយឡិនឌ័រ ពណ៌ទឹកប្រាក់ សេរីឆ្នាំ២០០៣ ពាក់ស្លាកលេខ: ភ្នំពេញ ២ AO ៥៦៥៨ ចំនួន ១ គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ ។

៩-រថយន្តកាម៉ារី បាឡែន ពណ៌ទឹកប្រាក់ សេរីឆ្នាំ២០០២ ពាក់ស្លាកលេខ ភ្នំពេញ ២ AC ២៥០៦ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ។

១០-រថយន្តកាម៉ារីឆ្អាម ពណ៌ទឹកមាស សេរីឆ្នាំ១៩៩៧ ពាក់ស្លាកលេខ: ២I ០៨៣១ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ ។

១១- រថយន្តកាម៉ារី ពណ៌បៃតងចាស់ ពាក់ស្លាកលេខ: ភ្នំពេញ ២G ៣៦៥៧ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្ត ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០២ ។

១២- រថយន្តកាម៉ារីស៊ិត ពណ៌ខ្មៅ ពាក់ស្លាកលេខ: ឆ០៣៥៩ ភព២ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តនៅចុងចម្លើយ ។

១៣- រថយន្តលុចស៊ុស ៣៣០ ពណ៌ទឹកមាស សេរីឆ្នាំ២០០៥ ពាក់ស្លាកលេខ: ភ្នំពេញ ២BL ២៦៨៣ ចំនួនមួយគ្រឿង មានប័ណ្ណសំគាល់យានយន្តនៅចុងចម្លើយ ។

**គូភាគីបានព្រមព្រៀងចែកគ្នារួមមាន:**

**ក-ភាគីដើមចោទត្រូវបានមាន:**

១-រថយន្តម៉ាកហាយឡិនឌ័រ ពណ៌ទឹកប្រាក់ សេរីឆ្នាំ២០០៣ ពាក់ស្លាកលេខ:ភ្នំពេញ ២ AO ៥៦៥៨ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ ។

២-រថយន្តកាម៉ារី បាឡែន ពណ៌ទឹកប្រាក់ សេរីឆ្នាំ២០០២ ពាក់ស្លាកលេខ: ភ្នំពេញ ២ AC ២៥០៦ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ។

៣-រថយន្តកាម៉ារី ពណ៌បៃតងចាស់ពាក់ស្លាកលេខ:ភ្នំពេញ២G ៣៦៥៧ ចំនួន១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០២ ។

**ខ-ភាគីចុងចម្លើយត្រូវបានមាន:**

១- រថយន្តកាម៉ារី ពណ៌ទឹកប្រាក់ សេរីឆ្នាំ២០០៧ ពាក់ស្លាកលេខ: ភ្នំពេញ 2BA ៨០៥២ ចំនួន១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ ។

២-រថយន្តកាម៉ារីឆ្លាម ពណ៌ទឹកមាស សេរីឆ្នាំ១៩៩៧ ពាក់ស្លាកលេខ: ២I០៨៣១ ចំនួន១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ ។

**គ-ទ្រព្យសម្បត្តិព្រមព្រៀងលក់យកប្រាក់ សងធនាគារ និងសល់ពីសងធនាគារចែកគ្នាពាក់កណ្ដាលម្នាក់មាន:**

១-ផ្ទះថ្មលេខ:R២២ មួយល្វែងពីរជាន់កន្លះមានទំហំទទឹង ៤.០១ម៉ែត្រ គុណនឹងបណ្ដោយ១៦ម៉ែត្រ មានទីតាំងស្ថិត នៅផ្លូវលំភូមិខ១ សង្កាត់ច្រាំងចំរេះ២ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ: ភព ៣៣៧៤៤ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និង សុរិយោដី លោក សារិន វណ្ណា ។

២-ដីឡូត៍ទំហំទទឹង ១៤.៥ម៉ែត្រ និងបណ្ដោយ២០ម៉ែត្រ មានទីតាំងស្ថិតនៅភូមិ៤ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។

៣-ដីទំហំ១៨៤ម៉ែត្រការ៉េ មានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ: ១៧៨/១៦ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ចេញដោយមេឃុំសំបូរមាស មានទីតាំងស្ថិតនៅភូមិអន្លង់ស្វែង ឃុំសំបូរមាស ស្រុកមុខកំពូល ខេត្តកណ្ដាល ។

**ឃ-ទ្រព្យសម្បត្តិប្រគល់ឱ្យកូនទាំងពីរមាន:**

១-ដីទំហំ២៧៨៩ម៉ែត្រការ៉េ មានក្បាលដីលេខ:១០៣ មានទីតាំងស្ថិតនៅភូមិព្រៃមាន់ ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។

ដែលគប្បីតុលាការយកការព្រមព្រៀងគ្នានេះទុកជាបានការ ។

-ដោយឡែកទ្រព្យសម្បត្តិ ដែលគូភាគីមិនបានព្រមព្រៀងគ្នាមាន: ក្រុមហ៊ុនសាលាបើកបរវៃធំណាប់ មានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម សាលាបង្រៀនបើកបរយានយន្តលេខ: ៧១៩៥៥៥ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២ ចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន និងត្រូវបានព្យួរលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មរយៈពេល៦ខែ កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៣ គូភាគីមិនមានការព្រមព្រៀងគ្នាឡើយ តែមានឈ្មោះដើមចោទជាម្ចាស់អាជីវកម្ម បង្ហាញឱ្យឃើញថានេះជាទ្រព្យសម្បត្តិដោយឡែករបស់ដើមចោទ ហេតុនេះគប្បីតុលាការធ្វើការសម្រេច ដោយផ្អែកលើមាត្រា ៩៨០នៃក្រមរដ្ឋប្បវេណី ។

-តាមការអះអាងរបស់គូភាគីបានបង្ហាញថា ដើមចោទ និង ចុងចម្លើយមានជំពាក់បំណុលធនាគារអេស៊ីលីដា មិនទាន់បានសងរួចនៅឡើយ តែគូភាគីបានព្រមព្រៀងគ្នារួមគ្នាចេញសងទៅធនាគារ ហេតុនេះតុលាការគប្បីយកការព្រមព្រៀងគ្នាទុកជាបានការ ។

-អនុវត្តតាមមាត្រា៦៤នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្តី គប្បីជាបន្ទុករបស់ចុងចម្លើយ ។

## សេចក្តីសម្រេចបញ្ចប់

១-ឱ្យដើមចោទឈ្មោះ ឆួន សុគារី និង ចុងចម្លើយឈ្មោះ សាន់ ម៉ារ៉ៃឡ លែងលះគ្នាតាមការព្រមព្រៀង តាមមាត្រា៩៧៥ នៃក្រមរដ្ឋប្បវេណី ។

២-ប្រគល់កូនឈ្មោះ **សាន់ រោហចច័ន្ទសេរីរ័ត្ន** ភេទស្រី កើតថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១ ឱ្យទៅដើមចោទឈ្មោះ ឆួន សុគារី ជាម្តាយមានអំណាចមេបាគ្រប់គ្រង ចិញ្ចឹមបីបាច់ថែរក្សា រហូតដល់កូនមាននីតិភាព តាមការព្រមព្រៀងគ្នា តាមមាត្រា ១០៣៧នៃក្រមរដ្ឋប្បវេណី។

៣-ប្រគល់កូនឈ្មោះ **សាន់ អគ្គារិទ្ធបញ្ញារីន** ភេទប្រុស កើតថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៥ ឱ្យទៅចុងចម្លើយឈ្មោះ សាន់ ម៉ារ៉ៃឡ ជាឪពុកមានអំណាចមេបាគ្រប់គ្រង ចិញ្ចឹមបីបាច់ថែរក្សា រហូតដល់កូនមាននីតិភាព តាមការព្រមព្រៀងគ្នា តាមមាត្រា ១០៣៧នៃក្រមរដ្ឋប្បវេណី។

៤-ដើមចោទឈ្មោះ ឆួន សុគារី ជាម្តាយ និងចុងចម្លើយឈ្មោះ សាន់ ម៉ារ៉ៃឡ ជាឪពុក ដែលពុំមានអំណាចមេបាលើកូន ក្រោយពេលលែងលះគ្នា មានសិទ្ធិចូលជួបប្រាស្រ័យទាក់ទងជាមួយកូន តាមការនឹករលឹកគ្រប់ពេលវេលា។ ភាគីដើមចោទជាម្តាយ និង ភាគីចុងចម្លើយជាឪពុក ត្រូវបង្កលក្ខណៈងាយស្រួលដល់គ្នាទៅវិញទៅមកផងដែរ តាមមាត្រា ១០៤០នៃក្រមរដ្ឋប្បវេណី ។

**៥-ប្រគល់ទ្រព្យសម្បត្តិរួមមាន:**

-រថយន្តម៉ាកហាយឡិនឌ័រ ពណ៌ទឹកប្រាក់ ស៊េរីឆ្នាំ២០០៣ ពាក់ស្លាកលេខ: ភ្នំពេញ ២AO ៥៦៥៨ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ ។

-រថយន្តកាម៉ារី បាខ្មែន ពណ៌ទឹកប្រាក់ ស៊េរីឆ្នាំ២០០២ ពាក់ស្លាកលេខ ភ្នំពេញ ២AC ២៥០៦ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ។

-រថយន្តកាម៉ារី ពណ៌បៃតងចាស់ពាក់ស្លាកលេខ: ភ្នំពេញ ២G ៣៦៥៧ ចំនួន ១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០២ ។

ទៅឱ្យដើមចោទឈ្មោះ ឆួន សុគារី គ្រប់គ្រង តាមការព្រមព្រៀងរបស់គូភាគី តាមមាត្រា៩៨០នៃក្រមរដ្ឋប្បវេណី ។

**៦-ប្រគល់ទ្រព្យសម្បត្តិរួមមាន:**

- រថយន្តកាម៉ារី ពណ៌ទឹកប្រាក់ ស៊េរីឆ្នាំ២០០៧ ពាក់ស្លាកលេខ: ភ្នំពេញ 2BA ៨០៥២ ចំនួន១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ ។

-រថយន្តកាម៉ារីឆ្លាម ពណ៌ទឹកមាស ស៊េរីឆ្នាំ១៩៩៧ ពាក់ស្លាកលេខ: ២l០៨៣១ ចំនួន១គ្រឿង មានប័ណ្ណសំគាល់យានយន្តចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ ។

ទៅឱ្យចុងចម្លើយឈ្មោះ សាន់ ម៉ារ៉ៃឡ គ្រប់គ្រង តាមការព្រមព្រៀងរបស់គូភាគី តាមមាត្រា៩៨០នៃក្រមរដ្ឋប្បវេណី ។

**៧-ប្រគល់ទ្រព្យសម្បត្តិរួមមាន:**ដីទំហំ២៧៨៩ម៉ែត្រការ៉េ មានក្បាលដីលេខ:១០៣ មានទីតាំងស្ថិតនៅភូមិព្រែកមាន់ ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ឱ្យទៅកូនឈ្មោះ សាន់ រោហចច័ន្ទសេរីរ័ត្ន ភេទស្រី កើតថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១ និងកូនឈ្មោះ សាន់ អគ្គារិទ្ធបញ្ញារីន ភេទប្រុស កើតថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៥ ជាអ្នកគ្រប់គ្រង នៅ

ពេលកុមារទាំងពីរមានអាយុនីតិភាព ដោយមានដើមចោទឈ្មោះ នួច សុភារី និងចុងចម្លើយឈ្មោះ សាន់ ម៉ារ៉ៃឡ ជាអ្នកមើលថែទាំក្នុងកំឡុងពេលកុមារទាំងពីរនៅអនីតិជននៅឡើយ ។

**៨-ប្រគល់ទ្រព្យសម្បត្តិមាន:** ក្រុមហ៊ុនសាលាបើកបរដៃចំណាប់មានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មសាលាបង្រៀនបើកបរយានយន្តលេខ: ៧១៩ ជជត ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២ ទៅឱ្យដើមចោទឈ្មោះ នួច សុភារី ចាប់ពីពេលនេះតទៅ ។

**៩-ទ្រព្យសម្បត្តិរួមត្រូវលក់សងទៅធនាគារអេស៊ីលីដារួមមាន:**

-ផ្ទះថ្មលេខ:R២២ មួយល្វែងពីរជាន់កន្លះមានទំហំទទឹង ៤.០១ម៉ែត្រ គុណនឹងបណ្តោយ១៦ម៉ែត្រ មានទីតាំងស្ថិតនៅផ្លូវលំភូមិខ១ សង្កាត់ច្រាំងចំរេះ២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ: ភព ៣៣៧៤៤ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និង សុរិយោដី លោក សារិន វណ្ណា ។

-ដីឡូត៍ទំហំទទឹង ១៤.៥ម៉ែត្រ និងបណ្តោយ២០ម៉ែត្រ មានទីតាំងស្ថិតនៅភូមិ៤ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។

-ដីទំហំ១៨៤ម៉ែត្រការ៉េ មានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ: ១៧៨/១៦ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០១៦ ចេញដោយមេឃុំសំបួរមាស មានទីតាំងស្ថិតនៅភូមិអន្លង់ស្វែង ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល ។

តាមការព្រមព្រៀងរបស់គូភាគី តាមមាត្រា ៩៨០នៃក្រមរដ្ឋប្បវេណី ។

១០-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

សាលក្រមនេះ ប្រកាសជាសាធារណៈនៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ។

ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។៩៤

ចៅក្រម

ហត្ថលេខា និង ត្រា: **គឹម វ័ណ្ណារិន**

---

បានឃើញ

ចៅក្រម

គឹម វ័ណ្ណារិន

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ១២រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

កំពង់ឆ្នាំង ,ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣

ក្រឡាបញ្ជី

ឡុប សាមីធី

សាលាដំបូងរាជធានីភ្នំពេញ

លេខ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## **លិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រម**

**យើង តឹក ស្រីមុំ ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ**

-បានឃើញ មាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម នស/រកម/០៧០៦/២១ ចុះថ្ងៃទី ០៦.០៧.២០០៦ ។

-បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូង រាជធានីភ្នំពេញ ។

-បានឃើញ សាលក្រមលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ពាក្យសុំចុះថ្ងៃទី ខែ ឆ្នាំ របស់មេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ ដែលមានខ្លឹមសារសុំលិខិតបញ្ជាក់ការចូលស្ថាពរ នៃសាលក្រមលេខ ចុះថ្ងៃទី ខែធ្នូ ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ សេចក្តីអនុញ្ញាត ចុះថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ប្រធានសាលាដំបូងរាជធានីភ្នំពេញ។

## **សូមបញ្ជាក់ថា**

១/សាលក្រមលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ បានចូលជា ចាប់ពីថ្ងៃទី ខែ ឆ្នាំ រួចហើយ ។

២/លិខិតបញ្ជាក់ការចូលស្ថាពរនៃសាលក្រមនេះ ចេញឲ្យសាមីខ្លួន ដើម្បីយកទៅប្រើប្រាស់តាមផ្លូវច្បាប់ ។

ថ្ងៃ ខែ ឆ្នាំ ព.ស

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

**ក្រឡាបញ្ជី**

តឹក ស្រីមុំ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ
ចូល លេខ
ថ្ងៃទី ខែ ឆ្នាំ
ម៉ោង

## ពាក្យបណ្តឹងឧទ្ធរណ៍

ខ្ញុំបាទ            កើតនៅថ្ងៃទី      ខែ      ឆ្នាំ      កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ            ចុះថ្ងៃទី      ខែ      ឆ្នាំ      មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅផ្ទះលេខ១៧៨ ផ្លូវលេខ      ភូមិ      សង្កាត់      ខណ្ឌ      រាជធានីភ្នំពេញ ទូរស័ព្ទលេខ៖            ។

**សូមគោរពជូន**

**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

*សូមតាមរៀងៗ*

**កម្មវត្ថុ** ៖ សុំប្តឹងឧទ្ធរណ៍ចំពោះ**សាលក្រមរដ្ឋប្បវេណីលេខ៖**            **ចុះថ្ងៃទី      ខែ      ឆ្នាំ**      របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់សេចក្តីសម្រេចបញ្ចប់**ចំណុច ២** និងចំណុចដែលតុលាការមិនបានសម្រេចសេចក្តីតាមការទាមទាររបស់ខ្ញុំបាទ ដែលទាក់ទងនឹងទ្រព្យដោយឡែកដូចបានរៀបរាប់ក្នុង**ចំណុច ២ នៃសេចក្តីថ្លែងការណ៍បន្ថែម** របស់លោក**មេធាវី**            ចុះថ្ងៃទី      ខែ      ឆ្នាំ      ។

**យោង** ៖ **សាលក្រមរដ្ឋប្បវេណីលេខ៖**            **ចុះថ្ងៃទី      ខែ      ឆ្នាំ**      របស់សាលាដំបូងរាជធានីភ្នំពេញ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ កាលពីថ្ងៃទី      ខែ      ឆ្នាំ      សាលាដំបូងរាជធានីភ្នំពេញបានប្រកាស**សាលក្រមរដ្ឋប្បវេណីលេខ៖**      **ចុះថ្ងៃទី      ខែ      ឆ្នាំ**      ជាសាធារណៈ និងបានប្រគល់សាលក្រមនេះមកឱ្យខ្ញុំបាទ តាមរយៈមេធាវីតំណាងដោយអាណត្តិរបស់ខ្ញុំបាទ នៅថ្ងៃទី      ខែ      ឆ្នាំ      ។

ដោយហេតុថា ខ្ញុំបាទមិនសុខចិត្តចំពោះសេចក្តីសម្រេចនៃសាលក្រមខាងលើនេះត្រង់**ចំណុច ២** ទាំងស្រុង និងចំណុចដែលតុលាការមិនបានសម្រេចសេចក្តីតាមការទាមទាររបស់ខ្ញុំបាទ ទាក់ទងនឹងទ្រព្យដោយឡែករបស់ខ្ញុំបាទ ដែលរួមមានសម្ភារៈ ដូចជា ក្តារពុម្ព, ទិប, ជន្លួស, ម៉ូទ័របុក, ម៉ូទ័រស្ពាន, ម៉ាស៊ីនបង្ហាប់ និងសម្ភារៈសំណង់ផ្សេងទៀត ដូចដែលបានរៀបរាប់ក្នុង**ចំណុច ២ នៃសេចក្តីថ្លែងការណ៍បន្ថែម** របស់លោក**មេធាវី** (មេធាវីតំណាងដោយអាណត្តិរបស់ខ្ញុំបាទ) ចុះថ្ងៃទី      ខែ      ឆ្នាំ      ។

សេចក្តីសម្រេចនេះ មានភាពអយុត្តិធម៌ និងធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ខ្ញុំបាទ ហេតុដូច្នេះហើយ ទើបខ្ញុំបាទដាក់ពាក្យបណ្តឹងឧទ្ធរណ៍ចំពោះ**សាលក្រមរដ្ឋប្បវេណីលេខ៖**      **ចុះថ្ងៃទី      ខែ      ឆ្នាំ**      របស់សាលាដំបូងរាជធានីភ្នំពេញត្រង់សេចក្តីសម្រេចបញ្ចប់**ចំណុច ២** និងចំណុច

ដែលតុលាការមិនបានសម្រេចសេចក្តីតាមការទាមទាររបស់ខ្ញុំបាទ ដែលទាក់ទងនឹងទ្រព្យដោយឡែករួចបាន រៀបរាប់ក្នុង**ចំណុច ២ នៃសេចក្តីថ្លែងការណ៍បន្ថែម** របស់លោក**មេធាវី** ចុះថ្ងៃទី ខែ ឆ្នាំ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាទទួលពាក្យបណ្តឹងឧទ្ធរណ៍របស់ខ្ញុំបាទខាងលើ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃ ខែ ឆ្នាំ ព.ស

ថ្ងៃទី ខែ ឆ្នាំ

**ស្នាមមេដៃស្តាំ**

<u>ជូនភ្ជាប់មកជាមួយនូវៈ</u>

- សាលក្រមរដ្ឋប្បវេណីលេខៈ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ (ច្បាប់ថតចម្លងមួយច្បាប់)។
- សេចក្តីថ្លែងការណ៍បន្ថែម ចុះថ្ងៃទី ខែ ឆ្នាំ របស់លោកមេធាវី (ច្បាប់ថតចម្លងមួយច្បាប់)។

ដែលតុលាការមិនបានសម្រេចសេចក្តីតាមការទាមទាររបស់ខ្ញុំបាទ ដែលទាក់ទងនឹងទ្រព្យដោយឡែកដូចបានរៀបរាប់ក្នុង**ចំណុច ២ នៃសេចក្តីថ្លែងការណ៍បន្ថែម** របស់លោក**មេធាវី** ចុះថ្ងៃទី ខែ ឆ្នាំ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាទទួលពាក្យបណ្តឹងឧទ្ធរណ៍របស់ខ្ញុំបាទខាងលើ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ៕

ថ្ងៃ ខែ ឆ្នាំ ព.ស

ថ្ងៃទី ខែ ឆ្នាំ

**ស្នាមមេដៃស្តាំ**

ជូនភ្ជាប់មកជាមួយនូវ៖

- សាលក្រមរដ្ឋប្បវេណីលេខ៖ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ (ច្បាប់ថតចម្លងមួយច្បាប់)។
- សេចក្តីថ្លែងការណ៍បន្ថែម ចុះថ្ងៃទី ខែ ឆ្នាំ របស់លោកមេធាវី (ច្បាប់ថតចម្លងមួយច្បាប់)។